មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

## របាយការណ៍ប្រចាំឆ្នាំ៖ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤




ស្កេនដើម្បីអាន

ខែវិច្ឆិកា ឆ្នាំ២០២៤

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ និងឯករាជ្យ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ រូបសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌ស ហើរចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យថា គឺការទាមទារសេរីភាពនៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូម**ចូលទៅកាន់** www.cchrcambodia.org ។

## អំពីរបាយការណ៍

របាយការណ៍នេះគឺជាលទ្ធផលនៃគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា។ គម្រោងនេះបានចាប់ផ្តើមអនុវត្តដំបូងនៅក្នុងខែកញ្ញា ឆ្នាំ២០២០ ក្នុងគោលបំណងពង្រីកលំហសេរីភាពខាងការបញ្ចេញមតិ និងបរិយាកាសពហុនិយមនិងឯករាជ្យសម្រាប់ប្រព័ន្ធផ្សព្វផ្សាយដែលសេរី និងដើម្បីបង្កើនឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងដំណើរការប្រជាធិបតេយ្យ និងធ្វើការសម្រេចចិត្តដោយការទទួលព័ត៌មានពេញលេញ។

របាយការណ៍នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទីបួន ដែលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជាបានរៀបចំតាត់តែងឡើង។ របាយការណ៍ឆ្នាំទីមួយ ទីពីរ និង ទីបី ត្រូវបានចេញផ្សាយជាបន្តបន្ទាប់គ្នានៅក្នុងខែមេសា ឆ្នាំ២០២២ ខែវិច្ឆិកា ឆ្នាំ២០២២ និងខែវិច្ឆិកា ឆ្នាំ២០២៣ ហើយអាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក៖ https://cchrcambodia.org ។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះអាចរៀបចំឡើងទៅបានដោយមានការចូលរួមចំណែកដ៏មានតម្លៃពីសំណាក់បុគ្គល និងស្ថាប័ន ជាច្រើន។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលបានចែករំលែកបទពិសោធន៍ និងទស្សនៈយល់ឃើញ ដោយបានលើកនូវបញ្ហាប្រឈមផ្ទាល់នៃសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការលះបង់កម្លាំងកាយចិត្តរបស់ក្រុមការងារស្រាវជ្រាវ ដែលបានធ្វើការប្រមូល ការវិភាគ និងការរាយការណ៍ទិន្នន័យនេះយ៉ាងល្អិតល្អន់ ដែលអាចឱ្យយើងធ្វើការបោះពុម្ពផ្សាយរបាយការណ៍នេះទៅបាន។ យើងខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះបុគ្គល និងស្ថាប័នដែលបានផ្តល់មតិចូលរួមដ៏មានតម្លៃ និងការគាំទ្រពេញមួយដំណើរការស្រាវជ្រាវនេះ។ ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់ម្ចាស់ជំនួយ និងដៃគូ ដែលបានប្តេជ្ញា

ចិត្តចំពោះការគាំទ្រសិទ្ធិមនុស្ស និងសេរីភាពខាងការបញ្ចេញមតិ ដែលធ្វើឱ្យគម្រោងនេះអាចអនុវត្តទៅបាន។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើអ្នកមានសំណួរ ឬចង់ផ្តល់មតិចូលរួមទៅលើរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org។ របាយការណ៍នេះ ក៏ដូចជា ឯកសារបោះពុម្ពផ្សាយផ្សេងៗទៀតរបស់ ម.ស.ម.ក អាចស្វែងរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក. www.cchrcambodia.org ឬនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org របស់ ម.ស.ម.ក ដែលទទួលបានពានរង្វាន់។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្រាបែក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

# មាតិកា


មាតិកា ..... i

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ..... ii

វិសាលភាព និងវិធីសាស្រ្តស្រាវជ្រាវ ..... ១

ខ្លឹមសារសង្ខេប ..... ៣

សេចក្តីផ្តើម ..... ៥

I. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ..... ៨

II. ក្របខណ្ឌច្បាប់ស្តីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ..... ១០

III. ការវិភាគផ្នែកច្បាប់ទៅលើការវិវត្តនៃច្បាប់ថ្មីៗបំផុត ..... ១១

IV. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ..... ១៤

៤.១. ស្ថានភាពនៃសេរីភាពសារព័ត៌មាន ..... ១៥

៤ ២.ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស ..... ៣៨

៤.៣. ស្ថានភាពនៃសិទ្ធិទទួលព័ត៌មាន ..... ៥២

V. សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ..... ៥៨

VI. ឧបសម្ព័ន្ធ ..... ៦២

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| **កម្ពុជា** | ព្រះរាជាណាចក្រកម្ពុជា |
| **រដ្ឋធម្មនុញ្ញ** | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| **ម.ស.ម.ក** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| **ក.អ.ស.ព.ន** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| **ការិយាល័យឧត្តមស្នងការ** | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| **រដ្ឋាភិបាល** | រាជរដ្ឋាភិបាលកម្ពុជា |
| **និយ័តករ** | និយតករទូរគមនាគមន៍កម្ពុជា |
| **ស.ស.ស.ម** | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| **អ.ស.ប្រ** | អង្គការសហប្រជាជាតិ |
| **យូណេស្កូ** | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| **គ.ស.ម.អ.ស.ប្រ** | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| **វីអូអេ** | វិទ្យុសំឡេងសហរដ្ឋអាមេរិក |
| **វីអូឌី** | វិទ្យុសំឡេងប្រជាធិបតេយ្យ |

# វិសាលភាព និងវិធីសាស្ត្រស្រាវជ្រាវ

## វិសាលភាព

របាយការណ៍នេះបង្ហាញអំពីព័ត៌មានសំខាន់ៗ ពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សិទ្ធិទទួលព័ត៌មាន និងរបកគំហើញទាក់ទងនឹងស្ថានភាពនៃសិទ្ធិទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា») ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ («អំឡុងពេលនៃរបាយការណ៍»)។ របាយការណ៍ប្រចាំឆ្នាំនេះ ផ្តោតជាពិសេសទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស អ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដូចជាសិទ្ធិទទួលព័ត៌មានរបស់អ្នកសារព័ត៌មាន និងសាធារណជននៅកម្ពុជា។

## វិធីសាស្ត្រស្រាវជ្រាវ

ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះ បានចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាជាលក្ខណៈប្រព័ន្ធដែលប្រមូលមកពីប្រភពជាច្រើនផ្សេងៗគ្នា។ ដើម្បីចងក្រងរបាយការណ៍អំពីបច្ចុប្បន្នភាពនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននេះ ការសិក្សាស្រាវជ្រាវលើទិន្នន័យដែលមានស្រាប់ត្រូវបានធ្វើឡើងដើម្បីបង្ហាញអំពីក្របខណ្ឌច្បាប់អន្តរជាតិ និងច្បាប់ជាតិពាក់ព័ន្ធនឹងសិទ្ធិទាំងនេះ។ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម និងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានត្រូវបានយកមកសិក្សាពិនិត្យ ដើម្បីធ្វើការវាយតម្លៃទៅលើអនុលោមភាពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ទិន្នន័យដែលបានប្រើក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃ និងការរាយការណ៍អំពីហេតុការណ៍ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៃ ម.ស.ម.ក។ ទិន្នន័យទាំងនេះ ត្រូវបានបំពេញបន្ថែមជាមួយគ្នានឹងទិន្នន័យដែលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជាបានកត់ត្រានៅពេលចាំបាច់។ របាយការណ៍នេះក៏បានបញ្ចូលផងដែរនូវករណីសិក្សាសំខាន់ៗ ស្តីពីការរំលោភលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលព័ត៌មានទាំងនេះត្រូវបានប្រមូលតាមរយៈប្រភពអ៊ីនធឺណិត។

បន្ថែមពីនេះ ក៏មានការសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដើម្បីប្រមូលនូវទស្សនៈយល់ឃើញរបស់ពួកគេលើស្ថានភាពបច្ចុប្បន្ននៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ព្រមទាំងបទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្តសិទ្ធិទាំងនេះ នៅពេលដែលអនុវត្តភារកិច្ចរបស់ខ្លួន។ នៅក្នុងបរិបទនៃរបាយការណ៍នេះ បុគ្គលិក ម.ស.ម.ក បានធ្វើការសម្ភាសអ្នកសារព័ត៌មានចំនួន ២២ នាក់ ក្នុងនោះមានស្ត្រី ៧ នាក់ ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស ២១ នាក់ ក្នុងនោះមានស្ត្រី ១០ នាក់។ សម្ភាស ត្រូវបានធ្វើឡើងទាំងដោយជួបផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។ ឈ្មោះរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងស្ថាប័នរបស់ពួកគេត្រូវបានរក្សាជាការសម្ងាត់។ ទោះយ៉ាងណាក្តី

សក្ខីកម្មដែលជាទស្សនៈ និងបទពិសោធន៍របស់ពួកគេដែលបានចែករំលែកជាគុណតម្លៃ ជាជាងការបង្ហាញអត្តសញ្ញាណ។

**ដែនកំណត់**

សូមបញ្ជាក់ផងដែរថា ទិន្នន័យប្រមូលបាន និងករណីដែលបានរាយការណ៍ទាំងឡាយគឺមិនទាន់គ្រប់ជ្រុងជ្រោយតំណាងឱ្យគ្រប់ករណីទាំងអស់ឡើយ ដោយហេតុថាករណីមួយចំនួននៃការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ឬសិទ្ធិទទួលព័ត៌មាន អាចនឹងមិនត្រូវបានរាយការណ៍។

# ខ្លឹមសារសង្ខេប

របាយការណ៍នេះពិនិត្យមើលទៅលើស្ថានភាពសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤។ សេរីភាពខាងការបញ្ចេញមតិ ដែលជាសសរស្តម្ភនៃសង្គមប្រជាធិបតេយ្យ គឺមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន។ សិទ្ធិអន្តរទំនាក់ទំនងទាំងនេះ គឺមានចែងទាំងនៅក្នុងច្បាប់អន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា។ ទោះបីជាមានច្បាប់ការពារនូវសិទ្ធិទាំងនេះ ហើយកម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗមួយចំនួនក្តី ការរឹតត្បិតទៅលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងពលរដ្ឋសាមញ្ញ ដែលអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាននៅតែបន្តកើតមាន។ ហេតុដូច្នេះ ការអនុវត្តជាក់ស្តែងនូវសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ជួបប្រទះនឹងឧបសគ្គគួរឱ្យគត់សម្គាល់ ដែលកើតចេញពីច្បាប់ដែលមានលក្ខណៈរឹតត្បិត ការគាបសង្កត់ពីសំណាក់រដ្ឋាភិបាល និងវប្បធម៌នៃការដាក់កំហិតខ្លួនឯងដែលបានចាក់ឫសយ៉ាងជ្រៅ។

ច្បាប់ជាតិបង្កឧបសគ្គជាច្រើនចំពោះការអនុវត្តសិទ្ធិជាមូលដ្ឋានឱ្យបានពេញលេញ។ ការតាក់តែងច្បាប់ជាញឹកញាប់មិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដោយធ្វើឱ្យលំហសេរីភាពខាងបញ្ចេញមតិបន្តធ្លាក់ចុះបន្ថែមទៀត។ ឧទាហរណ៍ នៅខែកញ្ញា ឆ្នាំ២០២៣ រដ្ឋាភិបាល បានអនុម័តអនុក្រឹត្យស្តីពីគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការព័ត៌មាន និងសាធារណមតិ ដោយបង្កើតនូវគណៈកម្មាធិការមួយដែលមានអំណាចយ៉ាងទូលំទូលាយក្នុងការតាមដានត្រួតពិនិត្យ និងធ្វើនិយ័តកម្មព័ត៌មានលើប្រព័ន្ធអ៊ីនធឺណិត ដែលនាំឱ្យមានក្តីបារម្ភអំពីការដាក់កំហិត និងការគាបសង្កត់កើនឡើងទៅលើការរិះគន់រដ្ឋាភិបាលក្រោមរូបភាពជាការប្រយុទ្ធប្រឆាំងនឹង "ព័ត៌មានក្លែងក្លាយ"។ លើសពីនេះទៅទៀត ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មា[1] ដែលនោះបង្ហាញអំពីការបោះជំហានឆ្ពោះទៅរកតម្លាភាពកាន់តែទូលំទូលាយយ៉ាងណាក្តី ច្បាប់នេះគឺចាំបាច់ត្រូវធ្វើវិសោធនកម្មដើម្បីធានាបាននូវការអនុលោមពេញលេញតាមបទដ្ឋានអន្តរជាតិ។ ទោះបីជាអង្គការសង្គមស៊ីវិលបានអំពាវនាវឱ្យមានការអនុម័តច្បាប់នេះឱ្យបានឆាប់រហ័សក្តី ក៏ការពន្យារពេលអនុម័តច្បាប់នេះនាំឱ្យមានក្តីព្រួយបារម្ភបន្ថែមទៀត។

ក្រៅពីការរឹតត្បិតផ្លូវច្បាប់ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវវិធីសាស្ត្រជាច្រើនដើម្បីគាបសង្កត់ទៅលើសេរីភាពខាងការបញ្ចេញមតិដែរ។ វិធីសាស្ត្រទាំងនេះ រួមមាន ការបំភិតបំភ័យ ការឃ្លាំមើល ការគំរាមកំហែង និងការឃាត់ខ្លួនតាមប្រព័ន្ធតុលាការ ដោយកំណត់មុខសញ្ញាលើបុគ្គលដែលបង្ហាញទស្សនៈរិះគន់។ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ទទួលរងគ្រោះក្នុងកម្រិតខុសៗគ្នាពីការរឹតត្បិតទាំងនេះ ដោយត្រូវប្រឈមមុខនឹងការធ្វើទុក្ខបុកម្នេញផ្លូវច្បាប់ និងបរិយាកាសអសុវត្ថិភាព។ អំឡុងពេលនៃការចងក្រងរបាយការណ៍នេះ បានបញ្ជាក់ជាភស្តុតាងអំពីករណីជាច្រើននៃការឃាត់ខ្លួនផ្លូវច្បាប់ទៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ និងបញ្ហាប្រឈមនៃការទទួលព័ត៌មាន។

[1] សម្រាប់ការវិភាគផ្លូវច្បាប់ពេញលេញអំពីសេចក្តីព្រាងច្បាប់ស្តីពី A2I សូមមើល ម.ស.ម.ក "ស្ថានភាពនៃ សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា៖ របាយការណ៍ប្រចាំឆ្នាំ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១" (*ម.ស.ម.ក* ខែមេសា ឆ្នាំ២០២២)។

របាយការណ៍នេះ បង្ហាញអំពីទិន្នន័យសំខាន់ៗដែលប្រមូលបានក្នុងអំឡុងពេលនៃរបាយការណ៍ ដោយគូសបញ្ជាក់អំពីបញ្ហាប្រឈមជាច្រើនទម្រង់ចំពោះសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ ទិន្នន័យបែបបរិមាណវិស័យនេះ គឺបំពេញបន្ថែមដោយសក្ខីកម្មពីអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលផ្តល់នូវបទពិសោធន៍ជាក់ស្តែងអំពីបញ្ហាលំបាក ដែលបានជួបប្រទះនៅក្នុងការបំពេញការងារស្របច្បាប់របស់ពួកគេ។

តាមរយៈការពិចារណាទៅលើរបកគំហើញទាំងនេះ របាយការណ៍នេះក៏ផ្តល់នូវអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដោយជំរុញឱ្យមានវិធានការម៉ឺងម៉ាត់ក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងបង្កើតនូវបរិយាកាសអំណោយផលដើម្បីការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា។

# សេចក្តីផ្តើម

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺជាសសរស្តម្ភនៃសង្គមលទ្ធិប្រជាធិបតេយ្យដែលជាយន្តការដ៏សំខាន់បំផុតមួយដើម្បីធានាការអនុវត្តអំណាចដោយការទទួលខុសត្រូវ និងលំហូរព័ត៌មានដោយសេរី។[2] ទោះបីជាសិទ្ធិនេះមានតួនាទីយ៉ាងសំខាន់ក្តី ក៏នៅទទួលរងការវាយប្រហារនៅទូទាំងសកលលោកនៅក្នុងរយៈពេល ១៧ ឆ្នាំចុងក្រោយនេះ។ ទិន្នន័យរបស់អង្គការហ្វ្រីដឹមហៅស៍បង្ហាញថានិន្នាការសេរីភាពខាងការបញ្ចេញមតិ ទាំងប្រព័ន្ធផ្សព្វផ្សាយ និងជាលក្ខណៈបុគ្គល បានធ្លាក់ចុះជាងសិទ្ធិសេរីភាពផ្សេងទៀតនៅក្នុងរយៈពេលចុងក្រោយនេះ។ លើសពីនេះ ការរំលោភបំពានលើសេរីភាពបញ្ចេញមតិ គឺជាកត្តាចម្បងមួយនៃការធ្លាក់ចុះលទ្ធិប្រជាធិបតេយ្យនៅទូទាំងសកលលោក។[3]

កម្ពុជាជាឧទាហរណ៍មួយ ដែលស បញ្ជាក់ឱ្យឃើញអំពីនិន្នាការជាសកលនៃការធ្លាក់ចុះសេរីភាពខាងការបញ្ចេញមតិនេះ។ កម្ពុជាបង្ហាញឱ្យឃើញអំពីលំនាំគួរឱ្យព្រួយបារម្ភនៃការរឹតត្បិតលើសេរីភាពបញ្ចេញមតិ និងការបំបិទសំឡេងផ្ទុយ ដែលជាការគាបសង្កត់កាន់តែខ្លាំងឡើងមុនការបោះឆ្នោតសកលកន្លងទៅនៅខែកក្កដាឆ្នាំ២០២៣។ ចាប់តាំងពីឆ្នាំ២០១៧ មក ស្ថានភាពសិទ្ធិមនុស្សបានបន្តធ្លាក់ចុះ ហើយសិទ្ធិពលរដ្ឋកាន់តែរួមតូច។ ការធ្លាក់ចុះនៃសិទ្ធិនេះ គឺដោយសារតែការដៅមុខសញ្ញារបស់រដ្ឋាភិបាលចំពោះបុគ្គល និងស្ថាប័នណា ដែលហ៊ានបញ្ចេញទស្សនៈ និងគំនិតផ្ទុយពីអ្នកមានអំណាច រួមទាំងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកការពារសិទ្ធិមនុស្ស។ របាយការណ៍ដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក ទើបចេញផ្សាយថ្មីៗនេះ អះអាងបន្ថែមអំពីនិន្នាការនេះ ដោយបង្ហាញថាសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជានៅតែរងនូវការគាបសង្កត់ជាញឹកញាប់។ អ្នកសារព័ត៌មានរងការរំខានជាញឹកញាប់ នៅពេលរាយការណ៍អំពីប្រធានបទដែលមានលក្ខណៈរសើប ដូចជាបញ្ហាដីធ្លី និងរងវិធានការផ្លូវច្បាប់ដោយសារការអនុវត្តសិទ្ធិជាមូលដ្ឋានក្នុងការបញ្ចេញមតិដោយសេរីរបស់ខ្លួន។[4] ទោះបីជារដ្ឋាភិបាលធានាថាច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នឹងអនុម័តនៅឆ្នាំ២០២៥ ក៏ដោយ ក៏សិទ្ធិទទួលព័ត៌មាននេះមិនទាន់សម្រេចបាននៅឡើយ។ ការទទួលព័ត៌មានពីស្ថាប័នសាធារណៈនៅតែជាបញ្ហាប្រឈមក្នុងប្រទេសមួយដែលមានភាពស្រពេចស្រពិលក្នុងការគ្រប់គ្រងនិងគណនេយ្យភាពតិតតួចរបស់ស្ថាប័នរដ្ឋាភិបាល។

ផលប៉ះពាល់នៃការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ គឺឆ្លុះបញ្ចាំងក្នុងចំណាត់ថ្នាក់គួរឱ្យព្រួយបារម្ភរបស់កម្ពុជាលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤។ កម្ពុជាធ្លាក់ចំណាត់ថ្នាក់បួនលេខ ដោយឈរនៅលេខរៀង ទី១៥១ ក្នុងចំណោម ១៨០ ប្រទេសដែលត្រូវបានវាយតម្លៃដោយអង្គការអ្នករាយការណ៍គ្មានព្រំដែនដោយបញ្ជាក់ឱ្យឃើញអំពីការធ្លាក់ចុះជាបន្តបន្ទាប់លើសេរីភាពសារព័ត៌មាន និង

---

[2] សូមមើល គ.ស.ម.អ.ស.ប្រ "ទស្សនៈយល់ឃើញអំពី Rafael Marques ធៀបនឹង Angola" (ឯកសារអង្គការសហប្រជាជាតិ CCPR/C/83/D/1128/2002 ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៥) កថាខណ្ឌ ៦.៨។

[3] អង្គការហ្វ្រីដឹមហៅស៍ "សេរីភាពនៅក្នុងពិភពលោក ឆ្នាំ២០២៣៖ រយៈពេល ៥០ ឆ្នាំនៃការតស៊ូដើម្បីប្រជាធិបតេយ្យ" (*អង្គការហ្វ្រីដឹមហៅស៍* ឆ្នាំ២០២៣)។

[4] ម.ស.ម.ក "របាយការណ៍ឆ្នាំ២០២២ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា៖ (*ម.ស.ម.ក* ខែកញ្ញា ឆ្នាំ២០២៣) ទំព័រ ២៥ និង២៦។

បរិយាកាសប្រឈមដែលអ្នកសារព័ត៌មានជួបប្រទះ។[5]ស្រដៀងគ្នានេះដែរ របាយការណ៍ស្តីពីសេរីភាពនៅក្នុងពិភពលោក ឆ្នាំ២០២៤ របស់អង្គការហ្វ្រីដឹមហៅស៍[6] បានចាត់ថ្នាក់ប្រទេសកម្ពុជាថា «មិនមានសេរីភាព» ដោយបានពិន្ទុសេរីភាពជាសកលចំនួន ២៤ ក្នុងចំណោម ១០០ ពិន្ទុ ហើយក្នុងរបាយការណ៍ស្តីពីសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិត ឆ្នាំ២០២៤ របស់អង្គការនេះដដែល[7] ក៏បានចាត់ថ្នាក់កម្ពុជាថាជាប្រទេសមាន «សេរីភាពខ្លះ» ដោយបានពិន្ទុសេរីភាពតាមអនឡាញចំនួន ៤៣ លើ ១០០ ពន្ទុ។ ជាចុងក្រោយ សន្ទស្សន៍ប្រជាធិបតេយ្យ ឆ្នាំ២០២៣ របស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី ១២៩ នៃ ១៦៧ ប្រទេសដែលត្រូវបានវាយតម្លៃ ដោយចាត់ថ្នាក់ថាជា «ប្រទេសមានរបបផ្តាច់ការ»។[8] ការបន្តធ្លាក់ចុះចំណាត់ថ្នាក់នេះ គូសបញ្ជាក់ឱ្យឃើញអំពីការធ្លាក់ចុះនៃសេរីភាពប្រជាធិបតេយ្យ និងបរិយាកាសនៃរឹតត្បិតកើនឡើងសម្រាប់សេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេស។

របាយការណ៍នេះ ពិនិត្យទៅលើស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ដោយចងក្រងអំពីបញ្ហាប្រឈម និងការរឹតត្បិតដែលបន្តកើតមានឡើងលើបុគ្គលដែលអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ តាមរយៈការវិភាគទៅលើក្របខណ្ឌច្បាប់ ទិន្នន័យតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការសម្ភាសអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស របាយការណ៍នេះបញ្ជាក់ឱ្យឃើញអំពីនិន្នាការគួរឱ្យព្រួយបារម្ភនៃការដាក់កំហិត ការបំភិតបំភ័យ និងការដាក់កំហិតខ្លួនឯង នៅតែជាបញ្ហាសម្រាប់ប្រទេសកម្ពុជានៅឡើយ។ របកគំហើញដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គូសបញ្ជាក់អំពីតម្រូវការបន្ទាន់ដែលរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែចាត់វិធានការឱ្យបានម៉ឺងម៉ាត់ដើម្បីការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ ដោយធានាធ្វើយ៉ាងណាឱ្យពលរដ្ឋទាំងអស់អាចបញ្ចេញទស្សនៈយល់ឃើញរបស់ខ្លួនបានដោយសេរី និងដោយមិនមានការភ័យខ្លាចពីការតបត។

---

[5]សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនវាយតម្លៃស្ថានភាពអ្នកសារព័ត៌មានជារៀងរាល់ឆ្នាំនៅក្នុងប្រទេស និងដែនដីជាងមួយរយ ដោយផ្តល់ពិន្ទុ និងចាត់ថ្នាក់ប្រទេស និងដែនដីទាំងនោះផ្សេងៗគ្នា ទៅតាមពិន្ទុក្នុងចំណោមពិន្ទុ ១០០។ សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២៤ ចាត់ថ្នាក់ស្ថានភាពសេរីភាពសារព័ត៌មានរបស់ប្រទេសដែលបានវាយតម្លៃជាប្រាំប្រភេទ៖ ល្អ ពេញចិត្ត មានបញ្ហាពិបាក និងធ្ងន់ធ្ងរ។ សូមមើលសន្ទស្សន៍សេរីភាពសារព័ត៌មាន ពិភពលោកឆ្នាំ ២០២៤ សម្រាប់ព័ត៌មានលម្អិតអំពីប្រទេសកម្ពុជា។

[6] របាយការណ៍ស្តីពីសេរីភាពពិភពលោកចេញផ្សាយដោយហ្វ្រីដឹមហៅស៍ វាយតម្លៃលើសេរីភាពសកលនៃបណ្តាប្រទេស និងដែនដីជុំវិញពិភពលោក ដោយផ្តល់ពិន្ទុ និងចាត់ថ្នាក់ប្រទេស និងដែនដីទាំងនោះជាបីថ្នាក់ផ្សេងៗគ្នា ទៅតាមពិន្ទុក្នុងចំណោមពិន្ទុ ១០០ ដូចជា៖ ប្រទេសសេរី សេរីខ្លះ ឬប្រទេសមិនមានសេរីភាព។ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ស្តីពីសេរីភាពឆ្នាំ២០២៤ របស់កម្ពុជានៅក្នុងរបាយការណ៍ប្រទេសក្នុងពិភពលោក ។

[7] របាយការណ៍ស្តីពីសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិត គឺជាការស្ទង់មតិ និងការវិភាគប្រចាំឆ្នាំ អំពីសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតជុំវិញពិភពលោក ធ្វើឡើងដោយអង្គការហ្វ្រីដឹមហៅស៍។ របាយការណ៍នេះផ្តល់ពិន្ទុដល់ប្រទេសដែលត្រូវបានវាយតម្លៃ ក្នុងចំណោមពិន្ទុ ១០០ ហើយចាត់ថ្នាក់ជាបីប្រភេទទៅតាមពិន្ទុ៖ មានសេរីភាព មានសេរីភាពខ្លះ ឬមិនមានសេរីភាព។ សម្រាប់ព័ត៌មានលម្អិត សូមមើល របាយការណ៍ ប្រចាំប្រទេស របស់កម្ពុជាឆ្នាំ ២០២៤ ស្តីពីសេរីភាពនៅលើពិភពលោក។

[8] សន្ទស្សន៍ប្រជាធិបតេយ្យចេញផ្សាយដោយអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច គឺជារបាយការណ៍ប្រចាំឆ្នាំមួយដែលវាយតម្លៃលើស្ថានភាពប្រជាធិបតេយ្យនៅទូទាំងពិភពលោក។ សន្ទស្សន៍នេះផ្តល់នូវទិដ្ឋភាពទូទៅអំពីស្ថានភាពប្រជាធិបតេយ្យនៅក្នុងរដ្ឋឯករាជ្យ ១៦៧ និងដែនដីចំនួនពីរ ដោយគ្របដណ្តប់លើប្រជាជនពិភពលោកទាំងមូល។ សម្រាប់ព័ត៌មានបន្ថែម សូមមើល របាយការណ៍ ឆ្នាំ២០២៣។



| សេរីភាពពិភពលោក ឆ្នាំ២០២៤ | សេរីភាពតាមប្រព័ន្ធអ៊ីនធឺណិត ឆ្នាំ២០២៤ | សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ | សន្ទស្សន៍ប្រជាធិបតេយ្យ ឆ្នាំ២០២៣ |
| --- | --- | --- | --- |
| *ពិន្ទុសេរីភាពពិភពលោក៖* | *ពិន្ទុសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិត៖* | *ពិន្ទុសេរីភាពសារព័ត៌មានពិភពលោក៖* | *ពិន្ទុប្រជាធិបតេយ្យ៖* |
| ២៤/១០០ | ៤៣/១០០ | ៤២,០២/១០០ | ៣,០៥/១០ |
| មិនមានសេរីភាព | មានសេរីភាពខ្លះ | ស្ថានភាពលំបាក | របបផ្តាច់ការ |

## I. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលរួមបញ្ចូលទាំងសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន គឺជាមូលដ្ឋានគ្រឹះនៃសង្គមដែលប្រកបដោយយុត្តិធម៌ និងប្រជាធិបតេយ្យ។ សិទ្ធិដែលអន្តរទំនាក់ទំនងគ្នាទាំងនេះពង្រឹងសិទ្ធិអំណាចរបស់បុគ្គលដើម្បីឱ្យអ្នកមានអំណាចមានការទទួលខុសត្រូវ តតាំងទៅនឹងបទដ្ឋានដែលគ្រោះថ្នាក់ និងបណ្តុះនូវបរិយាកាសមួយដែលសាធារណជនទទួលមានព័ត៌មានគ្រប់គ្រាន់។ ទោះបីជាបច្ចេកវិទ្យាឌីជីថលជួយពង្រីកសេរីភាពទាំងនេះឱ្យកាន់តែទូលំទូលាយក្តី ជាមួយគ្នានេះដែរបច្ចេកវិទ្យាប្រែក្លាយជាមធ្យោបាយរបស់រដ្ឋាភិបាលក្នុងការបង្ក្រាបដល់សេរីភាពទាំងនេះក្នុងវិសាលភាពមួយដែលមិនធ្លាប់មានពីមុនមក។

### សេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិគ្របដណ្តប់គ្រប់ទម្រង់ទាំងអស់រួមទាំង ការបញ្ចេញមតិដោយការនិយាយ សំណេរ និងឌីជីថល ដែលរួមបញ្ចូលមធ្យោបាយផ្សេងទៀត ដូចជា សៀវភៅ ការបង្ហោះមាតិកាលើប្រព័ន្ធអ៊ីនធឺណិត និងសោតទស្សន៍-ចក្ខុទស្សន៍ ជាដើម។ សេរីភាពនេះក៏ការពារសិទ្ធិក្នុងការចូលរួមការពិភាក្សានានា រួមទាំងសកម្មភាពនយោបាយ ការតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងសារព័ត៌មាន។[9] សេរីភាពខាងការបញ្ចេញមតិមានសារសំខាន់សម្រាប់ដំណើរការលទ្ធិប្រជាធិបតេយ្យ ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋចូលរួមបានពេញលេញ និងឱ្យអ្នកដែលកាន់អំណាចទទួលខុសត្រូវ។ សេរីភាពនេះ ការពារសិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិសេរីភាពខាងគំនិត សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងសមាគម។ ប្រសិនបើគ្មានសិទ្ធិនេះទេ តម្លាភាព និងគណនេយ្យភាពក៏មិនអាចកើតមានទៀតបានដែរ។[10]

### សេរីភាពសារព័ត៌មាន

សារព័ត៌មានដែលសេរី គឺសំខាន់អនុញ្ញាតឱ្យមានការផ្សព្វផ្សាយចំណេះដឹងជាសាធារណៈ និងការអនុវត្តសិទ្ធិប្រជាធិបតេយ្យ ដែលធ្វើឱ្យពលរដ្ឋបង្កើតជាមតិយោបល់ ចូលរួមនៅក្នុងការពិភាក្សាដេញដោលមតិ និងឱ្យអាជ្ញាធរទទួលខុសត្រូវ។[11] សេរីភាពខាងការបញ្ចេញមតិ គឺសំខាន់ណាស់សម្រាប់ការលូតលាស់នៃលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលពង្រឹងដោយវិស័យសារព័ត៌មានស៊ើបអង្កេត ផ្តល់ឱ្យពលរដ្ឋនូវព័ត៌មានដែលអាចទុកចិត្តបាន ដែលជួយឱ្យពួកគេចូលរួមផ្សព្វផ្សាយព័ត៌មានសាធារណៈ និងតស៊ូមតិឱ្យមានការផ្លាស់ប្តូរ។ សេរីភាពនេះធានានូវតម្លាភាព លាតត្រដាងអំពីកំហុសនានា និងដើរតួនាទីជាការត្រួតពិនិត្យ

[9]គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣៤ – មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញមតិ និងសម្តែងមតិ" (ឯកសារអង្គការសហប្រជាជាតិ CCPR/C/GC/34 ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១១) កថាខណ្ឌ ២ (គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣៤។

[10]*ដូចខាងលើ* កថាខណ្ឌ ១១ និងកថាខណ្ឌ ១២។

[11]ក្រសួងការបរទេសន័រវេស "កិច្ចខិតខំប្រឹងប្រែងអន្តរជាតិដើម្បីលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ" (*ក្រសួងការបរទេស* ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០)។

សំខាន់ទៅលើអំណាចរបស់រដ្ឋាភិបាល។[12] សេរីភាពសារព័ត៌មាន គឺមានសារៈសំខាន់ណាស់ដើម្បីធានាឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ និងទប់ស្កាត់អំពើពុករលួយ ភាពអយុត្តិធម៌ និងការបំពាន។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនមានការរឹតត្បិត ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពិនិត្យលើអំណាច ដោយធានាបាននូវលំហូរព័ត៌មាន និងគំនិតសេរី។

## សិទ្ធិទទួលព័ត៌មាន

ពលរដ្ឋមានសិទ្ធិស្វែងរក និងទទួលព័ត៌មានសាធារណៈ។[13] សិទ្ធិទទួលព័ត៌មានក៏ធានាថា ប្រព័ន្ធផ្សព្វផ្សាយមានសិទ្ធិទទួលព័ត៌មានចំពោះកិច្ចការសាធារណៈ ឬកិច្ចការដែលមានសារៈសំខាន់ជាសាធារណៈ។[14] សិទ្ធិទទួលព័ត៌មានជានានូវតម្លាភាពនៃស្ថាប័នរដ្ឋាភិបាល សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងបង្កើនកិច្ចសន្ទនា និងការជឿទុកចិត្តរវាងរដ្ឋាភិបាល និងសង្គម។[15] សិទ្ធិនេះមានសារៈសំខាន់ណាស់សម្រាប់តម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ដោយអនុញ្ញាតឱ្យពលរដ្ឋចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តជាលក្ខណៈប្រជាធិបតេយ្យ។ ប្រសិនបើគ្មានសិទ្ធិនេះទេ រដ្ឋាភិបាលនឹងធ្វើប្រតិបត្តិការដោយសម្ងាត់ រួចផុតពីការពិនិត្យពិច័យ ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ។

---

[12]អង្គការសហប្រជាជាតិ "សេរីភាពសារព័ត៌មានមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ខណៈដែលអង្គការសហប្រជាជាតិថ្កោលទោសឃាតកម្មបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយចំនួន ៥៩ នាក់" (*សារព័ត៌មានអង្គការសហប្រជាជាតិ* ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០)។

[13]ហ្វ្រេង ឡា រុយ (Frank La Rue), "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសម្ដែងមតិ" (UN Doc A/68/362៤ ខែកញ្ញា ឆ្នាំ២០១៣) កថាខណ្ឌទី ២ ។

[14]គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌ ១៨។

[15]អេនឌ្រូ អេចក្លេស្ទោន (Andrew Ecclestone), "សំណើយុទ្ធសាស្ត្រដើម្បីសេរីភាពព័ត៌មាននៅកម្ពុជា" (ខែកញ្ញា ឆ្នាំ២០០៨)។

## II. ក្របខណ្ឌច្បាប់ស្តីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

លិខិតូបករណ៍អន្តរជាតិជាច្រើនដែលកម្ពុជាបានផ្តល់សច្ចាប័ន ធានានូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងជាតុផ្សំចំនួនពីរសំខាន់ៗនៃសិទ្ធិនេះ។ ខណៈដែលសេរីភាពខាងការបញ្ចេញមតិ គឺជាមូលដ្ឋានគន្លឹះនៃសង្គមសេរី និងប្រជាធិបតេយ្យ[16] ក៏ដោយ ក៏សិទ្ធិនេះមិនមានលក្ខណៈដាច់ខាតនោះទេ ហើយអាចត្រូវបានដាក់កម្រិតនៅក្នុងកាលៈទេសៈចង្អៀតមួយចំនួនដែលកំណត់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ក្របខណ្ឌច្បាប់សម្រាប់សេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន រួមបញ្ចូលទាំងច្បាប់អន្តរជាតិ និងច្បាប់ជាតិ។ នៅកម្រិតអន្តរជាតិ លិខិតូបករណ៍ ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស( ស.ស.ស .ម ) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន" ) អះអាងអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ស្របពេលដែលអនុញ្ញាតឱ្យមានការរឹតត្បិតដាក់លាក់ និងស្របច្បាប់ ដែលចាំបាច់ត្រូវតែអនុវត្តស្របតាមច្បាប់ ដោយមានគោលបំណងការពារសិទ្ធិរបស់អ្នកដទៃ និងត្រូវមានភាពចាំបាច់ និងស្មើភាព។ នៅកម្ពុជា រដ្ឋធម្មនុញ្ញ ធានាថា សិទ្ធិទាំងនេះ និងច្បាប់នានា ដូចជា ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ អះអាងអំពីសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានដែលកាន់កាប់ដោយរដ្ឋាភិបាល។ ទោះជាយ៉ាងនេះក្តី ច្បាប់ជាតិជាច្រើនបានដាក់ចេញនូវវិធានការរឹតត្បិត ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទាំងនេះ រួមមាន ការកំណត់និយមន័យមិនច្បាស់លាស់ ដែលនាំឱ្យមានការដាក់កំហិត ការឃ្លាំមើល និងការដាក់ទោសសកម្មជនគណបក្សជំទាស់។ ការអាស្រ័យគ្នាទៅវិញទៅមកនៃក្របខណ្ឌទាំងនេះ គូសបញ្ជាក់ឱ្យឃើញអំពីបញ្ហាប្រឈមជាបន្តបន្ទាប់នៅក្នុងការធានាឱ្យបាននូវសេរីភាពខាងការបញ្ចេញមតិពិតប្រាកដ។ សម្រាប់ការស្វែងយល់លម្អិតអំពីបញ្ហាទាំងនេះ រួមទាំងក្របខណ្ឌជាតិ និងអន្តរជាតិ សូមមើលរបាយការណ៍មុនៗ។[17]

---

[16] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌ ១។

[17] សម្រាប់ការវិភាគពេញលេញនៃក្របខណ្ឌជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន សូមមើលរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និង សិទ្ធិទទួលព័ត៌មាននៅកម្ពុជារបស់ ម.ស.ម.ក។ (ខែវិច្ឆិកា ឆ្នាំ ២០២៣) ទំព័រ ៨-១០។

## III. ការវិភាគផ្នែកច្បាប់នៅលើការវិវត្តនៃច្បាប់ថ្មីៗបំផុត

### បច្ចុប្បន្នភាពអំពីអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

អនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានអនុម័តនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១។[18] អនុក្រឹត្យនេះបង្កើតនូវច្រកទ្វារអ៊ីនធឺណិតជាតិ ដែលតម្រូវឱ្យរាល់ការទំនាក់ទំនង និងទិន្នន័យអ៊ីនធឺណិតទាំងក្នុងស្រុក និងក្រៅស្រុក ត្រូវឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតជាតិជាមុនសិន មុនពេលបញ្ជូនទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ។ អង្គការសង្គមស៊ីវិលបានជំទាស់នឹងសេចក្ដីស្នើអនុក្រឹត្យនេះ ព្រោះអនុក្រឹត្យនេះមានការគំរាមកំហែងដល់ការអនុវត្តសេរីភាពមូលដ្ឋានតាមអ៊ីនធឺណិត រួមទាំង សេរីភាពខាងការបញ្ចេញមតិផងដែរ។[19] អនុក្រឹត្យដែលគ្រោងដាក់ឱ្យអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ត្រូវបានពន្យារពេលដោយសារ «បញ្ហាបច្ចេកទេស» នេះបើយោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ)។[20] គិតត្រឹមដើមខែតុលា ឆ្នាំ២០២៤ ច្រកទ្វារអ៊ីនធឺណិតជាតិនៅមិនទាន់ចូលជាធរមាននៅឡើយនោះទេ។

### ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ឆ្នាំ២០២៣

នៅឆ្នាំ២០២៣ រដ្ឋសភាបានអនុម័តលើវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីការបោះឆ្នោតឃុំសង្កាត់ ដើម្បីដាក់ទោសដល់អ្នកញុះញង់ដល់អ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងណែនាំ/ញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោតនោះជាអំពើល្មើសច្បាប់។ ការរឹតត្បិតទាំងនេះ នាំឱ្យមានការរឹតត្បិតដែលមិនអនុញ្ញាតទៅលើសិទ្ធិសេរីភាពខាងបញ្ចេញមតិនៅក្រោមមាត្រា ១៩(៣) នៃ ក.អ.ស.ព.ន ។ តាមរយៈការដាក់ទោសសកម្មភាពដែលញុះញង់ឱ្យអ្នកមានសិទ្ធិបោះឆ្នោតធ្វើពហិការបោះឆ្នោត ឬបំផ្លាញសន្លឹកឆ្នោត ច្បាប់នេះបង្កនូវបរិយាកាសភ័យខ្លាចក្នុងការចូលរួមនយោបាយ និងការចូលរួមពីសាធារណជន។ បញ្ញត្តិទាំងនេះមិនត្រឹមតែរារាំងទៅលើការបញ្ចេញមតិជំទាស់ប៉ុណ្ណោះទេ តែថែមទាំងដាក់កំហិតទៅលើសមត្ថភាពរបស់ពលរដ្ឋក្នុងការចូលរួមពិភាក្សា និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត។ ការរឹតត្បិតនេះផ្ទុយទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលសង្កត់ទៅលើសារៈសំខាន់នៃកិច្ចសន្ទនាបើកចំហ និងការផ្លាស់ប្ដូរគំនិតទៅវិញទៅមកដោយសេរីក្នុងអំឡុងពេលបោះឆ្នោត ដែលធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ប្រជាធិបតេយ្យ ដែលជាមូលដ្ឋានគ្រឹះនៃប្រសិទ្ធភាពអភិបាលកិច្ច។

### ប្រកាសស្ដីពីការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន ឆ្នាំ២០២៤

នៅខែកក្កដា ឆ្នាំ២០២៤ ក្រសួងព័ត៌មានកម្ពុជាបានបង្ហាញអំពីសេចក្ដីព្រាងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានកម្ពុជា នៅក្នុងសន្និសីទមួយនៅរាជធានីភ្នំពេញ។ ក្រោយមក នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ ក្រសួង

---

[18] សម្រាប់ការវិភាគពេញលេញលើផលប៉ះពាល់នៃអនុក្រឹត្យលើសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការបញ្ចេញមតិ សូមមើល"របាយការណ៍ប្រចាំឆ្នាំលើកទីប្រាំមួយស្ដីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" របស់មជ្ឈមណ្ឌលសាមគ្គីភាព និងសមាគមអាដហុករបស់ ម.ស.ម.ក (មេសា ២០២២) ទំព័រ ៧-៩។

[19] ម.ស.ម.ក និងស្ថាប័នផ្សេងទៀត"សេចក្ដីថ្លែងការណ៍រួម៖ ប្រានចោលអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលប៉ះពាល់ដល់សិទ្ធិមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា" (១៨ កុម្ភៈ ២០២១)។

[20] សេង ថៃ "រដ្ឋាភិបាលព្យួរច្រកទ្វារអ៊ីនធឺណិតដែលមានភាពចម្រូងចម្រាសជាបណ្ដោះអាសន្ន" (*វីអូឌី* ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២)។

ព័ត៌មានបានចេញសេចក្តីប្រកាសស្តីពីការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។[21] បើយោងតាមរាជរដ្ឋាភិបាលកម្ពុជា ធម្មនុញ្ញនេះត្រូវបានបង្កើតឡើងបន្ទាប់ពីមានការពិគ្រោះយោបល់ និងវាយតម្លៃគ្រប់ជ្រុងជ្រោយជាមួយភាគីពាក់ព័ន្ធនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ។[22]ទោះជាយ៉ាងណាក៏ដោយ ធម្មនុញ្ញនេះបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងវិសាលភាពមួយដែលមានកម្រិតប៉ុណ្ណោះ។ ក្រុមភាគីពាក់ព័ន្ធដែលបានជ្រើសរើសក្នុងការចូលរួមមានរយៈពេលត្រឹមប្រាំបួនថ្ងៃ ដើម្បីផ្តល់មតិចូលរួមទៅលើសេចក្តីព្រាងនេះ ហើយសំណៅស្ថាពរត្រូវបានអនុម័តនៅក្នុងរយៈពេលត្រឹមបួនថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ជូនមតិយោបល់ ដែលមិនមានការពិភាក្សាសម្រេចបន្ថែមទៀតទៅលើធាតុចូលដែលទទួលបាននោះឡើយ។[23]

ទោះបីជាធម្មនុញ្ញនេះសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃសុក្រឹតភាពរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ក៏បញ្ញត្តិនៃធម្មនុញ្ញនេះផ្តោតជាចម្បងទៅលើការផ្សព្វផ្សាយព័ត៌មានពិតដែលអាចផ្ទៀងផ្ទាត់បាន និងការបង្ក្រាបព័ត៌មានក្លែងក្លាយ ជាជាងគូសបញ្ជាក់អំពីវិធានការបុរេសកម្មសម្រាប់ការផ្ទៀងផ្ទាត់ព័ត៌មានមុនពេលចុះផ្សាយ។ ប្រកាសនេះក៏បង្ហាញឱ្យឃើញអំពីភាពស្រពេចស្រពិលពាក់ព័ន្ធនឹងវិសាលភាព និងយន្តការអនុវត្ត។ ខណៈដែលមាត្រា ២ បញ្ជាក់អំពីការអនុវត្តនៃធម្មនុញ្ញនេះទៅលើបុគ្គលគ្រប់រូបដែលចូលរួមនៅក្នុងការផ្សព្វផ្សាយព័ត៌មាននៅក្នុងប្រទេសកម្ពុជា និងចាត់ទុកធម្មនុញ្ញនេះថាជាមូលដ្ឋានគ្រឹះសម្រាប់សារព័ត៌មានដែលមានក្រមសីលធម៌ក្តី ការអនុវត្តជាក់ស្តែងគឺនៅតែមានភាពស្រពេចស្រពិលនៅឡើយ។ មាត្រា ២ នៃធម្មនុញ្ញនេះពង្រីកបន្ថែមទៅលើវិសាលភាពនេះ ដោយបញ្ជាក់អំពីការអនុវត្តទៅលើតួអង្គជាច្រើន។ ទោះបីជាមានការអះអាងទាំងនេះក្តី ធម្មនុញ្ញនេះនៅខ្វះភាពច្បាស់លាស់ទៅលើនីតិវិធីអនុវត្ត។ មាត្រា ៣ លើកឡើងមិនច្បាស់លាស់អំពីការបង្កើត "គណៈកម្មាធិការ" មួយដើម្បីវាយតម្លៃ និងទទួលស្គាល់ការអនុវត្តតាមធម្មនុញ្ញនេះ ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងសមាសភាព ដំណើរការតែងតាំង ឬបែបបទប្រតិបត្តិការរបស់គណៈកម្មាធិការនេះឡើយ។

ដូចគ្នានេះដែរ ប្រកាសនេះបង្ហាញអំពីភាពស្រពេចស្រពិលពាក់ព័ន្ធនឹងការអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ មាត្រា ៤ ធ្វើការកំណត់មិនច្បាស់លាស់ទៅលើតួអង្គជាច្រើន ដែលរួមបញ្ចូលអង្គភាពមួយចំនួននៅក្នុងក្រសួងព័ត៌មាន ព្រមទាំងវិស័យព័ត៌មាន និងការផ្សព្វផ្សាយ ឱ្យទទួលខុសត្រូវក្នុងការអនុវត្តប្រកាសនេះ ដោយសន្មត់បានថារួមបញ្ចូលទាំងធម្មនុញ្ញដែលជាឧបសម្ព័ន្ធ។ កង្វះភាពច្បាស់លាស់នេះ នាំឱ្យមានការព្រួយបារម្ភអំពីលទ្ធភាពនៃការអនុវត្តតាមអំពើចិត្ត ឬទៅលើក្រុមជាក់លាក់។ លើសពីនេះ ធម្មនុញ្ញនេះក៏បញ្ជាក់អំពីអត្ថប្រយោជន៍ និងទំនួលខុសត្រូវមួយចំនួនសម្រាប់អ្នកសារព័ត៌មាន និងបណ្តាញផ្សព្វផ្សាយ ដូចជាបញ្ញត្តិសម្រាប់សុខភាព សង្គម និងការការពារផ្លូវច្បាប់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា (មាត្រា ២៤) ការស្នើសុំ

---

[21]ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ សំណៅក្រៅផ្លូវការ ៦ សីហា ២០២៤។

[22]បែន សុខហ៊ាន ខ្មែរថាមស៍ ២០២៤ សីហា ៧ 'ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន' ក្រសួងព័ត៌មានបង្កើត"
https://www.khmertimeskh.com/501536505/information-ministry-establishes-charter-forprofessional-journalism

[23]ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ កម្ពុជា៖ ជំនាញការអង្គការសហប្រជាជាតិអំពាវនាវឱ្យមានការផ្អាកធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤។
https://www.ohchr.org/en/press-releases/2024/09/cambodia-un-experts-call-suspension-professional-journalism-charter

បណ្ណសម្គាល់ខ្លួនសារព័ត៌មានពីក្រសួងព័ត៌មាន ( មាត្រា ២៥ ) ព្រមទាំងសិទ្ធិ និងភារកិច្ចពាក់ព័ន្ធ ( មាត្រា ២៦ ) ។ ទោះជាយ៉ាងនេះក្តី ប្រកាសនេះមិនបានបញ្ជាក់អំពីរបៀបអនុវត្ត ឬតាមដានត្រួតពិនិត្យបញ្ញត្តិទាំងនេះឡើយ ដោយនាំឱ្យមានភាពស្រពិចស្រពិលបន្ថែមទៀតពាក់ព័ន្ធនឹងការអនុវត្ត។ កង្វះភាពមិនច្បាស់លាស់នេះ អាចបង្កើតឱ្យមានបរិយាកាសមួយដែលអំណោយផលដល់ការអនុវត្តតាមអំពើចិត្តនៃធម្មនុញ្ញនេះ ដែលអាចធ្វើឱ្យមានការរំលោភលើសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន។

ការខកខានដ៏សំខាន់មួយនៅក្នុងប្រកាសនេះ គឺជាកង្វះការបញ្ជាក់ជាពាក្យពេចន៍ពាក់ព័ន្ធនឹងការដាក់ទោសទណ្ឌដែលអនុវត្តចំពោះតួអង្គដែលបំពានបញ្ញត្តិនៃធម្មនុញ្ញនេះ។ កង្វះភាពច្បាស់លាស់ពាក់ព័ន្ធនឹងវិធានការវិន័យនេះ ធ្វើឱ្យប៉ះពាល់ដល់ភាពស្របច្បាប់ និងលទ្ធភាពអនុវត្តនៃក្រមវិជ្ជាជីវៈប្រព័ន្ធផ្សព្វផ្សាយ។ ការបញ្ចប់សេចក្តីព្រាងវិធានសំខាន់ៗនៃធម្មនុញ្ញនេះមិនឆ្លើយតបនឹងក្របខណ្ឌគណនេយ្យភាពដែលនាំឱ្យមានការព្រួយបារម្ភអំពីការអនុវត្តជាក់ស្តែង និងលទ្ធភាពនៃការអនុវត្តតាមអំពើចិត្ត។ ការដែលមិនមានការកំណត់ច្បាស់លាស់អំពីផលវិបាកនៃការបំពានលើក្រមនេះ អាចនាំឱ្យមានការអនុវត្តមិនច្បាស់លាស់ និងមិនមានសង្គតិភាព ដែលអាចរារាំងដល់ប្រសិទ្ធភាពនៅក្នុងការលើកកម្ពស់សារព័ត៌មានប្រកបដោយក្រមសីលធម៌ និងការការពារសេរីភាពខាងការបញ្ចេញមតិ។

ទោះបីជាប្រកាសនេះបានគូសបញ្ជាក់លើកកម្ពស់សារព័ត៌មានប្រកបដោយក្រមសីលធម៌ក្តី ក៏ប្រកាសនេះនៅមានបញ្ញត្តិដែលធ្វើឱ្យមានការព្រួយបារម្ភអំពីលទ្ធភាពក្នុងការដាក់កំហិតទៅលើសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជាផងដែរ។ ការកំណត់និយមន័យទូលាយនៃពាក្យថា "អ្នកអនុវត្តនៅក្នុងវិស័យព័ត៌មាន និងផ្សព្វផ្សាយ"ដោយរួមបញ្ចូលអ្នកផ្សព្វផ្សាយព័ត៌មានមិនមែនវិជ្ជាជីវៈដូចជា អ្នកបង្កើតមាតិកា និងអ្នកប្រើប្រាស់បណ្តាញសង្គម ដែលអាចធ្វើឱ្យបុគ្គលជាច្រើនប្រឈមនឹងការរឹតត្បិត និងបទប្បញ្ញត្តិដែលអនុវត្តលើអ្នកសារព័ត៌មានវិជ្ជាជីវៈ ដែលអាចជាការដាក់កំហិតទៅលើសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ។ ការសង្កត់ទៅលើការប្រយុទ្ធប្រឆាំង "ព័ត៌មានក្លែងក្លាយ" និងការផ្សព្វផ្សាយព័ត៌មានមិនពិត ដោយមិនមានការកំណត់និយមន័យ និងការការពារច្បាស់លាស់ អាចប្រើប្រាស់ដើម្បីបំបិទសំឡេងរិះគន់ និងបង្ក្រាបសំឡេងជំទាស់។ លើសពីនេះទៅទៀត ធម្មនុញ្ញនេះហាមឃាត់មាតិកាដែល "ប៉ះពាល់ដល់វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ជាតិ" ដែលអាចបកស្រាយបានយ៉ាងទូលំទូលាយ ក្នុងការដាក់កំហិតមាតិកាលើប្រព័ន្ធអ៊ីនធឺណិតដែលរិះគន់ដល់រដ្ឋាភិបាល ឬបង្ហាញអំពីទស្សនៈយល់ឃើញផ្ទុយពីរដ្ឋាភិបាល។ កង្វះភាពច្បាស់លាស់ពាក់ព័ន្ធនឹងអាណត្តិរបស់គណៈកម្មាធិការដែលបង្កើតឡើងដើម្បីវាយតម្លៃការអនុវត្តតាមធម្មនុញ្ញ និងការដែលមិនមានយន្តការត្រួតពិនិត្យឯករាជ្យ នាំឱ្យមានការព្រួយបារម្ភបន្ថែមទៀតអំពីការអនុវត្តតាមអំពើចិត្ត និងលទ្ធភាពនៃការរំលោភបំពាន ដែលធ្វើឱ្យមានការគំរាមកំហែងយ៉ាងខ្លាំងចំពោះសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា។

## IV. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាព សារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន នៅតែបន្តរងការវាយប្រហារនៅក្នុងប្រទេសកម្ពុជា ដោយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស រងការបង្ក្រាប និងការជៅមុខសញ្ញាដោយសារតែការអនុវត្តសិទ្ធិស្របច្បាប់ក្នុងការរាយការណ៍ និងការតស៊ូមតិសំខាន់ៗរបស់ខ្លួន។ តារាងខាងក្រោមនេះសង្ខេបអំពីស្ថានភាពនៃសិទ្ធិទាំងបីក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ៖




[24]ស៊ឹង និមល "ក្រសួងព័ត៌មានបញ្ចប់ជាស្ថាពរនូវសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបន្ទាប់ពីមានការពន្យារពេលយ៉ាងយូរ" (ខេមបូចា ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤)

## ៤.១. ស្ថានភាពនៃសេរីភាពសារព័ត៌មាន[25]

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះរដ្ឋាភិបាលបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តលើកកម្ពស់សេរីភាពសារព័ត៌មាន។[26] នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានចេញផ្សាយនូវរបាយការណ៍ស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា ដោយផ្អែកលើការស្ទង់មតិអ្នកសារព័ត៌មានចំនួន ៣៤១ នាក់នៅទូទាំងប្រទេស។ របាយការណ៍នេះបានរកឃើញថា អ្នកឆ្លើយតប ៧៩,៨% បានវាយតម្លៃសេរីភាពសារព័ត៌មាននៅកម្ពុជាថា "ល្អ" ឬ "ល្អណាស់"។ ភាគរយដដែលនៃអ្នកឆ្លើយតបនេះក៏បានបង្ហាញឱ្យឃើញថាពួកគេមានសេរីភាពពេញលេញនៅក្នុងអាជីពការងាររបស់ពួកគេ ដោយមានសុវត្ថិភាព និងងាយស្រួលក្នុងការប្រមូលព័ត៌មាន សរសេរព័ត៌មាន និងបោះពុម្ពផ្សាយស្នាដៃនិពន្ធដោយមិនមានការរឹតត្បិត។ បន្ថែមពីនេះ ៩៥% នៃអ្នកសារព័ត៌មានដែលបានស្ទង់មតិ បានលើកឡើងថាភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា បានចូលរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់សេរីភាពសារព័ត៌មាន។[27]




យោងតាមក្រសួងព័ត៌មានរបស់កម្ពុជា *"ទោះបីជាមិនមានអ្នកសារព័ត៌មានជាប់ពន្ធនាគារ ឬរងការពិន័យដោយសារតែការរាយការណ៍ស្របច្បាប់ក្នុងរយៈពេលប្រាំពីឆ្នាំចុងក្រោយក្តី ក៏មានការទទួលស្គាល់ថាបុគ្គលមួយចំនួនបានប្រើប្រាស់បុព្វសិទ្ធិសារព័ត៌មានមិនត្រឹមត្រូវដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬសកម្មភាពល្មើសច្បាប់ដែរ"*។ ក្រសួងព័ត៌មានបានសង្កត់ធ្ងន់ថា វិធានការប្រឆាំងនឹងសកម្មភាពល្មើសច្បាប់នេះ មិនគួរចាត់ទុកថាជាការរំលោភបំពានទៅលើសេរីភាពសារព័ត៌មាននោះទេ។ [28] ជាចុងក្រោយ របាយការណ៍នេះបានសន្និដ្ឋានថា

[25]អត្ថបទព័ត៌មាននៅក្នុងប្រអប់ស្តីពីចំនួនស្ថាប័នសារព័ត៌មានដកស្រង់ចេញពី៖ ក្រសួងព័ត៌មាន "របាយការណ៍ស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា" (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤) https://tinyurl.com/mr4659u5 ។
[26]បែន សុខហ៊ាន "លោកនាយករដ្ឋមន្ត្រីគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្ត "សេរីភាពសារព័ត៌មាន" (*ខ្មែរថាមស៍* ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤)។
[27]ក្រសួងព័ត៌មាន "របាយការណ៍ស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា" (ថ្ងៃទី៣០ ថ្ងៃមេសា ឆ្នាំ២០២៤) https://tinyurl.com/mr4659u5 ទំព័រ ១៦។
[28]*ដូចខាងលើ* ទំព័រ ២២។

*"សេរីភាពសារព័ត៌មាន និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា មានស្ថានភាពល្អ និងមានវឌ្ឍនភាពផ្ទៃមានយ៉ាងស្ថិរភាព ស្របតាមការអភិវឌ្ឍ និងវឌ្ឍនភាពនៅក្នុងសង្គមកម្ពុជា"។*[29]

ទោះជាយ៉ាងនេះក្តី របកគំហើញរបស់ ម.ស.ម.ក បង្ហាញថា សេរីភាពសារព័ត៌មាននៅកម្ពុជានៅបន្តរងការរឹតត្បិត ដោយស្ថានភាពរបស់អ្នកសារព័ត៌មាននៅបន្តធ្លាក់ចុះគួរឱ្យកត់សម្គាល់។ របាយការណ៍អន្តរជាតិផ្សេងៗទៀតក៏បាន អះអាងអំពីព័ត៌មាននេះផងដែរ។ ឧទាហរណ៍ អង្គការអ្នករាយការណ៍គ្មានព្រំដែន បានទម្លាក់ចំណាត់ថ្នាក់កម្ពុជាពីលេខរៀង ១៤៧ ក្នុងចំណោម ១៨០ ប្រទេសនៅឆ្នាំ២០២៣ មកលេខរៀង ១៥១ នៅឆ្នាំ២០២៤ ដោយកត់សម្គាល់ថា ការតបតទៅនឹងអ្នកសារព័ត៌មានពីសំណាក់រដ្ឋាភិបាលមានការកើនឡើង ដែលគេចាត់ប្រទេសកម្ពុជាចូលទៅក្នុងបញ្ជីប្រទេសដែលមានស្ថានភាពសេរីភាពសារព័ត៌មាន "ធ្ងន់ធ្ងរណាស់"។[30] នៅលើគេហទំព័ររបស់អង្គការអ្នករាយការណ៍គ្មានព្រំដែនប្រចាំប្រទេសកម្ពុជាលើកឡើងបន្ថែមថា ប្រធានបទជាច្រើន ដូចជា គណបក្សនយោបាយជំទាស់ អំពើពុករលួយ និងការកាប់បំផ្លាញព្រៃឈើ គឺមិនអាចយកមកធ្វើការផ្សព្វផ្សាយបានទេ និងលើកឡើងថា *"រលកនៃការបិទ និងបង្ក្រាបស្ថាប័នសារព័ត៌មាននៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ បានកំណត់ឱ្យប្រជាជនកម្ពុជាទទួលបានព័ត៌មានដែលផ្តល់ជូនពីសំណាក់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយធំៗប៉ុណ្ណោះ"* ដែលដំណើរការដោយអ្នកមានអំណាចដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សនយោបាយកាន់អំណាច។[31]

ដូចគ្នានេះដែរ អង្គការហ្វ្រីដឹមហៅស៍ បានផ្តល់ពិន្ទុដល់កម្ពុជាត្រឹម ១ ក្នុងចំណោម ៤ ប៉ុណ្ណោះ សម្រាប់សំណួរ *"តើមានប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យដែរឬទេ?"* នៅក្នុងរបាយការណ៍ស្តីពីសេរីភាពពិភពលោកឆ្នាំ២០២៤ របស់អង្គការ ដោយគូសបញ្ជាក់ឱ្យឃើញអំពីបរិយាកាសសារព័ត៌មានដែលមានការរឹតត្បិតខ្លាំង។ អង្គការនេះក៏បានកត់សម្គាល់ថា ចាប់តាំងពីឆ្នាំ២០១៧ មក រដ្ឋាភិបាលបានបង្ក្រាបទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដោយប្រើប្រាស់បណ្តឹង ការផ្តន្ទាទោស ការពិន័យផ្នែកពន្ធដាក្នុងបរិមាណច្រើន ហើយជួនកាល ប្រើប្រាស់អំពើហិង្សាដើម្បីធ្វើការយាយី និងបំភិតបំភ័យបណ្តាញផ្សព្វផ្សាយទាំងឡាយណាដែលរាយការណ៍រិះគន់។ អង្គការហ្វ្រីដឹមហៅស៍បានសង្កត់ធ្ងន់បន្ថែមទៀតថា ប្រព័ន្ធផ្សព្វផ្សាយគាំទ្ររដ្ឋាភិបាលធ្វើប្រតិបត្តិការដោយសេរីក៏ដោយ ប៉ុន្តែស្ថាប័នបរទេសប្រឈមមុខនឹងការដាក់កំហិតតឹងរ៉ឹង ហើយនៅក្នុងករណីខ្លះ ត្រូវបានបង្ខំឱ្យចាកចេញពីប្រទេសទាំងស្រុងតែម្តង។[32]

ការអនុម័ត ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន គឺជាភស្តុតាងដែលបញ្ជាក់អំពីបញ្ហាចម្រូងចម្រាសក្នុងអំឡុងពេលនៃការសរសេររបាយការណ៍។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានដាក់ចេញនូវសេចក្តីព្រាងធម្មនុញ្ញនេះ នៅក្នុងអំឡុងពេលនៃការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយសមាគមប្រព័ន្ធ

[29] *ដូចខាងលើ* ទំព័រ ៤៣។

[30] អង្គការអ្នករាយការណ៍គ្មានព្រំដែន "អាស៊ីប៉ាស៊ីហ្វិក សេរីភាពសារព័ត៌មានស្ថិតក្រោមគំនាបរដ្ឋាភិបាលផ្តាច់ការ" (សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ ចូលមើលថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤) https://tinyurl.com/nhz83zpn។

[31] អង្គការអ្នករាយការណ៍គ្មានព្រំដែន "គេហទំព័រប្រចាំប្រទេស៖ កម្ពុជា" (សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ ចូលមើលថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤) https://tinyurl.com/69dvbfzs។

[32] អង្គការហ្វ្រីដឹមហៅស៍ "សេរីភាពនៅក្នុងពិភពលោក ឆ្នាំ២០២៤៖ កម្ពុជា" (ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤) https://tinyurl.com/eutszedj។

ផ្សព្វផ្សាយ និងអ្នកសារព័ត៌មានប្រមាណ ២០០ ស្ថាប័ន។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក នេត្រ ភក្ត្រា បានសង្កត់ធ្ងន់ថា លិខិតូបករណ៍នេះត្រូវការជាចាំបាច់ដើម្បីដោះស្រាយបញ្ហារីករាលដាលនៃព័ត៌មានក្លែងក្លាយ ដោយបន្ថែមថា បញ្ហាដូចជា"កង្វះប្រភពច្បាស់លាស់" និង "ការបកស្រាយរបស់ភាគីពាក់ព័ន្ធ" នៅក្នុងអត្ថបទព័ត៌មាន បានធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តសាធារណជន និងវិស័យប្រព័ន្ធផ្សព្វផ្សាយទាំងមូល។ អ្នកចូលរួមមានពេលរហូតដល់ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ ដើម្បីដាក់ជូនធាតុចូលនានាពាក់ព័ន្ធនឹងសេចក្តីព្រាងនេះ ប៉ុន្តែទាំង អង្គការយូណេស្កូ និងសារព័ត៌មាន ខេមបូចា បានស្នើសុំពេលវេលាបន្ថែមទៀត។ សារព័ត៌មាន ខេមបូចា បានសង្កត់ធ្ងន់ទៅលើភាពចាំបាច់ដែលត្រូវមានស្ថាប័នឯករាជ្យត្រួតពិនិត្យលើការអនុវត្តតាមស្តង់ដារវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដោយមិនទទួលរងឥទ្ធិពលពីសំណាក់រដ្ឋាភិបាល។[33]

ត្រឹមតែរយៈពេលបួនថ្ងៃប៉ុណ្ណោះ បន្ទាប់ពីកាលបរិច្ឆេទកំណត់ក្នុងការដាក់ជូនធាតុចូល នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានប្រកាសឱ្យប្រើប្រាស់ធម្មនុញ្ញនេះ ដោយមិនបានរៀបចំធ្វើការពិគ្រោះយោបល់បន្ថែមនោះទេ។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក នេត្រ ភក្ត្រា បានថ្លែងការពារការប្រកាសដាក់ឱ្យប្រើប្រាស់ដ៏ឆាប់រហ័សបែបនេះ ដោយបានលើកឡើងថា ធម្មនុញ្ញនេះមានគោលបំណង "បង្កើតសណ្តាប់ធ្នាប់" និង "មិនគាបសង្កត់សេរីភាពព័ត៌មាន ឬបំបិទសេរីភាពឡើយ"។ លោកបានកត់សម្គាល់ថា ទោះបីជាមានការទទួលយកមតិចូលរួមមួយចំនួនក្តី ក៏នៅមានការស្នើសុំមួយចំនួនត្រូវបានបដិសេធព្រោះជា "ទស្សនៈបរទេស"។ លោក ណុប វី នាយកប្រតិបត្តិនៃសារព័ត៌មាន ខេមបូចា បានសម្តែងក្តីព្រួយបារម្ភចំពោះដំណើរការ "បន្ទាន់" បែបនេះ និងកង្វះធាតុបញ្ចូលសំខាន់ៗ" នៃសំណើរបស់សមាគមប្រព័ន្ធផ្សព្វផ្សាយ។ ទោះបីជាធម្មនុញ្ញនេះលើកឡើងអំពីការបង្កើតគណៈកម្មាធិការឯករាជ្យមួយនៅពេលអនាគតដើម្បីត្រួតពិនិត្យលើការអនុវត្តក៏ដោយ ក៏ព័ត៌មានលម្អិតអំពីសមាសភាពគណៈកម្មាធិការនេះនៅតែមិនមានភាពច្បាស់លាស់នៅឡើយទេ។[34] ក៏មានការលើកឡើងអំពីក្តីព្រួយបារម្ភអំពីការដាក់ចេញនូវពាក្យមិនច្បាស់លាស់ ដូចជា "ការញុះញង់" "ការប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ" និង "សន្តិសុខជាតិ" ដែលឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ក្រមព្រហ្មទណ្ឌបច្ចុប្បន្នដើម្បីគាបសង្កត់ការរាយការណ៍ឯករាជ្យ។

នៅថ្ងៃទៅ១២ ខែកញ្ញា ឆ្នាំ២០២៤ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានអំពាវនាវឱ្យមានការព្យួរធម្មនុញ្ញនេះ ដោយលើកឡើងអំពីកង្វះការពិគ្រោះយោបល់ និងការផ្តល់ធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយពីភាគីពាក់ព័ន្ធ។ អ្នករាយការណ៍ពិសេសបានសង្កត់ធ្ងន់ថា ក្រមវិជ្ជាជីវៈប្រព័ន្ធផ្សព្វផ្សាយគួររៀបចំជាសេចក្តីព្រាងដោយប្រព័ន្ធផ្សព្វផ្សាយ និងដើម្បីប្រព័ន្ធផ្សព្វផ្សាយ មិនមែនតាមរយៈដំណើរការដឹកនាំដោយក្រសួងនោះទេ។ អ្នករាយការណ៍ពិសេស ក៏បានកត់សម្គាល់ដែរថា យន្តការត្រួតពិនិត្យនានាត្រូវតែមានសិទ្ធិអំណាចឯករាជ្យ ដែលជាការធានាមួយមិនបានចែងនៅក្នុងធម្មនុញ្ញនេះឡើយ។ ជាចុងក្រោយ អ្នករាយការណ៍បានចង្អុលបង្ហាញឱ្យឃើញថា ធម្មនុញ្ញនេះមិនបានរួមបញ្ចូលផលប្រយោជន៍សាធារ

[33]ស៊ឹង និមល "ប្រតិកម្មចម្រុះមកលើការពិគ្រោះយោបល់របស់ក្រសួងព័ត៌មានអំពីសេចក្តីព្រាងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤)។

[34] ស៊ឹង និមល "ធម្មនុញ្ញស្តីពីវិជ្ជាជីវៈសារព័ត៌មាន បានអនុវត្តយ៉ាងរហ័សក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីកាលបរិច្ឆេទកំណត់ដាក់ជូនធាតុចូល" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៤)។

ណៈឱ្យមានប្រៀបជាង និងមិនបង្កើតសិទ្ធិក្នុងការកែតម្រូវ និងឆ្លើយតបចំពោះកំហុសនោះទេ ព្រមទាំងបានលើកឡើងអំពីក្ដីព្រួយបារម្ភអំពីការផ្ដោតទៅលើការផ្សព្វផ្សាយតែព័ត៌មានសុក្រឹត ជាជាងការកំណត់អាទិភាពទៅលើការផ្ទៀងផ្ទាត់មុនពេលចុះផ្សាយ។[35]

ជាការឆ្លើយតប ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជានៅទីក្រុងហ្សឺណែវ បានលើកឡើងថា "ការធ្វើឱ្យយល់ច្រលំ" ពី "សេចក្ដីថ្លែងការណ៍បំភាន់ និងបុរេវិនិច្ឆ័យ" របស់អ្នករាយការណ៍ពិសេស មុនពេលលើកទឡ្ហីករណ៍ថា "ធម្មនុញ្ញនេះមិនបានរំលោភបំពានលើសេរីភាពខាងបញ្ចេញមតិនោះទេ ប៉ុន្តែផ្ទុយទៅវិញបង្កើតបានជាបរិយាកាសអំណោយផលមួយសម្រាប់សារព័ត៌មានប្រកបដោយទំនួលខុសត្រូវ និងលើកកម្ពស់សេរីភាពសារព័ត៌មានទៅវិញទេ។" ស្ថានបេសកកម្មអចិន្ត្រៃយ៍នេះក៏បានបន្តជំរុញឱ្យអ្នកជំនាញការអង្គការសហប្រជាជាតិឱ្យប្រកាន់ខ្ជាប់តាមក្រមប្រតិបត្តិសម្រាប់អ្នកកាន់អាណត្តិនីតិវិធីពិសេស និងរារាំងពី "ការធ្វើសេចក្ដីថ្លែងការណ៍សាធារណៈដែលអាចបង្កើតឡើងជាការជ្រៀតជ្រែកនៅក្នុងដែនយុត្តាធិការជាតិកម្ពុជា។[36]"

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជារបស់ ម.ស.ម.ក បានកត់ត្រាអំពីការរឹតត្បិតជាច្រើនដែលអ្នកសារព័ត៌មានជួបប្រទះ នៅពេលអនុវត្តការងារស៊ើបអង្កេត និងអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ។ ការរឹតត្បិតទាំងនេះ រួមមានការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ ការយាយីតាមប្រព័ន្ធតុលាការ ការរារាំងពីការរាយការណ៍បញ្ហារសើប ដែលនាំឱ្យមានការដាក់កំហិតខ្លួនឯង និងការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ និងការយាយីតាមប្រព័ន្ធអ៊ីនធឺណិត ដែលសុទ្ធតែកើតឡើងដោយការមិនមានទោសពៃអ្វីទាំងអស់។ របកគំហើញទាំងនេះ រួមជាមួយនឹងការវាយតម្លៃពីអង្គការអ្នករាយការណ៍គ្មានព្រំដែន និងអង្គការហ្វ្រីដឹមហៅស៍ គឺផ្ទុយទៅនឹងការអះអាងរបស់ក្រសួងព័ត៌មានអំពីសេរីភាពសារព័ត៌មានដូចដែលបានលើកឡើងក្នុងរបាយការណ៍ដែលបានចេញផ្សាយកាលពីពេលថ្មីៗនេះ។ បញ្ហាទាំងនេះគូសបញ្ជាក់ឱ្យឃើញបន្ថែមទៀតថា សេរីភាពសារព័ត៌មាន ដែលជាសសរស្តម្ភនៃប្រជាធិបតេយ្យ និងនីតិរដ្ឋ កំពុងស្ថិតក្នុងស្ថានភាពមិនល្អ។

## ការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ

អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ បានលើកឡើងថា ពួកគេមិនហ៊ានសរសេរអំពីសន្តិសុខជាតិ និងនយោបាយនោះទេ ដោយសារតែខ្លាចប្រឈមមុខនឹងការចោទប្រកាន់ផ្លូវច្បាប់ និងការដកហូតអាជ្ញាបណ្ណពីសំណាក់ក្រសួងព័ត៌មាន។ សក្ខីកម្មនេះគូសបញ្ជាក់ឱ្យឃើញថា ការដកហូតអាជ្ញាបណ្ណបច្ចុប្បន្ន គឺត្រូវបានគេយល់ឃើញថាជាការគំរាមកំហែងមួយ និងជាមធ្យោបាយតបតទៅលើអ្នកសារព័ត៌មាន និងស្ថាប័នផ្សព្វផ្សាយដែលហ៊ានចុះផ្សាយប្រធានបទរសើប។ រាជរដ្ឋាភិបាលកម្ពុជាបានដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយសរុបចំនួនបី ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍

[35] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ប្រទេសកម្ពុជា៖ ជំនាញការអង្គការសហប្រជាជាតិអំពាវនាវឱ្យមានការផ្អាកធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន" (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤) https://tinyurl.com/5bdcxa9y។

[36] រាជរដ្ឋាភិបាលកម្ពុជា "សេចក្ដីថ្លែងការណ៍សារព័ត៌មាន៖ ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន គឺជាសមិទ្ធផលស្របច្បាប់ក្នុងការការពារអ្នកសារព័ត៌មាន និងកសាងទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធផ្សព្វផ្សាយ" (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤) https://tinyurl.com/ycxeat7z។

ដោយបញ្ជាក់អំពីវិសាលភាពនៃវិធានការនេះនៅតែបន្តអនុវត្តដើម្បីតបតចំពោះការរាយការណ៍រិះគន់នៅក្រោមរូបភាពដើម្បីរក្សាក្រមសីលធម៌វិជ្ជាជីវៈ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណសារព័ត៌មានជីវិត និងកីឡា ដោយចោទប្រកាន់ថាមិនគោរពតាមការណែនាំរបស់ក្រសួង រំលោភលើឯកសារផ្លូវច្បាប់ និងរំលោភបំពាន "ធ្ងន់ធ្ងរ" លើវិជ្ជាជីវៈ និងក្រមសីលធម៌សារព័ត៌មាន។ សារព័ត៌មានចុះផ្សាយបានទទួលការជូនដំណឹងអំពីសេចក្តីសម្រេចនេះតាមរយៈលិខិតចុះថ្ងៃទី១៨ ខែមីនា ដោយបានរាយការណ៍ថាមិនមានការជូនដំណឹងជាមុននោះទេ។ ការដកហូតនេះបានធ្វើឡើងភ្លាមៗ បន្ទាប់ពីការចុះផ្សាយរបាយការណ៍មួយរបស់ស្ថាប័នសារព័ត៌មាននេះនៅថ្ងៃទី១៦ខែកុម្ភៈ អំពីការអះអាងអំពើពុករលួយដែលពាក់ព័ន្ធនឹងប្រធានមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង។ របាយការណ៍នេះបានអះអាងអំពីភាពមិនប្រក្រតីនៅក្នុងការទិញសម្ភារៈបរិក្ខារ ដោយលើកឡើងអំពីវិក្កយបត្រពីអ្នកផ្គត់ផ្គង់ និងការសម្ភាសជាមួយនឹងមន្ត្រីនៅមន្ទីរនោះដែលបានស្នើសុំមិនបញ្ចេញឈ្មោះ។ នៅថ្ងៃទី១៩ ខែកុម្ភៈ មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែងបានបដិសេធអំពីការអះអាងនេះ និងបានគំរាមកំហែងចាត់វិធានការផ្លូវច្បាប់ប្រសិនបើមិនធ្វើការកែតម្រូវទេ។ សារព័ត៌មានចុះផ្សាយបានបដិសេធក្នុងការអនុវត្តតាមការណែនាំនេះ ដោយបានអះអាងថារឿងរ៉ាវនេះគឺមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់។[37]

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណ www.kruth01.com និង www.khmerpostnews.com ដោយលើកឡើងអំពីការរំលោភបំពាន "ធ្ងន់ធ្ងរ" លើវិជ្ជាជីវៈ និងក្រមសីលធម៌សារព័ត៌មាន។ សារព័ត៌មានចុះផ្សាយទាំងពីរនេះបានបដិសេធថាមិនបានប្រព្រឹត្តអ្វីខុសឆ្គងនោះទេ។ ស្ថាប័នទាំងពីរធ្លាប់ចុះផ្សាយមាតិកាដែលផ្តោតលើមន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរនៅមុនពេលមានបញ្ហានេះកើតឡើង។ អ្នកចុះផ្សាយនៃសារព័ត៌មានខ្មែរប៉ុស្តិ៍ បានអះអាងថាមិនមានការជូនដំណឹង ឬឱកាសក្នុងការពិភាក្សាមុនពេលការដកហូតអាជ្ញាបណ្ណនោះទេ។ អ្នកនាំពាក្យក្រសួងព័ត៌មាន លោក ទេព អស្នារិទ្ធ បានលើកឡើងថា ស្ថាប័ន ទាំងនេះបានពាក់ព័ន្ធនៅក្នុងបទល្មើសនៃការជំរិតទារប្រាក់ និងទទូចថាបានជូនដំណឹងជាមុនរួចហើយ។ យោងតាមប្រព័ន្ធផ្សព្វផ្សាយនៅមូលដ្ឋាន សារព័ត៌មានចុះផ្សាយទាំងពីរនេះត្រូវបានគេរាយការណ៍ថាទទួលរងការចោទប្រកាន់ពីបទប្រើប្រាស់អំពើហិង្សាក្នុងអំឡុងពេលនៃវិវាទរវាងអ្នកលេងល្បែងស៊ីសង អំឡុងពេលរាយកាណ៍អំពីការជល់មាន់ខុសច្បាប់នៅខេត្តកណ្តាលកាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ ដែលបាននាំឱ្យមានការចាប់ខ្លួនពួកគេនៅរយៈពេលបីថ្ងៃបន្ទាប់។[38]

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ អាជ្ញាធរបានគំរាមកំហែងយ៉ាងច្បាស់អំពីការដកហូតអាជ្ញាបណ្ណ។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគំរាមសារព័ត៌មានខេមបូចា ថានឹងចាត់វិធានការផ្លូវច្បាប់ ប្រសិនបើសារព័ត៌មាននេះមិនព្រមលុបឈ្មោះរដ្ឋមន្ត្រីក្រសួងកសិកម្ម លោក ឌិត ទីណា ពីអត្ថបទសារព័ត៌មានមួយអំពីការវាយដំជាសាធារណៈ មកលើអ្នកជំនាញកសិកម្ម

---

[37]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០២៤) ទំព័រ ១៣ និង ១៩ https://tinyurl.com/3v7eauxy។

[38]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា – ខែមិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០២៤) ទំព័រ ១៦ https://tinyurl.com/3v7eauxy។

លោក នី ណាក់។ ក្រសួងបានចោទប្រកាន់ស្ថាប័ននេះពីបទរាយការណ៍ដោយស្មានថាការវាយប្រហារមកលើលោក នី ណាក់ គឺមកពីកត្តានយោបាយ និងជាប់ទាក់ទិនទៅនឹងការរិះគន់លើបណ្តាញសង្គមរបស់លោកកាលពីពេលថ្មីៗនេះអំពីមន្ត្រីរដ្ឋាភិបាល។ ក្រសួងបានបដិសេធពីការបញ្ចូលឈ្មោះរបស់រដ្ឋមន្ត្រីទៅក្នុងអត្ថបទព័ត៌មាននេះ ដោយបានកត់សម្គាល់ថា លោក នី ណាក់ មិនបានលើកឡើងអំពីលោករដ្ឋមន្ត្រីដោយផ្ទាល់នៅលើការផ្សព្វផ្សាយលើហ្វេសប៊ុករបស់លោកនោះទេ។ ក្រសួងបានទាមទារឱ្យសារព័ត៌មាន ខេមបូចា លុបឈ្មោះរដ្ឋមន្ត្រីចេញ និង "កែសម្រួលការរំលោភបំពានធ្ងន់ធ្ងរទាំងនេះលើក្រមសីលធម៌សារព័ត៌មាន ដោយលុបចោលការអះអាង និងការប៉ាន់ស្មានមិនមានភស្តុតាងបញ្ជាក់ចេញ។" លើសពីនេះ ក្រសួងបានជំរុញស្ថាប័នឱ្យធានាឱ្យបានថា "គោលបំណងទុច្ចរិត និងការបរិហាកេរ្តិ៍នេះ មិនត្រូវកើតឡើងម្តងទៀតឡើយ" ដោយព្រមានថា ការខកខានមិនអនុវត្តតាម "នឹងនាំឱ្យមានការចាត់វិធានការផ្លូវច្បាប់ ដែលអាចនាំឱ្យមានលទ្ធផលដូចគ្នាទៅនឹង វីអូឌី [វិទ្យុសំឡេងប្រជាធិបតេយ្យ]" ដែលបានដកហូតអាជ្ញាបណ្ណកាលពីខែកុម្ភៈ ឆ្នាំ២០២៣។ ជាចុងក្រោយសារព័ត៌មាន ខេមបូចា សុខចិត្តអនុវត្តតាម និងបានលុបឈ្មោះរដ្ឋមន្ត្រីចេញពីអត្ថបទព័ត៌មាន។[39]

លើសពីនេះ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ TN TV បានចុះផ្សាយអត្ថបទព័ត៌មានមួយដោយអះអាងថា ឧត្តមសេនីយ៍ផ្កាយបីម្នាក់មិនបានទូទាត់សងកម្ចី ១ លានដុល្លារអាមេរិក។ បន្ទាប់មក ឧត្តមសេនីយ៍រូបនោះបានប្តឹងទៅលើសារព័ត៌មានចុះផ្សាយពីបទបរិហាកេរ្តិ៍ និងញុះញង់ បន្ទាប់ពីសារព័ត៌មាននេះបដិសេធលុបអត្ថបទព័ត៌មាននោះចោល ដែលសារព័ត៌មាននេះការពារខ្លួនទៅវិញថា អត្ថបទព័ត៌មាននេះគឺផ្អែកលើភស្តុតាងរឹងមាំ។ ដើមបណ្តឹងក៏បានដាក់ពាក្យបណ្តឹងនៅក្រសួងព័ត៌មាន ដោយស្នើសុំដកហូតអាជ្ញាបណ្ណរបស់ TN TV។ នៅថ្ងៃទី០៦ ខែមីនា ក្រសួងបានរៀបចំកិច្ចប្រជុំមួយជាមួយសារព័ត៌មានចុះផ្សាយ និងមេធាវីរបស់ឧត្តមសេនីយ៍ ដោយពិភាក្សាអំពីក្រមសីលធម៌សារព័ត៌មាន។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ គេរាយការណ៍ថាមេធាវីបានតវ៉ាឱ្យដកហូតអាជ្ញាបណ្ណរបស់ TN TV។[40] នៅថ្ងៃទី១២ ខែមេសា ក្រសួងបានព្រមានដល់ស្ថាប័នសារព័ត៌មានឱ្យលុបចោលអត្ថបទព័ត៌មាន "គ្មានមូលដ្ឋាន" នេះចេញ ឬត្រូវដកហូតអាជ្ញាបណ្ណ និងប្រឈមនឹងផលវិបាកផ្នែកច្បាប់ផ្សេងៗ។[41] ការឆ្លើយតបនេះ ជាការកំណត់យុត្តិសាស្ត្រគ្រោះថ្នាក់មួយ ដែលការដកហូតអាជ្ញាបណ្ណអាចក្លាយជាការទាមទារទូទៅ (ការប្រើប្រាស់យុទ្ធិសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ) ប្រឆាំងទៅលើអ្នកសារព័ត៌មាន ដែលបង្កើតឱ្យមានឥទ្ធិពលភ័យខ្លាចមកលើការរាយការណ៍បញ្ហារសើបដែលពាក់ព័ន្ធនឹងបុគ្គលមានអំណាច។

ការគំរាមកំហែងដកហូតអាជ្ញាបណ្ណដែលបានជួបប្រទះនេះ អាចបង្ខំឱ្យស្ថាប័នផ្សព្វផ្សាយលុបចោលនូវមាតិការសើបចេញក្រោមសម្ពាធពីអាជ្ញាធរ។ គួរឱ្យកត់សម្គាល់ផងដែរ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

[39]វិទ្យុអាស៊ីសេរីខ្មែរ 'បណ្តាញសារព័ត៌មានកម្ពុជា បានលុបឈ្មោះរដ្ឋមន្ត្រីចេញបន្ទាប់ពីការគំរាមកំហែងផ្លូវច្បាប់' (*វិទ្យុអាស៊ីសេរី* ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣)។

[40]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃ២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១៥ និងទំព័រ ១៦ https://tinyurl.com/3v7eauxy។

[41]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា – ខែមិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤) ទំព័រ ១៧ https://tinyurl.com/3v7eauxy។

សារព័ត៌មាន UMA TV Online News និងវិទ្យុស្ថានស្លឹករឹត សុទ្ធតែបានចុះផ្សាយអត្ថបទព័ត៌មានមួយអំពីការតវ៉ាពាក់ព័ន្ធនឹងដីធ្លីនៅខេត្តពោធិ៍សាត់នៅក្រោមចំណងជើងថា "មន្ត្រីបរិស្ថាន និងនគរបាលស្រុកចាប់ខ្លួនអនីតិជនដើម្បីសួរចម្លើយនៅតុលាការដោយមិនមានដីកា ឬសំអាងហេតុច្បាស់លាស់"។ ជាការឆ្លើយតប មន្ទីរបរិស្ថានខេត្តបានចោទប្រកាន់គេហទំព័រទាំងពីរនេះពីបទផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ និងញុះញង់ឱ្យមានការឈូសឆាយព្រៃឈើខុសច្បាប់។ មន្ទីរបានគំរាមប្តឹងស្ថាប័ននីមួយៗនូវទឹកប្រាក់ចំនួន ១០០ លានរៀល ប្រសិនបើមិនលុបអត្ថបទព័ត៌មាននេះទេ និងបានរាយការណ៍បញ្ហានេះទៅកាន់ក្រសួងព័ត៌មាន។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រសួងបានជួបជាមួយនឹងនិពន្ធនាយករបស់សារព័ត៌មាន UMA TV Online News និងវិទ្យុស្ថានស្លឹករឹត ដោយទាមទារឱ្យស្ថាប័នទាំងពីរលុបរបាយការណ៍នេះចេញ។ កាលដំបូងស្ថាប័នទាំងពីរបានបដិសេធចំពោះការទាមទារនេះ តែក្រោយមកបានយល់ព្រមអនុវត្តតាម ដោយភ័យខ្លាចថាក្រសួងអាចនឹងដកហូតអាជ្ញាបណ្ណរបស់ពួកគេ។[42]

ជារួម ការប្រើវិធានដកហូតអាជ្ញាបណ្ណពីសំណាក់អាជ្ញាធរ និងភាគីទីបីនេះ មិនត្រឹមតែរាំងដល់វិស័យសារព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្វែងការយកចិត្តទុកដាក់ពីការដោះស្រាយសុពលភាពនៃបញ្ហាដែលបានរាយការណ៍ ទៅជាការវាយប្រហារលើស្ថាប័នផ្សព្វផ្សាយរាយការណ៍រិះគន់ទៅវិញ។ វិធីសាស្ត្របែបនេះធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានគ្រឹះនៃសេរីភាពសារព័ត៌មាន និងជំរុញឱ្យមានការដាក់កំហិតខ្លួនឯង ដែលបង្កជាការគំរាមកំហែងមួយយ៉ាងធ្ងន់ធ្ងរចំពោះតួនាទីដ៏សំខាន់នៃសារព័ត៌មានក្នុងការឱ្យអ្នកមានអំណាចទទួលខុសត្រូវ។ ប្រសិនបើទុកចោលមិនមានការត្រួតពិនិត្យ យុទ្ធសាស្ត្រនៃការប្រើប្រាស់យន្តការផ្លូវច្បាប់ និងនិយ័តកម្មដើម្បីបំបិទសំឡេងស្ថាប័នរិះគន់បែបនេះ អាចធ្វើឱ្យសមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយធ្លាក់ដុនដាបក្នុងការរាយការណ៍អំពីបញ្ហាដែលជាប្រយោជន៍សាធារណៈ ដែលជាចុងក្រោយធ្វើឱ្យការផ្សព្វផ្សាយបែបប្រជាធិបតេយ្យចុះអន់ថយ។

## ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរបានយាយីទៅលើប្រព័ន្ធផ្សព្វផ្សាយក្នុងគោលបំណងទប់ស្កាត់ ឬដាក់ទណ្ឌកម្មទៅលើសារព័ត៌មានដែលផ្សាយរិះគន់។ ចំណាត់ការផ្លូវច្បាប់បាននឹងកំពុងបន្តដាក់ចេញពីអាជ្ញាធរ និងភាគីទីបីដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងរឹតត្បិតសិទ្ធិ សេរីភាពក្នុងការរាយការណ៍របស់ពួកគេ។

អ្នកចូលរួមមួយចំនួននៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកសារព័ត៌មាន បានលើកឡើងថា ប្រព័ន្ធតុលាការ គឺត្រូវបានប្រើជាឧបករណ៍ដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន តាមរយៈការគំរាមកំហែងចាប់ខ្លួន។ ពួកគេបានកត់សម្គាល់ថា អាជ្ញាធរដាក់ពាក្យបណ្ដឹងជាញឹកញាប់ប្រឆាំងទៅលើអ្នកសារព័ត៌មានដោយសារតែការរាយការណ៍របស់ពួកគេ តែផ្ទុយទៅវិញនៅពេលដែលអ្នកសារព័ត៌មានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងមន្ត្រីពីបទរឹតត្បិត ឬរំលោភបំពានលើសេរីភាពសារព័ត៌មាន មិនឃើញមានការចាត់វិធានការអ្វីឡើយ។ ប្រការនេះបញ្ជាក់ឱ្យឃើញអំពីស្ដង់ដារពីរយ៉ាងច្បាស់លាស់ ដោយអាជ្ញាធរធ្វើសកម្មភាពដោយមិនមានទោស និងប្រើប្រាស់តុលាការដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន ប៉ុន្តែអ្នកសារព័ត៌មានគឺត្រូវប្រឈមនឹងផលវិបាកផ្លូវច្បាប់

[42]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែតុលា – ខែធ្នូ ឆ្នាំ២០២៤)" (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ទំព័រ ១៥ https://tinyurl.com/3v7eauxy។

សម្រាប់ការបំពេញតួនាទីស្របច្បាប់របស់ខ្លួន។ ជាលទ្ធផល អ្នកចូលរួមមួយចំនួនបានអង្កេតឃើញថា អ្នកសារព័ត៌មានជាញឹកញាប់បង្ខំចិត្តមិនដាក់ពាក្យបណ្ដឹង ដោយជឿថាក្ដីបារម្ភរបស់ពួកគេនឹងមិនមានអ្នកណាដោះស្រាយឱ្យឡើយ។

អ្នកសារព័ត៌មានចំនួនប្រាំពីរនាក់ដែលបានស្ទង់មតិ ក៏បានសម្ដែងអំពីក្ដីបារម្ភអំពីការប្រើប្រាស់ប្រព័ន្ធតុលាការជាឧបករណ៍ដើម្បីយាយីសេរីភាពសារព័ត៌មាននៅកម្ពុជា។ ពួកគេកត់សំគាល់ថាអំណាចតុលាការជាការគំរាមកំហែងដ៏ធំបំផុត ជាពិសេសនៅពេលប្រើដើម្បីដៅមុខសញ្ញាលើអ្នកសារព័ត៌មានដែលចោទប្រកាន់ពីបទបរិហាកេរ្តិ៍ និងញុះញង់នៅក្រោមក្រមព្រហ្មទណ្ឌ។ អ្នកសារព័ត៌មាន បានបញ្ជាក់ពីភាពភ័យខ្លាចនៃការប្រឈមមុខនឹងបណ្ដឹងផ្លូវច្បាប់បន្ទាប់ពីចុះផ្សាយអត្ថបទព័ត៌មាន ជាពិសេស នៅពេលដែលការរាយការណ៍របស់ពួកគេប៉ះទៅលើបុគ្គលដែលកាន់អំណាច។ អ្នកសារព័ត៌មានមួយចំនួនបានកត់សម្គាល់ថា ការគំរាមកំហែងដាក់ពន្ធនាគារ គឺត្រូវបានប្រើប្រាស់ច្រើនឡើងៗ ដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន ដោយមានអ្នកសារព័ត៌មានម្នាក់ចង្អុលបង្ហាញថាមន្ត្រីតុលាការជាន់ខ្ពស់គឺជាអ្នកគំរាមកំហែងដោយផ្ទាល់។ ការប្រើប្រាស់ប្រព័ន្ធតុលាការជាយុទ្ធសាស្ត្រនេះ មិនត្រឹមតែបង្អាក់ទឹកចិត្តអ្នកសារព័ត៌មានពីការចុះផ្សាយរឿងរ៉ាវសើបប៉ុណ្ណោះទេ តែថែមទាំងមានគោលបំណងបំបាក់ស្មារតីរបស់ពួកគេ ហេតុដូច្នេះការធ្វើបែបនេះគឺធ្វើឱ្យប៉ះពាល់ដល់តួនាទីដ៏សំខាន់នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងការធ្វើយ៉ាងណាឱ្យអ្នកមានអំណាចមានការទទួលខុសត្រូវ។

នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជា ឬភាគីទីបី បានចាត់វិធានការផ្លូវច្បាប់មកលើអ្នកសារព័ត៌មានយ៉ាងតិច ១៧ នាក់ ដែលមានការកើនឡើងពីចំនួនអ្នកសារព័ត៌មាន (១៦ នាក់) ដែលប្រឈមមុខនឹងវិធានការផ្លូវច្បាប់នៅក្នុងរយៈពេលដូចគ្នានៃរបាយការណ៍មុន។ ក្នុងចំណោមអ្នកសារព័ត៌មានទាំងនេះ៖

**ការចាត់វិធានការផ្លូវច្បាប់មកលើអ្នកសារព័ត៌មានយ៉ាងតិច ១៧ នាក់**




*អ្នកសារព័ត៌មាន ៣ នាក់ ត្រូវបានផ្តន្ទាទោស ឬបានតម្កល់សាលក្រមទុកជាបានការដោយតុលាការជាន់ខ្ពស់ នៅចន្លោះពេលចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤*

**សារព័ត៌មានខ្មែរដោយដែន** – កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ អ្នកសារព័ត៌មានខ្មែរដោយដែន ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារប្រាំមួយខែ និងពិន័យជាប្រាក់ ២ លានរៀល ($៥០០)

ពីបទញុះញង់ និងក្លែងបន្លំឯកសារ ទោះបីយ៉ាងណា ការផ្តន្ទាទោសនេះត្រូវបានព្យួរទោស។ លោកត្រូវបានគេចាប់ខ្លួននៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ នៅខេត្តបន្ទាយមានជ័យ និងបានបញ្ជូនទៅឃុំខ្លួនមុនពេលសវនការរយៈពេលពីរថ្ងៃក្រោយមក មុននឹងដោះលែងវិញនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។ យោងតាមអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស ("អង្គការលីកាដូ") លោកត្រូវបានគេឃុំខ្លួនបន្ទាប់ពីចុះផ្សាយរបាយការណ៍អំពីអំពើពុករលួយនៅមន្ទីរសុខាភិបាល និងសាខាពន្ធដារខេត្ត។ បន្ទាប់មក លោកត្រូវបានមន្ត្រីមកពីនាយកដ្ឋានទាំងនេះ ប្តឹងពីបទញុះញង់ និងបរិហារកេរ្តិ៍ ព្រមទាំងទទួលរងការចោទប្រកាន់ពីបទក្លែងបន្លំពាក់ព័ន្ធនឹងការរក្សាទុកបណ្ណកម្មសិទ្ធិអចលនទ្រព្យនៅប៉ោយប៉ែត។[43]

TNM **លោក សែម បូ៉ា** – នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ តុលាការខេត្តបាត់ដំបង បានសម្រេចផ្តន្ទាទោសលោក សែម បូ៉ា ដែលជាអ្នកសារព័ត៌មានទូរទស្សន៍អនឡាញមួយរូប ពីបទបរិហារកេរ្តិ៍នៅក្រោមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។ លោក បូ៉ា បានប្រឈមមុខនឹងវិធានការផ្លូវច្បាប់ពីសំណាក់អភិបាលស្រុកឯកភ្នំ បន្ទាប់ពីលោកបានរាយការណ៍អំពីទំនាស់ដីធ្លីចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២។ លោក បូ៉ា ដើមឡើយត្រូវបានកាត់ទោសកំបាំងមុខនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ និងត្រូវបានពិន័យជាប្រាក់ចំនួនបួនលានរៀល ($ ១.០០០) ដោយបានប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤។ លោក បូ៉ា បានសម្តែងការខកចិត្តរបស់លោកឱ្យសារព័ត៌មាន ខេមបូចា បានដឹង ដោយបានរិះគន់តុលាការអំពីការខកខានក្នុងការអនុវត្តច្បាប់ស្តីពីសារព័ត៌មានចំពោះសំណុំរឿងនេះ និងជំរុញឱ្យរដ្ឋាភិបាលធានាថាប្រព័ន្ធតុលាការមិនរារាំងដល់ការរាយការណ៍ពីការពិតនោះទេ។[44]

**អ្នកសារព័ត៌មាន នគរមាស ជីធីវី** –នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ តុលាការខេត្តមណ្ឌលគិរី បានចាត់ចំណាត់ការផ្តន្ទាទោសដាក់ពន្ធនាគារចំនួនបីឆ្នាំដែលបានព្យួរទោស មកលើអ្នកសារព័ត៌មានអនឡាញម្នាក់មកពីសារព័ត៌មាននគរមាស ជីធីវី (Norkor Meas GTV) ពីបទជំរិតទារប្រាក់។ អ្នកសារព័ត៌មានរូបនោះបានបដិសេធថាមិនបានប្រព្រឹត្តអំពើខុសឆ្គងនោះទេ។ កាលពីមុន លោកត្រូវបានគេចោទប្រកាន់ពីបទជំរិតទារប្រាក់នៅខែតុលា ឆ្នាំ២០២៣ អមជាមួយនឹងអ្នកសារព័ត៌មានបួនរូបផ្សេងទៀត ដែលខុសពីលោក ពួកគេត្រូវបានគេបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន។[45]

ករណីទាំងនេះបង្ហាញពីបញ្ហាប្រឈម ដែលអ្នកសារព័ត៌មានត្រូវប្រឈមមុខនៅពេលអនុវត្តការងាររបស់ពួកគេ។ អ្នកសារព័ត៌មានជាច្រើនប្រឈមនឹងការឃុំខ្លួន និងសាកសួរនៅពេលដែលពួកគេកំពុងបំពេញការងារ ប៉ុន្តែ ក៏មានការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌផងដែរ ដែលអាជ្ញាធរ និងភាគីទីបី ប្រើក្រមព្រហ្មទណ្ឌដើម្បីបំបិទការរាយការណ៍របស់ខ្លួន។ បណ្តឹងផ្លូវច្បាប់ជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមរបស់

---

[43] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ២៩ https://tinyurl.com/3v7eauxy។

[44] មាស ភារុណ "តុលាការខេត្តបាត់ដំបងផ្តន្ទាទោសអគ្គនាយកសារព័ត៌មាន TNM Online TV ពីបទបរិហារកេរ្តិ៍ និងពិន័យជាប្រាក់ ៤ លានរៀល" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)

[45] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា – ខែមិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤) ទំព័រ ១០ https://tinyurl.com/3v7eauxy។

សាធារណជន ត្រូវបានគេប្រើប្រាស់ជាឧបករណ៍មួយដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងមិនលើកទឹកចិត្តឱ្យពួកគេរាយការណ៍ អំពីបញ្ហាដែលត្រូវបានគេចាត់ទុកថាជារឿងសើប ឬពាក់ព័ន្ធនឹងអ្នកមានអំណាច ឬតួអង្គផ្នែកសេដ្ឋកិច្ច។

- **បណ្ណសម្គាល់ខ្លួនសារព័ត៌មានត្រូវបានចាប់ផ្ដើមអនុវត្ត**

នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក នេត្រ ភក្ត្រា បានប្រកាសដាក់ឱ្យប្រើប្រាស់នូវបណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានចេញដោយរដ្ឋាភិបាល ដើម្បីធានាបាននូវយថាភូត និងបង្ការកុំឱ្យមានការក្លែងបន្លំ ក្នុងគោលបំណងរក្សាឱ្យបាននូវកំណត់ត្រាអ្នកសារព័ត៌មាននៅកម្ពុជាឱ្យបានច្បាស់លាស់។ [46] នៅត្រឹមថ្ងៃទី២១ ខែវិច្ឆិកា អ្នកសារព័ត៌មានគឺតម្រូវជាចាំបាច់ឱ្យមានបណ្ណសម្គាល់ខ្លួនដែលរដ្ឋាភិបាលបានចេញ និងផ្ដល់ជាបណ្ណសម្គាល់ខ្លួន ហើយបណ្ណសម្គាល់ខ្លួនចេញដោយស្ថាប័នផ្សព្វផ្សាយលែងមានសុពលភាពតទៅទៀត។ [47]

សេចក្ដីពន្យល់ទូទៅ លេខ ៣៤ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បញ្ជាក់ថា សារព័ត៌មានរួមបញ្ចូលនូវតួអង្គចម្រុះគ្នាជាច្រើន ដែលរាប់ចាប់តាំងពីអ្នករាយការណ៍ពេញម៉ោងរហូតដល់អ្នកសរសេរអត្ថបទផ្សាយលើប្រព័ន្ធអ៊ីនធឺណិត។ [48] មាត្រា ៤៤ កត់សម្គាល់ថា ការចុះបញ្ជី ឬប្រព័ន្ធផ្ដល់អាជ្ញាបណ្ណទូទៅរបស់រដ្ឋសម្រាប់អ្នកសារព័ត៌មាន គឺមិនស្របគ្នាទៅនឹងមាត្រា ១៩(៣)នោះទេ ដែល"សេរីភាពខាងការបញ្ចេញមតិ អាចនឹងរងការដាក់កំហិត ប្រសិនបើដែនកំណត់ទាំងនោះអាចបង្ហាញថាចាំបាច់ដើម្បីរក្សាបាននូវ "ការគោរពសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ"។ [49] សេចក្ដីពន្យល់នេះ បញ្ជាក់ថាគម្រោងទទួលស្គាល់គុណវុឌ្ឍិមានកម្រិត គឺអាចទទួលយកបានតែសម្រាប់ការផ្ដល់សិទ្ធិចូលកន្លែង ឬកម្មវិធីជាក់លាក់ប៉ុណ្ណោះ ដូចជាមណ្ឌលបោះឆ្នោត និងចាំបាច់ត្រូវតែអនុវត្តដោយមិនមានការរើសអើង និងផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត។[50]

មានករណីជាច្រើនដែលបានរំលោភបំពានលើមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងគោលការណ៍ណែនាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ភ្នំពេញ បានរៀបចំសវនាការឧទ្ធរណ៍ជាលើកដំបូងសម្រាប់លោក កឹម សុខា ដែលបានចោទប្រកាន់ពីបទក្បត់ជាតិនៅថ្ងៃទី៣០ ខែមករា។ អ្នកសារព័ត៌មានមកពី វិទ្យុបារាំងអន្តរជាតិ ខេមបូចា និងវីអូអេ ត្រូវបានគេបដិសេធក្នុងការចូលរួម ទោះបីជាបានចុះឈ្មោះសម្រាប់គ្រប់សវនាការទាំងអស់ក៏ដោយ ដោយមន្ត្រីតុលាការបានលើកឡើងថាបរិវេណតូចចង្អៀត។ ការទាមទារ

[46]ខ្មែរថាមស៍ "លោក នេត្រ ភក្ត្រា៖ បណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានថ្មីមានកូដ QR ជួយទប់ស្កាត់ការក្លែងបន្លំ បានចេញជូនដល់អ្នកសារព័ត៌មានទាំងអស់" (ថ្ងៃ០៧ ខែមេសា ឆ្នាំ២០២៤)។ https://www.khmertimeskh.com/501468886/neth-pheaktra-a-new-form-of-journalist-identification-card-equipped-with-a-qr-code-to-prevent-forgery-being-issued-to-all-journalists/

[47]ហង្ស ពណ្ណរាយ "ក្រសួងព័ត៌មានតម្រូវឱ្យអ្នកសារព័ត៌មានប្រើប្រាស់បណ្ណសម្គាល់ខ្លួនសារព័ត៌មានផ្លូវការ" (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣)។

[48]គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "សេចក្ដីពន្យល់ លេខ ៣៤ មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញមតិ និងសម្ដែងមតិ"

[49]ដូចខាងលើ

[50]ដូចខាងលើ

ឱ្យមានការទទួលស្គាល់គុណវុឌ្ឍិសម្រាប់ព្រឹត្តិការណ៍មួយ គឺអនុញ្ញាតបាននៅក្រោម ក.អ.ស.ព.ន ដូចដែលបាន លើកឡើងពីខាងលើ ប៉ុន្តែការរើសអើងលើអ្នកសារព័ត៌មានរបស់វិទ្យុបារាំងអន្តរជាតិ សារព័ត៌មាន ខេមបូចា និង វីអូអេ ផ្ទុយគ្នាទៅនឹងមាត្រា ៤៤ នៃសេចក្ដីពន្យល់ទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[51]

ករណីមួយទៀត អត្ថបទព័ត៌មានមួយដែលបានចុះផ្សាយកាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែល រៀបរាប់លម្អិតអំពីអ្នកសារព័ត៌មាន វីអូអេ ដែលបានទាក់ទងលោក ប្លង់ សុផល អ្នកនាំពាក្យសាលាដំបូងរាជធានី ភ្នំពេញ ដើម្បីផ្ទៀងផ្ទាត់អំពីការឃុំខ្លួនអ្នកស្រី ណែវ ស៊ីអ៊ីម។ លោក សុផល បានទាមទារសុំមើលបណ្ណសម្គាល់ ខ្លួនអ្នកសារព័ត៌មាន ដោយបានលើកឡើងថា "អ្នកសារព័ត៌មាន វីអូអេ មិនមានបណ្ណសម្គាល់ខ្លួនសារព័ត៌មាន ហេតុដូច្នេះ ខ្ញុំសុំមិននិយាយជាមួយនោះទេ។" សូម្បីតែបន្ទាប់ពីបានបង្ហាញបណ្ណសម្គាល់ខ្លួនសារព័ត៌មានហើយ ក៏លោក សុផល នៅតែបដិសេធក្នុងការឆ្លើយសំណួរបន្តដែរ។[52]

## បញ្ហាប្រឈមនៅក្នុងការរាយការណ៍អំពីបញ្ហារសើប

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ ម.ស.ម.ក បានកត់ត្រាហេតុការណ៍ជាច្រើនដែលអាជ្ញាធរ ឬភាគីទីបី បានរឹតត្បិត ឬដាក់សម្ពាធលើអ្នកសារព័ត៌មាន ដោយមិនឱ្យរាយការណ៍អំពីប្រធានបទជាក់លាក់មួយ ចំនួន។

> អ្នកសារព័ត៌មានដែលរាយការណ៍អំពីទំនាស់ដីធ្លី ការបំផ្លិចបំផ្លាញបរិស្ថាន និងការកាប់ឈើខុសច្បាប់ នៅតែរងបញ្ហាប្រឈមដែលរួមមានការយាយីតាមរយៈផ្លូវច្បាប់និងរាងកាយ និងការបំភិតបំភ័យ។ ដូច គ្នានេះដែរពួកគេជួបប្រទះការលំបាកក្នុងការស្នើសុំព័ត៌មានពីអាជ្ញាធរ។

*<u>បញ្ហាដីធ្លី និងបរិស្ថាន៖</u>* ជម្លោះដីធ្លី ការបំផ្លាញបរិស្ថាន និងការកាប់ឈើខុសច្បាប់ ជាបញ្ហាចម្រូងចម្រាស នៅកម្ពុជា ជាយូរមកហើយ។ អង្គការអ្នករាយការណ៍គ្មានព្រំដែនបានកត់សម្គាល់ថា សារព័ត៌មានបរិស្ថានគឺ "គ្រោះថ្នាក់" នៅកម្ពុជា។[53] អ្នកសារព័ត៌មានដែលរាយការណ៍អំពីប្រធានបទទាំងនេះ ជារឿយៗ លាតត្រដាង អំពីអំពើពុករលួយ ឬការសមគំនិតគ្នារវាងមន្ត្រី និងអាជីវកម្មនានា ដែលធ្វើឱ្យពួកគេក្លាយទៅជាមុខសញ្ញានៃការ យាយី ការគំរាមកំហែង ឬថែមទាំងអំពើហិង្សាលើរាងកាយទៀតផង។

អ្នកសារព័ត៌មានបួននាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលបានស្ទង់មតិ បានលើកឡើងដោយផ្ទាល់ អំពីបញ្ហានេះ។ អ្នកសារព័ត៌មានទីមួយបានសង្កត់ធ្ងន់ថា ការសរសេរអំពីបញ្ហាដីធ្លី បង្កជាការគំរាមកំហែងដ៏ធំ ចំពោះអ្នកសារព័ត៌មាន។ អ្នកសារព័ត៌មានទីពីរបានកត់សម្គាល់អំពីបញ្ហាលំបាកក្នុងការស្នើសុំព័ត៌មានពីអាជ្ញាធរ

---

[51]ខេមបូចា "របាយការណ៍ប្រចាំត្រីមាស ខែមករា – ខែមីនា ឆ្នាំ២០២៤" (ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤)។ https://www.camboja.net/wp-content/uploads/2024/04/Quarterly-Report-Jan-Mar-2024-EN.pdf; ក្រុមប្រឹក្សាសិទ្ធិមនុស្ស"សេចក្ដីពន្យល់ លេខ ៣៤"

[52]Grow Lip Lip វីអូអេ "មន្ត្រីគណបក្សភ្លើងទៀន ត្រូវបានចោទប្រកាន់ពីបទញុះញង់" (ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣) https://khmer.voanews.com/a/an-opposition-candlelight-party-official-charged-with-incitement/7344915.html

[53]អង្គការអ្នករាយការណ៍គ្មានព្រំដែន "គេហទំព័រប្រចាំប្រទេស៖ កម្ពុជា" (សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ ចូលមើលថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤) https://tinyurl.com/69dvbfzs។

ជាពិសេស អំពីប្រធានបទរសើប ដូចជា បញ្ហាដីធ្លី និងព្រៃឈើ។ អ្នកសារព័ត៌មានទីបីបានបញ្ជាក់ថា ការទទួលបានទិន្នន័យអំពីការបំផ្លាញធនធានធម្មជាតិ និងការកាប់បំផ្លាញព្រៃឈើ គឺមានការរឹតត្បិតយ៉ាងខ្លាំង ដែលធ្វើឱ្យការងារស៊ើបអង្កេតមានការលំបាក។ ជាចុងក្រោយ អ្នកសារព័ត៌មានទីបួនបានសម្តែងអំពីការភ័យខ្លាចក្នុងការសរសេរករណីនានាពាក់ព័ន្ធនឹងការរឹបអូសដីសាធារណៈសម្រាប់ជាកម្មសិទ្ធិឯកជន ដោយគូសបញ្ជាក់អំពីគ្រោះថ្នាក់ពាក់ព័ន្ធនឹងការរាយការណ៍អំពីប្រធានបទនេះ។

ទិន្នន័យដែលបានប្រមូលនៅក្នុងរយៈពេលនៃសរសេររបាយការណ៍នេះ បានបង្ហាញថាការរាយការណ៍អំពីទំនាស់ដីធ្លី ការបំផ្លិចបំផ្លាញបរិស្ថាន និងការកាប់ឈើខុសច្បាប់នៅតែជាបញ្ហាប្រឈមដដែល។ ក្នុងហេតុការណ៍ដែលបានរៀបរាប់ខាងក្រោមនេះ អ្នកសារព័ត៌មានបានប្រឈមនឹងការជ្រៀតជ្រែកក្នុងការប្រមូលព័ត៌មាន ឬការសរសេរអំពីបញ្ហាពាក់ព័ន្ធនឹងដីធ្លី ឬការបំផ្លាញធនធានធម្មជាតិ។

***អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាដីធ្លី និងបរិស្ថាន បានប្រឈមនឹងការរឹតត្បិតជាច្រើនពីថ្ងៃទី០១ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤***

**ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣៖** លោក **ជុំ ពិសម័យ** អ្នកសារព័ត៌មានមកពី**សារព័ត៌មានកោះសន្តិភាព** បានទទួលរងការគំរាមពាក្យសម្តីពីសំណាក់អភិបាលស្រុកឯកភ្នំនៅខេត្តបាត់ដំបងថានឹងចាត់វិធានការផ្លូវច្បាប់ បន្ទាប់ពីរូបលោកបានរាយការណ៍អំពីការសាងសង់សំណង់ខុសច្បាប់ ដែលបំពុលទឹកស្ទឹងសង្កែ និងរិះគន់លោកអភិបាលចំពោះការអនុញ្ញាតឱ្យអាជីវកម្មនេះចាក់ដីបំពេញមួយផ្នែកនៃផ្លូវទឹកនេះ។ ក្រោយមកអាជ្ញាធរស្រុកបានបដិសេធលើការរាយការណ៍នេះនៅលើហ្វេសប៊ុក ដោយបានចាត់ទុកជាព័ត៌មានក្លែងក្លាយ និងបានជូនដំណឹងដល់លោក ពិសម័យ ថា អភិបាលកំពុងតែស្វែងរកភស្តុតាងដើម្បីប្តឹងលើរូបលោក។ លោកក៏បានទទួលការទាក់ទងផ្តល់ជាប្រាក់កាស ដើម្បីឱ្យរូបលោកលុបចោលអត្ថបទព័ត៌មាននេះដែរ តែលោកបានបដិសេធ។[54]

**ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣៖ លោក អ៊ាន គិមហឿន** អ្នករាយការណ៍មកពី **ទូរទស្សន៍ហង្សមាស** នៅខេត្តស្ទឹងត្រែង បានទទួលការណែនាំពីប្រធានមន្ទីរបរិស្ថានខេត្តឱ្យឈប់រាយការណ៍អំពីបញ្ហាដែលអាចប៉ះពាល់ដល់មុខមាត់របស់អាជ្ញាធរ។ ការណែនាំនេះកើតឡើងបន្ទាប់ពីលោក គិមហឿន បានរាយការណ៍អំពីការខកខានរបស់អាជ្ញាធរក្នុងការចាប់ខ្លួនឈ្មួញកាប់ឈើខុសច្បាប់នៅស្រុកបុរីអូរស្វាយសែនជ័យ។លោកត្រូវបានគេប្រាប់យ៉ាងច្បាស់ឱ្យលុបអត្ថបទព័ត៌មាននោះចេញពីគណនីហ្វេសប៊ុករបស់លោកបន្ទាប់ពីបានផ្សព្វផ្សាយ ប៉ុន្តែលោកបដិសេធក្នុងការធ្វើតាមការបង្គាប់នេះឡើយ។[55]

**ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣៖ លោក គិម ដែន** ចាងហ្វាងនៃសារព័ត៌មាន DN Peace News នៅខេត្តស្ទឹងត្រែង ត្រូវបាននគរបាលយោធាចាប់ខ្លួន និងបានដាក់ពន្ធនាគារពីបទទន្ទ្រានខុសច្បាប់លើដីរដ្ឋនៅឆ្នាំ២០១៥។ ទាំងកិរិយារបស់លោក ដែន និងចាងហ្វាងរងនៃសារព័ត៌មាន DN Peace News លោក សុវណ្ណ

[54] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែតុលា – ខែធ្នូ ឆ្នាំ២០២៣)" (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ទំព័រ ១២ https://tinyurl.com/3v7eauxy។
[55] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែតុលា – ខែធ្នូ ឆ្នាំ២០២៣)" (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ទំព័រ ១១ https://tinyurl.com/3v7eauxy។

ដារ៉ាវុធ បានបញ្ជាក់ថា លោក ដែន បានកាប់ឆ្ការដីនេះនៅឆ្នាំ២០១៥ ប៉ុន្តែបានប្រគល់ទៅឱ្យរដ្ឋវិញនៅឆ្នាំដដែល។ លោកក៏បានសង្កត់ធ្ងន់ផងដែរថា លោក ដែន កាលពីពេលថ្មីៗនោះបានរាយការណ៍អំពីការកាប់ឈើខុសច្បាប់នៅក្នុងខេត្ត។[56]

**ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤៖** ចាងហ្វាងនៃសារព័ត៌មាន New Network News ត្រូវបានអ្នកតំណាងក្រុមហ៊ុន Eastern Rubber (Cambodia) Co. Ltd. ប្ដឹងពីបទបរិហាកេរ្តិ៍ បន្ទាប់ពីរាយការណ៍អំពីទំនាស់ដីធ្លីមួយនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ អ្នកតំណាងបានចោទប្រកាន់អ្នកសារព័ត៌មានពីបទចែកចាយព័ត៌មានមិនពិត និងទាមទារសំណងជំងឺចិត្តចំនួន $១០.០០០។ ចលនានេះកើតឡើងបន្ទាប់ពីមានការរាយការណ៍ផ្សាយផ្ទាល់នៅលើបណ្ដាញហ្វេសប៊ុក ដែលលើកឡើងអំពីការតវ៉ាប្រឆាំងនឹងការឈូសឆាយដីនៅក្នុងតំបន់នោះ។ ក្រោយមក ក្រុមហ៊ុនបានយល់ព្រមសងសំណងដល់គ្រួសារដែលរងផលប៉ះពាល់។ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា បានបញ្ជាក់ថា អ្នកតំណាងបានដាក់សម្ពាធឱ្យអ្នកភូមិលក់ដីរបស់ខ្លួន និងបញ្ជាក់ថាអ្នកភូមិបីនាក់ផ្សេងទៀតក៏រងបណ្ដឹងផងដែរ។[57]

**ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤៖** អ្នករាយការណ៍អនឡាញចំនួនបីអ្នកមកពីសារព័ត៌មាន សាន ព្រំ ត្រូវបាននគរបាលឃុំខ្លួនរយៈពេល ១០ ម៉ោង បន្ទាប់ពីសម្ភាសន៍គ្រួសារដែលពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លីនៅខេត្តព្រះសីហនុ។ បន្ទាប់ពីការសម្ភាសន៍នេះ នគរបាលស្រុកក៏បានមកដល់ បិទផ្លូវ និងណែនាំអ្នករាយការណ៍ឱ្យទៅប៉ុស្តិ៍នគរបាលដើម្បីសាកសួរព័ត៌មានបន្ថែម។ នៅពេលមកដល់ អ្នករាយការណ៍ត្រូវបានគេឃុំខ្លួនដើម្បីសួរចម្លើយចាប់ពីម៉ោង ១០:៣០ នាទីព្រឹក រហូតដល់ម៉ោង ៨ យប់។ ក្នុងអំឡុងពេលឃុំខ្លួននេះ នគរបាលបានថតរូប និងបង្ខំឱ្យពួកគេចុះហត្ថលេខានៅលើឯកសារដែលយល់ព្រមមិនចុះផ្សាយអត្ថបទព័ត៌មានរបស់ពួកគេ នៅក្រោមការគំរាមកំហែងចាត់វិធានការផ្លូវច្បាប់។ នគរបាលក៏បានអះអាងថា អ្នកសារព័ត៌មាននៅរាជធានីភ្នំពេញ មិនមានសិទ្ធិមកយកព័ត៌មាននៅក្នុងខេត្តនោះទេ។ នៅថ្ងៃបន្ទាប់ រូបថតរបស់អ្នកសារព័ត៌មានត្រូវបានចែករំលែកជាសាធារណៈនៅលើតេលេក្រាម និងហ្វេសប៊ុក។ អ្នកសារព័ត៌មានបានថ្កោលទោសចំពោះអំពើបែបនេះ ដោយលើកឡើងថាការធ្វើបែបនេះគឺរំលោភបំពានលើសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ។ ពួកគេបានដាក់ពាក្យបណ្ដឹងនៅក្រសួងព័ត៌មាន ប៉ុន្តែមិនបានទទួលដំណឹងអ្វីអំពីចំណាត់ការនោះទេ។[58]

**ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤៖** មន្ត្រីនៅខេត្តមណ្ឌលគិរី បានកោះហៅអ្នកសារព័ត៌មានពីររូបមកពីសារព័ត៌មាន BPNC News និង **សារព័ត៌មានដើមក្រសាំង** ដើម្បីធ្វើការសាកសួរពាក់ព័ន្ធនឹងអត្ថបទព័ត៌មានស្ដីពីការកាប់ឈើខុសច្បាប់នៅស្រុកកែវសីមា។ ដីកាកោះហៅ ដែលចេញដោយការិយាល័យរដ្ឋបាលស្រុកកែវសីមា បានស្នើសុំឱ្យអ្នកសារព័ត៌មាន ដែលមានទីលំនៅក្នុងខេត្តព្រៃវែង ឱ្យបង្ហាញខ្លួននៅថ្ងៃទី២៨ ខែកុម្ភៈ

[56]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែតុលា – ខែធ្នូ ឆ្នាំ២០២៣)" (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ទំព័រ ៨ https://tinyurl.com/3v7eauxy។

[57]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១៦ https://tinyurl.com/3v7eauxy។

[58] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១៤ https://tinyurl.com/3v7eauxy។

ឆ្នាំ២០២៤។ អ្នកសារព័ត៌មានបានធ្វើដំណើរទៅខេត្តមណ្ឌលគិរីនៅថ្ងៃទី២៧ ខែកុម្ភៈ តែត្រូវបានគេប្រាប់ថា កិច្ចប្រជុំនេះត្រូវបានផ្អាកដោយមិនមានការពន្យល់បកស្រាយអ្វីសោះ។ អត្ថបទព័ត៌មានស្ដីពីការកាប់ឈើខុសច្បាប់ បានសរសេរដំបូងដោយអ្នកសារព័ត៌មានមកពី សារព័ត៌មានដើមក្រសាំង និងចុះផ្សាយដោយសារព័ត៌មាន BPNC News នៅថ្ងៃទី២៤ ខែកុម្ភៈ។ ទោះជាយ៉ាងនេះក្ដី ក្រោយមកអត្ថបទនេះត្រូវបានលុបចេញដោយសារតែបញ្ហាទីតាំង។ ទោះបីជាលុបចេញក៏ដោយ ក៏អ្នកសារព័ត៌មានបានទទួលដីកាកោះហៅមួយនៅថ្ងៃទី២៦ ខែកុម្ភៈ ឱ្យផ្ដល់សេចក្ដីបំភ្លឺផងដែរ។[59]

**<u>ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤៖</u>** អ្នកសារព័ត៌មានឯករាជ្យម្នាក់មកពី **វិទ្យុសហគមន៍ស្ត្រី**នៅក្នុងខេត្តក្រចេះ ត្រូវបានតុលាការខេត្តកោះហៅមកសាកសួរ បន្ទាប់ពីការរាយការណ៍អំពីការតវ៉ាពាក់ព័ន្ធនឹងជនជាតិដើមភាគតិចនៅក្នុងស្រុកអូរគ្រៀងសែនជ័យ។ ការតវ៉ានេះ បានធ្វើឡើងនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ បាននាំឱ្យមានការដុតស្នាក់ការបរិស្ថានមួយនៅក្នុងឃុំស្រែជិះ។ អ្នកសារព័ត៌មាន ដែលជាជនជាតិដើមភាគតិចដែរនោះ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តហិង្សាលើអាផ្ទាធរ។ កាលពីមុន លោកធ្លាប់បានក្រសួងបរិស្ថាននៅរាជធានីភ្នំពេញសាកសួរម្ដងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។ អ្នកសារព័ត៌មានរូបនេះបានប្រាប់សារព័ត៌មាន ខេមបូចា ថានៅពេលកំពុងផ្សព្វផ្សាយការតវ៉ានោះ លោកបានពាក់បណ្ណសម្គាល់ខ្លួនសារព័ត៌មាន ថតរូប និងវីដេអូ និងបានសម្ភាសទាំងជាមួយអ្នកតវ៉ា និងអាជ្ញាធរនៅទីតាំងកើតហេតុផ្ទាល់។[60]

**<u>ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤៖</u>** ស្ថាប័នផ្សព្វផ្សាយអនឡាញចំនួនបួន—**ផល្លី ញូវ**, BSN, Ray Phon និង UKK News—ត្រូវបានអាជ្ញាធរមូលដ្ឋានក្នុងខេត្តពោធិ៍សាត់ ប្ដឹងពីបទបរិហារកេរ្តិ៍ និងញុះញង់ឱ្យមានការរើសអើង។ បណ្ដឹងនេះត្រូវបានដាក់បន្ទាប់ពីពួកគេបានរាយការណ៍អំពីការឈូសឆាយដីខុសច្បាប់នៅក្នុងតំបន់អភិរក្សសត្វព្រៃភ្នំសំកុស ដោយបានចុះផ្សាយអត្ថបទព័ត៌មាន និងវីដេអូតាំងពីខែកុម្ភៈ។[61] នៅថ្ងៃទី២២ ខែកុម្ភៈ មន្ទីរបរិស្ថានខេត្ត ធ្លាប់បានបដិសេធម្ដងរួចមកហើយចំពោះការអះអាងនេះ និងទាមទារឱ្យធ្វើការកែតម្រូវឡើងវិញ។ នៅថ្ងៃទី២៩ ខែឧសភា សារព័ត៌មាន ផល្លី ញូវ បានចេញសេចក្ដីបំភ្លឺដោយការពារការរាយការណ៍របស់ខ្លួន ប៉ុន្តែបានសម្ដែងអំពីឆន្ទៈក្នុងការកែតម្រូវសាច់រឿង ដើម្បីចៀសវាងការបាត់បង់អាជ្ញាបណ្ណរបស់ខ្លួន។ ចុងក្រោយ អ្នកសារព័ត៌មានរបស់សារព័ត៌មាន Ray Phon ត្រូវបានកោះហៅមកសាកសួរនៅថ្ងៃទី១១ ខែមិថុនា។[62]

---

[59]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១២ https://tinyurl.com/3v7eauxy។

[60]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ២៣ https://tinyurl.com/3v7eauxy។

[61] ឃ្លាំមើលសេរីភាពសារព័ត៌មាននៅផ្នែកអាស៊ីអាគ្នេយ៍៖ អ្នកសារព័ត៌មានត្រូវបានគេប្ដឹងបរិហារកេរ្តិ៍ និងញុះញង់ដោយសារការរាយការណ៍កាប់បំផ្លាញព្រៃឈើនៅខេត្តពោធិ៍សាត់(ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤) https://pfmsea.org/journalists-sued-defamation-and-incitement-reporting-land-clearing-pursat

[62]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា –ខែមិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤) ទំព័រ ១២ និង ១៣ https://tinyurl.com/3v7eauxy។

*អំពើពុករលួយ៖* អ្នកចូលរួមខ្លះនៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅជាមួយនឹងអ្នកសារព័ត៌មានបានលើកឡើងថា ពួកគេមិនហ៊ានសរសេរអំពីអំពើពុករលួយនោះទេ ដោយបញ្ជាក់ថាប្រធានបទនេះគឺប្រថុយប្រថានពេកហើយ។ លើសពីនេះ អ្នកសារព័ត៌មានពីរនាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលបានស្ទង់មតិ បានលើកឡើងថាពួកគេបានបដិសេធក្នុងការសរសេរអត្ថបទអំពីបញ្ហានេះឡើយ ស្របពេលដែលអ្នកសារព័ត៌មានមួយរូបទៀតបានលើកឡើងថាអ្នកដែលសរសេរពីបញ្ហានេះ គឺប្រឈមនឹងការគំរាមកំហែងយ៉ាងខ្លាំង។ ក្នុងន័យដូចគ្នានេះដែរ អង្គការអ្នករាយការណ៍គ្មានព្រំដែន កត់សម្គាល់ថា "ការផ្សព្វផ្សាយករណីអំពើពុករលួយដែលមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងនាយករដ្ឋមន្ត្រី ឬអ្នកជំនិតរបស់លោក គឺមិនអាចបានឡើយ។"[63]

ទិន្នន័យដែលបានប្រមូលក្នុងអំឡុងពេលនៃរបាយការណ៍បង្ហាញថា អាជ្ញាធរ និងបុគ្គលកាន់អំណាចបន្តតបតលើអ្នកសារព័ត៌មានដែលបកអាក្រាតអំពីពុករលួយ ដោយធ្វើឱ្យពួកគេប្រឈមនឹងការបាត់បង់ការងារ។ ប្រការនេះសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់តាមរយៈការដកហូតអាជ្ញាបណ្ណរបស់សារព័ត៌មានជីវិត និងកីឡា បន្ទាប់ពីសារព័ត៌មាននេះបានរាយការណ៍អំពីអំពើពុករលួយដែលជាប់ពាក់ព័ន្ធនឹងប្រធានមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង (សូមមើលទំព័រ ២៦) ក៏ដូចជាការថ្កោលទោសទៅលើចាងហ្វាងនៃសារព័ត៌មាន ខ្មែរដោយដែន ពីការរាយការណ៍អំពីអំពើពុករលួយនៅក្នុងមន្ទីរសុខាភិបាល និងសាខាពន្ធដារខេត្តបន្ទាយមានជ័យផងដែរ។ ខាងក្រោមនេះគឺជាករណីមួយទៀតដែលបញ្ជាក់អំពីការប្រឈមមុខនឹងវិធានការផ្លូវច្បាប់ពីសំណាក់អ្នកសារព័ត៌មានដែលរាយការណ៍អំពើពុករលួយ ឬជំរិតទារប្រាក់ដែលប្រព្រឹត្តដោយមន្ត្រី។

**អ្នកសារព័ត៌មាន HPN NEWS** – នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ តុលាការខេត្តមណ្ឌលគិរី បានសួរចម្លើយអ្នកសារព័ត៌មានមិនបញ្ចេញឈ្មោះមួយរូបមកពីសារព័ត៌មាន HPN News បន្ទាប់ពីការចុះផ្សាយអត្ថបទព័ត៌មានមួយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ដែលអះអាងថាអាជ្ញាធរមូលដ្ឋានគិតកម្រៃពីអ្នកភូមិម្នាក់ ៥០.០០០ រៀល ($១២,៥០) ដើម្បីចូលទៅក្នុងឧទ្យានជាតិវីរជ័យដើម្បីបេះផ្លែឈើព្រៃ។ បន្ទាប់ពីអត្ថបទព័ត៌មានបានចុះផ្សាយ តុលាការបានចេញដីកាកោះហៅនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ ដោយទាមទារឱ្យអ្នកសារព័ត៌មានចូលមកបង្ហាញខ្លួនដើម្បីសួរចម្លើយ។ មានគេរាយការណ៍ថា តុលាការបានឱ្យអ្នកសារព័ត៌មានធ្វើជាសហដើមបណ្ដឹង ដើម្បីជួយក្នុងការស៊ើបអង្កេត និងផ្ដល់ភស្តុតាងគាំទ្រដល់ការចោទប្រកាន់នោះ។ អ្នកសារព័ត៌មាន ដែលបានបង្ហាញបង្កាន់ដៃដែលចេញទៅឱ្យប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានជាភស្តុតាង បានលើកឡើងថា ដីកាកោះហៅនេះគឺជាការប៉ុនប៉ងបំភិតបំភ័យ និងបង្ក្រាបសេរីភាពសារព័ត៌មាន ដោយនិយាយថា តុលាការគួរតែកោះហៅមន្ត្រីដែលពាក់ព័ន្ធមកសួរចម្លើយ ជាជាងដៅមុខសញ្ញាលើអ្នកសារព័ត៌មាន។[64]

<u>សកម្មភាពខុសច្បាប់៖</u> ក្នុងអំឡុងពេលនៃរបាយការណ៍ ម.ស.ម.ក បានកត់ត្រាករណីដែលអ្នកសារព័ត៌មានប្រឈមនឹងការរឹតត្បិតជាខ្លាំងនៅពេលធ្វើការស៊ើបអង្កេត ឬរាយការណ៍សកម្មភាពខុសច្បាប់។ ការ

---

[63] អង្គការអ្នករាយការណ៍គ្មានព្រំដែន "គេហទំព័រប្រចាំប្រទេស៖ កម្ពុជា" (សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ ចូលមើលថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤) https://tinyurl.com/69dvbfzs។

[64] ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្ដីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា – ខែមិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០២៤) ទំព័រ ១៧ https://tinyurl.com/3v7eauxy។

រឹតត្បិតទាំងនេះ អាចកើតចេញពីអាជ្ញាធរមូលដ្ឋាន ឬកងកម្លាំងសន្តិសុខដែលចង់គេចវេសពីការបំពេញកិច្ចការមិនមានប្រសិទ្ធភាពនៅក្នុងការដោះស្រាយបញ្ហានេះ ឬអាចមកពីការសមគំនិតគ្នាជាមួយនឹងអ្នកដែលពាក់ព័ន្ធនៅក្នុងសកម្មភាពខុសច្បាប់ទៀតផង។

**ថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤៖** អ្នកសារព័ត៌មានម្នាក់មកពីសារព័ត៌មាន Luos Seng News ត្រូវបាននគរបាលព្រំដែនចាប់ខ្លួនដោយសាររាយការណ៍អំពីការជួញដូរទំនិញខុសច្បាប់រវាងកម្ពុជា និងវៀតណាមនៅប្រកត្រួតពិនិត្យព្រំដែនបាវិត ខេត្តស្វាយរៀង។ នគរបាលប្រាំមួយនាក់បានទាមទារឱ្យលោកបង្ហាញអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ និងលិខិតអនុញ្ញាតពីមន្ទីរព័ត៌មានខេត្ត មុនពេលណែនាំលោកឱ្យចាកចេញ ដោយនិយាយថា អ្នកសារព័ត៌មានមិនអនុញ្ញាតឱ្យរាយការណ៍ពីតំបន់នេះទេ។[65]

**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤៖** និពន្ធនាយកនៃសារព័ត៌មាន Penh Chet Media ត្រូវបានក្រុមហ៊ុនឯកជនមួយនៅក្នុងខេត្តតាកែវប្ដឹង បន្ទាប់ពីរាយការណ៍អំពីករណីសង្ស័យវេចខ្ចប់បារីខុសច្បាប់នៅរោងចក្រមួយនៅក្នុងស្រុកបាទី។ ទោះបីជាអ្នកសារព័ត៌មានបានចុះទៅដល់ទីតាំងផ្ទាល់នៅថ្ងៃទី២៧ ខែកុម្ភៈ និងរកមិនឃើញភស្តុតាងពាក់ព័ន្ធផ្ទាល់ទៅនឹងសកម្មភាពខុសច្បាប់ក៏ដោយ ក៏លោកសម្រេចចិត្តចុះផ្សាយរបាយការណ៍នេះដោយផ្អែកលើប្រភពទុកចិត្ត ដោយសង្ឃឹមថារបាយការណ៍នេះនឹងជំរុញឱ្យអាជ្ញាធរធ្វើការស៊ើបអង្កេត។ ការចុះផ្សាយនេះនាំឱ្យមានការដាក់បណ្ដឹងពីសំណាក់ប្រធានសន្តិសុខរបស់រោងចក្រដែលបានអះអាងថាអត្ថបទព័ត៌មាននេះបានធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន។ នៅថ្ងៃទី២៩ ខែកុម្ភៈ រដ្ឋបាលស្រុកបាទីបានចេញសេចក្តីថ្លែងការណ៍ច្រានចោលអត្ថបទព័ត៌មាននេះថាមិនមានមូលដ្ឋាន ដោយលើកឡើងថាអត្ថបទព័ត៌មាននេះធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អាជ្ញាធរ និងក្រុមហ៊ុន។ ជាចុងក្រោយ អ្នកសារព័ត៌មានបានលុបចោលអត្ថបទព័ត៌មាននេះ បន្ទាប់ពីមានការស្នើសុំពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ដែលបានបញ្ចប់វិវាទផ្លូវច្បាប់នេះ។[66]

## ការដាក់កំហិតខ្លួនឯង

យោងតាមហេតុការណ៍ដូចបានគូសបញ្ជាក់នៅក្នុងជំពូកនេះបង្ហាញថា អ្នកសារព័ត៌មានមិនមានសេរីភាពក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីបញ្ហាដែលអាជ្ញាធរកំណត់ថាមានលក្ខណៈរសើប។ ជាលទ្ធផលនៃការបំភិតបំភ័យ ការគំរាមកំហែង និងការផ្តន្ទាទោស ដែលអ្នកសារព័ត៌មានទទួលរងដោយគ្រាន់តែបំពេញការងាររបស់ខ្លួន អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានដាក់កំហិតខ្លួនឯង និងជៀសវាងការផ្សាយព័ត៌មានដែលអាចធ្វើឱ្យក្រុមឥស្សរជនដែលកំពុងកាន់អំណាចខឹងសម្បា។ ការដាក់កំហិតខ្លួនឯង គឺដាក់កម្រិតទៅលើវិសាលភាព និងភាពស៊ីជម្រៅនៃការរាយការណ៍ ដែលអ្នកសារព័ត៌មានត្រូវតែវាយតម្លៃជាប្រចាំចំពោះផលវិបាកដែលអាចកើតឡើងពីការងាររបស់ខ្លួន។

---

[65]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១៧ https://tinyurl.com/3v7eauxy។

[66]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – ខែមីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ១០ https://tinyurl.com/3v7eauxy។

ក្នុងចំណោមអ្នកសារព័ត៌មានដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ អ្នកសារព័ត៌មានចំនួន ១១នាក់ បានរាយការណ៍ថា ពួកគេដាក់កំហិតលើខ្លួនឯង ឬបានដាក់កំហិតលើខ្លួនឯងក្នុងអំឡុងពេលនៃរបាយការណ៍។ ប្រធានបទរសើបដែលអ្នកផ្តល់សម្ភាសន៍បានលើកឡើងថាពួកគេបដិសេធក្នុងការរាយការណ៍ ដោយសារតែខ្លាចផលប៉ះពាល់រួមមាន នយោបាយ (៧នាក់បានលើកឡើង) សន្តិសុខជាតិ (៤នាក់) តុលាការ (៣នាក់) វិធានការរដ្ឋាភិបាល (២នាក់) អំពើពុករលួយ (២នាក់) វិធានការដីធ្លី បញ្ហាព្រំដែន គោលនយោបាយបរទេស និងបញ្ហាសង្គម "ក្តៅៗ" (១នាក់រាយការណ៍លើប្រធានបទនីមួយៗ)។ អ្នកសារព័ត៌មានបានលើកឡើងថាពួកគេខ្លាចនឹងការសរសេរអំពីបញ្ហានយោបាយពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ដោយសារតែការគំរាមកំហែង និងបណ្តឹង។ អ្នកសារព័ត៌មានមួយរូបទៀតបានលើកឡើងថា ពួកគេមិនដែលសរសេរអត្ថបទស៊ើបអង្កេតអំពីនយោបាយនោះទេ ដោយសារតែអត្ថបទបែបនេះអាចបង្កគ្រោះថ្នាក់ដល់ពួកគេផ្ទាល់ គ្រួសារ និងមនុស្សនៅជុំវិញខ្លួនពួកគេ។ ដូចគ្នានេះដែរ អ្នកចូលរួមមួយចំនួននៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកសារព័ត៌មាន បានសម្តែងអំពីការស្ទាក់ស្ទើរក្នុងការសរសេរអំពីអំពើពុករលួយ និងនយោបាយ ដោយសារតែហានិភ័យដែលពាក់ព័ន្ធនឹងប្រធានបទទាំងនេះ។ អ្នកសារព័ត៌មានផ្សេងទៀតបានបង្ហាញថា ទោះបីជាពួកគេអាចនឹងស្ម័គ្រចិត្តសរសេរប្រធានបទរសើបក្តី ក៏ពួកគេនឹងមិនដាក់ឈ្មោះខ្លួនឯងនៅក្នុងអត្ថបទព័ត៌មាននោះដែរ។

ការភ័យខ្លាចពីការតបត នាំឱ្យមានការដាក់កំហិតលើខ្លួនឯងទាំងក្នុងចំណោមអ្នកសារព័ត៌មាន និងសាធារណៈជននៅកម្ពុជា ដែលរារាំងដល់ការរាយការណ៍បែបស៊ើបអង្កេត។ ប្រភពនានា រួមទាំងជនរងគ្រោះដែលរងភាពអយុត្តិធម៌ និងកម្មកររោងចក្រ គឺស្ទាក់ស្ទើរក្នុងការជជែកជាមួយអ្នកសារព័ត៌មាន ដោយភ័យខ្លាចការរងគ្រោះបន្ថែមទៀត។ ប្រការនេះរារាំងដល់ការរាយការណ៍លម្អិតអំពីប្រធានបទរសើប និងរារាំងដល់ដំណោះស្រាយ ដែលនាំឱ្យបញ្ហាសំខាន់ៗត្រូវបានទុកចោលមិនបានដោះស្រាយ។ វិធានការផ្លូវច្បាប់ទៅលើបុគ្គលគណបក្សជំទាស់ និងសកម្មជនចំពោះសេចក្តីថ្លែងការណ៍លើប្រព័ន្ធផ្សព្វផ្សាយ បង្កើតបានជាឥទ្ធិពលភ័យខ្លាច ធ្វើឱ្យមានការដាក់កំហិតខ្លួនឯង និងភ័យខ្លាចកាន់តែខ្លាំង។ ប្រការនេះបង្អាក់ទឹកចិត្តបុគ្គលនានាមិនឱ្យចែករំលែកព័ត៌មានជាមួយនឹងអ្នកសារព័ត៌មាន ដែលគាបសង្កត់ទៅលើការផ្សព្វផ្សាយសំខាន់ៗ។ ខាងក្រោមនេះផ្តល់នូវឧទាហរណ៍មួយចំនួនអំពីករណីទាំងនេះ៖

**លោក ស៊ឹង សែនករុណា៖** នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ គណបក្សប្រជាជនកម្ពុជាបានដាក់បណ្តឹងប្រឆាំងលោក ស៊ឹង សែនករុណា ជាអ្នកស៊ើបអង្កេតសិទ្ធិមនុស្សជាន់ខ្ពស់នៃសមាគមអាដហុកភ្លាមៗ បន្ទាប់ពីសារព័ត៌មាន ខេមបូឌាដេលី បានស្រង់សម្តីរបស់លោក ដែលនិយាយថា គណបក្សកាន់អំណាចប្រើប្រាស់តុលាការជានិច្ច ដើម្បីបង្ក្រាបមន្ត្រីគណបក្សជំទាស់។ មេធាវីរបស់គណបក្សប្រជាជនកម្ពុជា បានអះអាងថា សេចក្តីថ្លែងការណ៍ទាំងនេះគឺមានបំណងបន្ទោស បង្កាច់បង្ខូច និងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះរបស់គណបក្ស ក៏ដូចជាមានចេតនាដាក់ឥទ្ធិពលទៅលើលទ្ធផលនៃការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី ៥ ផងដែរ។ ពួកគេបានឱ្យសាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោស លោក សែនករុណា នៅក្រោមច្បាប់ និង

បានទាមទារសំណងចំនួនពីរពាន់លានរៀល។[67] ចុងក្រោយ លោក សែនករុណា បានលាលែងពីតំណែងរបស់លោកនៅសមាគមអាដហុក និងបានទៅប្រទេសអូស្ត្រាលីជាមួយគ្រួសាររបស់លោកនៅចុងខែមេសា ឆ្នាំ២០២៤ ដើម្បីស្វែងរកសិទ្ធិជ្រកកោននយោបាយ។[68]

**លោក ហ៊ាម គឹមហុង៖** នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ អាជ្ញាធរមួយចំនួននៅក្នុងស្រុកឆែប ខេត្តព្រះវិហារ បានណែនាំឱ្យលោក ហ៊ាម គឹមហុង ជាសមាជិកគណៈកម្មាធិការព្រៃឈើសហគមន៍សង្កែ ចុះហត្ថលេខាលើកិច្ចសន្យានៅប៉ុស្តិ៍នគរបាលមូលដ្ឋាន។ ឯកសារនេះតម្រូវឱ្យលោកទទួលយកការស្តីបន្ទោសពីការនិយាយជាមួយនឹងអ្នកសារព័ត៌មានកាលពីមុន និងបញ្ឈប់ផ្តល់បទសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត និងសកម្មភាពនានាដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ថ្នាក់ដឹកនាំ បើមិនដូច្នេះទេអាចឈានទៅរកការចាត់វិធានការតាមផ្លូវច្បាប់។ បញ្ហាដែលឈានដល់កម្រិតនេះ បានកើតឡើងបន្ទាប់ពីបទសម្ភាសន៍ជាមួយ វិទ្យុអាស៊ីសេរី ដែលលោក គឹមហុង បានពិភាក្សាអំពីផលប៉ះពាល់បរិស្ថាន និងកសិកម្មនៃសកម្មភាពជីករ៉ែដែករបស់ក្រុមហ៊ុន Global Green (Cambodia) Energy Development មកលើប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារ និងស្ទឹងត្រែង។[69]

**លោក យុន ថារ៉ូ៖** នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ សហភាពសហជីពការពារសិទ្ធិកម្មករកម្ពុជា (CWPUC) បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោក យុន ថារ៉ូ ប្រធានកម្មវិធីនៅមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (អង្គការ សង់ត្រាល់) ដោយទាមទារសំណង ១០០ លានរៀល ពីបទបរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង។ ការចោទប្រកាន់ទាំងនេះ កើតចេញពីបទសម្ភាសន៍មួយជាមួយវិទ្យុអាស៊ីសេរី នៅថ្ងៃទី១៥ ខែមិថុនា ដែលក្នុងពេលនោះ លោក ថារ៉ូ ត្រូវបានគេចោទប្រកាន់ថារិះគន់ការប្រើប្រាស់សហជីព "ក្លែងក្លាយ" ក្រុមយុវជន ឬក្រុមសង្គមស៊ីវិល ដើម្បីធ្វើឱ្យខូចខាតដល់សហជីព អង្គការយុវជន និងអង្គការសង្គមស៊ីវិល "ឯករាជ្យ" ។ សហភាពសហជីពការពារសិទ្ធិកម្មករកម្ពុជា បានលើកឡើងថា សេចក្តីថ្លែងការណ៍នេះ គឺជា "ការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរដោយមិនមានមូលដ្ឋានច្បាប់ច្បាស់លាស់ និងរំលោភលើសិទ្ធិ សេរីភាព និងសេចក្តីថ្លៃថ្នូរ" របស់សហជីពវិជ្ជាជីវៈ។[70] នៅថ្ងៃទី៨ ខែកក្កដា លោក ហង្ស រ៉ាវី ប្រធានសហភាពសហជីពការពារសិទ្ធិកម្មករកម្ពុជា បានដាក់ពាក្យបណ្តឹងលើកទីពីរប្រឆាំងទៅនឹងលោក យុន ថារ៉ូ លើករណីដដែល ដោយលើកនេះទាមទារសំណងមួយរយលានរៀល។[71]

---

[67]សុទ្ធ គឹមសឿន "មេធាវីរបស់គណបក្សប្រជាជនកម្ពុជាប្តឹងលោក សែនករុណា ពីបទប្រមាថគណបក្ស" (*ខ្មែរថាមស៍* ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤)។

[68]ប៊ុត រស្មីគង្គា "តុលាការស៊ើបសួរលោក សែនករុណា ពីបទប្រមាថ" (*ខ្មែរថាមស៍* ៣ ខែឧសភា ឆ្នាំ២០២៤)។

[69]អាន វិចិត្រ "មន្ត្រីស្រុកឆែបតម្រូវឱ្យប្រជាពលរដ្ឋស្នើសុំការអនុញ្ញាតមុនពេលនិយាយជាមួយអ្នកសារព័ត៌មាន" [ភាសាខ្មែរ] (*សារព័ត៌មាន ខេមបូចា*, ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤) Lors Liblib "អាជ្ញាធរហាមឃាត់សកម្មជនព្រៃឈើនៅក្នុងខេត្តព្រះវិហារ មិនឱ្យផ្តល់បទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី" [ភាសាខ្មែរ] (*វីអូអេ* ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤)។

[70]ឃួន ណារីម តាំង ប៉ហ្គិច និងលី រ៉ូសឡែន "របាយការណ៍នេះគឺដើម្បីធ្វើឱ្យលក្ខខណ្ឌកម្មករនិយោជិតល្អប្រសើរ សេចក្តីបំភ្លឺរបស់អង្គការ សង់ត្រាល់ ការស៊ើបអង្កេតរបស់ក្រសួងមហាផ្ទៃ" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤)

[71]លី រ៉ូសឡែន "អង្គការ សង់ត្រាល់ ការធ្វើសវនកម្មលើអង្គការសង់ត្រាល់ ខណៈអង្គការអន្តរជាតិ ជំរុញឱ្យរដ្ឋាភិបាលលុបចោលការអនុវត្តនេះ" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

**លោក ទាវ វណ្ណុល៖** នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ សាលាដំបូងរាជធានីភ្នំពេញបានរកឃើញថា ប្រធានគណបក្សភ្លើងទៀន ជាប់ពិរុទ្ធពីបទបរិហាកេរ្តិ៍ជាសាធារណៈ។ ការចោទប្រកាន់នេះកើតចេញពីមតិយោបល់របស់លោក ដែលបានផ្តល់ឱ្យស្ថាប័នផ្សព្វផ្សាយជប៉ុន Nikkei Asia នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលនៅក្នុងនោះលោកបានរិះគន់ដល់ការដើរថយក្រោយនៃប្រជាធិបតេយ្យនៅក្រោមរបបដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត និងបានអះអាងថា អាជ្ញាធរគឺកំពុងតែឃ្លាំមើលថ្នាក់ដឹកនាំគណបក្សភ្លើងទៀន។ លោក វណ្ណុល ត្រូវបានតុលាការបង្គាប់ឱ្យសងជំងឺចិត្តចំនួន ៦ពាន់លានរៀលទៅឱ្យរដ្ឋាភិបាល និងពិន័យជាប្រាក់ចំនួន ១០ លានរៀលផងដែរ។[72]

## អំពើហិង្សាលើរូបរាងកាយ និងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតលើអ្នកសារព័ត៌មាន

អ្នកសារព័ត៌មាននៅកម្ពុជា ជាពិសេសអ្នកដែលដើរតួនាទីជាអ្នកឃ្លាំមើល និងជាអ្នករាយការណ៍ព័ត៌មានជាសម្ងាត់ ជារឿយៗប្រឈមនឹងការគំរាមកំហែងដល់សុវត្ថិភាពរូបរាងកាយរបស់ពួកគេ។ នៅក្នុងករណីខ្លះ ការគំរាមកំហែងទាំងនេះវិវត្តទៅរកកម្រិតគួរឱ្យព្រួយបារម្ភ ដោយមានអ្នកសារព័ត៌មានម្នាក់ដែលបានស្ទង់មតិបានទាំងលើកឡើងអំពីការគំរាមសម្លាប់ទៀតផង។

តាមរយៈគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក បានបង្ហាញឱ្យឃើញថា ការវាយប្រហារលើរូបរាងកាយរបស់បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ នៅតែបន្តកើតឡើងក្នុងអំឡុងពេលនៃរបាយការណ៍ ដែលអាចកើតឡើងដោយគ្មានរងទោសទណ្ឌនោះទេ។ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ អ្នកសារព័ត៌មាន៣នាក់មកពីសារព័ត៌មាន Samyang Hot News ត្រូវបានមនុស្សមួយក្រុមប្រដាប់ដោយដំបង និងដុំថ្មវាយដុំលើពួកគេ ស្របពេលដែលពួកគេកំពុងតែរៀបចំផ្សាយផ្ទាល់នូវបទរាយការណ៍មួយអំពីសកម្មភាពល្បែងស៊ីសងនៅក្រុងប៉ោយ ប៉ែត ខេត្តបន្ទាយមានជ័យ។ ជនបង្កបានធ្វើឱ្យខូចខាតដល់សម្ភារៈបរិក្ខាររបស់ពួកគេ រួមមានទូរស័ព្ទស្មាតហ្វូនពីរគ្រឿង ជើងកាមេរ៉ាពីរ អាយកូមពីរ និងរថយន្តពីរគ្រឿង។ អ្នកសារព័ត៌មានម្នាក់បានបាក់ដៃ ស្របពេលដែលអ្នកសារព័ត៌មានម្នាក់បានបាក់ធ្មេញ។ ទោះបីជាបានដាក់ពាក្យបណ្ដឹងជាមួយនគរបាលឃុំហើយ ក៏មិនមានចំណាត់ការអ្វីទាំងអស់។ ក្រោយមក អ្នកសារព័ត៌មានបានប្រគល់សំណុំរឿងនេះទៅកាន់នគរបាលក្រុងប៉ោយប៉ែត ដែលបញ្ជូនសំណុំរឿងនេះទៅកាន់សាលាដំបូងខេត្តដើម្បីចាត់វិធានការបន្តនៅថ្ងៃទី១៣ ខែមីនា។[73] នៅពេលធ្វើសេចក្តីព្រាងនេះ មិនមានព័ត៌មានបញ្ជាក់ថា ជនល្មើសត្រូវបាននាំយកទៅជំនុំជម្រះរកយុត្តិធម៌នោះទេ។

ស្រដៀងគ្នានេះដែរ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣ លោក អ៊ឹម ហាច ជាអ្នករាយការណ៍តាមអនឡាញ ត្រូវបានមនុស្សមួយក្រុមវាយដំ និងយកខ្សែចងនៅក្នុងខេត្តកំពង់ចាម ខណៈពេលដែលកំពុងតែរាយការណ៍អំពី

[72]ឃួន ណារីម និងទេព សួគ៌ានី "ប្រធានគណបក្សភ្លៀងទៀនជាប់ទោសពីបទបរិហាកេរ្តិ៍ តុលាការបង្គាប់ឱ្យសងជំងឺចិត្ត ១,៥ លានដុល្លារដល់រដ្ឋាភិបាល" ( *សារព័ត៌មាន ខេមបូចា* ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤)។

[73]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមករា – មីនា ឆ្នាំ២០២៤)" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤) ទំព័រ ៩ និង ១០ https://tinyurl.com/3v7eauxy។

ករណីចោទប្រកាន់ថាជួញដូរឈើខុសច្បាប់។ វីដេអូមួយដែលបានបង្ហោះនៅលើហ្វេសប៊ុកបានបង្ហាញថា លោក ហាច ត្រូវបានគេស្រោតសម្លៀកបំពាក់ ចង និងដេកនៅលើដី។ លោកត្រូវបានគេបញ្ជូនទៅកាន់នគរបាល ប៉ុន្តែក្រោយមកបានដោះលែងមកវិញបន្ទាប់ពីព្រមព្រៀងសម្រុះសម្រួលជាមួយនឹងជនបង្ក ដែលមិនមានចំណាត់ការណាមួយអនុវត្តលើជនបង្កនោះទេ។ ហេតុការណ៍នេះត្រូវបានគេរាយការណ៍ថាកើតឡើងបន្ទាប់ពី លោក ហាច បានចូលក្នុងបរិវេណអាជីវកម្មឯកជនដោយមិនមានការអនុញ្ញាតឱ្យផ្តិតយករូបភាព។[74] នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២៤ នគរបាលយោធានៅក្រុងប៉ោយប៉ែត បានវាយដំលើរូបកាយ និងបានចាប់ខ្លួនអ្នកសារព័ត៌មានអនឡាញមួយរូប ខណៈពេលដែលគាត់កំពុងរាយការណ៍អំពីការបង្ក្រាបមួយទៅលើ "សកម្មភាពអនាធិបតេយ្យ" ដែលកំណត់មុខសញ្ញាលើជនជាតិឥណ្ឌូនេស៊ី។ នៅពេលកំពុងថតរូបភាព មន្ត្រីនគរបាលបានដកហូតយកទូរស័ព្ទស្មាតហ្វូនរបស់គាត់។ នៅពេលដែលអ្នកសារព័ត៌មានបានជំទាស់ និងទាមទារសុំទូរស័ព្ទមកវិញ នគរបាលបានចាប់ខ្លួនគាត់ ដោយយកខ្សែចងដៃ និងរុញគាត់ចូលក្នុងរថយន្ត។ នគរបាលយោធាបានអះអាងថា ពួកគេបានធ្វើសកម្មភាពដើម្បីទប់ស្កាត់ការជ្រៀតជ្រែកកម្លាំងអន្តរាគមន៍ដោយលើកឡើងថាអ្នកសារព័ត៌មានរូបនោះមិនមានបណ្ណសម្គាល់ខ្លួនសារព័ត៌មាន។ បន្ទាប់ពីឃុំខ្លួនរយៈពេលបីម៉ោង អ្នកសារព័ត៌មានត្រូវបានដោះលែងវិញនៅពេលដែលព្រមព្រៀងមិនសរសេរអត្ថបទព័ត៌មានអំពីការចាប់ខ្លួននេះ។[75]

អ្នកសារព័ត៌មាន និងស្ថាប័នផ្សព្វផ្សាយក៏បានជួបប្រទះនឹងការឃាយីតាមប្រព័ន្ធអ៊ីនធឺណិតផងដែរក្នុងអំឡុងពេលនៃរបាយការណ៍។ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ អ្នកសារព័ត៌មានជាង ១០០ នាក់បានដាក់ញត្តិទៅក្រសួងព័ត៌មាន ដើម្បីដកហូតអាជ្ញាបណ្ណសារព័ត៌មានរបស់បុគ្គលល្បីនៅលើហ្វេសប៊ុក ឈ្មោះ ផេង វណ្ណៈ។ ចលនានេះបានធ្វើឡើង បន្ទាប់ពីលោក វណ្ណៈ បានប្រើប្រាស់ភាសាប្រមាថមកលើអ្នកសារព័ត៌មាននៅលើទំព័រហ្វេសប៊ុករបស់ខ្លួន គឺ Pheng Vannak News។ អ្នកសារព័ត៌មានដែលបានចុះហត្ថលេខាលើញត្តិបានលើកទឡ្ហីករណ៍ថា ពាក្យសម្តីរបស់លោក វណ្ណៈ មិនមានពាក្យរិះគន់បែបស្ថាបនានោះទេ តែបានញុះញង់ឱ្យមានការរើសអើង និងបានរួមចំណែកដល់ការធ្វើឱ្យសាធារណជនបាត់បង់សេចក្តីទុកចិត្តមកលើប្រព័ន្ធផ្សព្វផ្សាយ។[76] ញត្តិនេះបន្តថែងទៀតថា មតិរបស់គាត់បានធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពខាងវិជ្ជាជីវៈរបស់ពួកគេ និងបានរួមចំណែកធ្វើឱ្យមានបរិយាកាសគ្រោះថ្នាក់សម្រាប់អ្នកសារព័ត៌មានឯករាជ្យ។[77] ទោះជាយ៉ាងនេះក្តី អាជ្ញាធរមិនបានចាត់វិធានការអ្វីនោះឡើយ។

---

[74]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែតុលា – ធ្នូ ២០២៤)" (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ទំព័រ ១៥ https://tinyurl.com/3v7eauxy។

[75]ខេមបូចា "របាយការណ៍តាមដានប្រចាំត្រីមាសស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា (ខែមេសា – មិថុនា ឆ្នាំ២០២៤)" (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤) ទំព័រ ៩ https://tinyurl.com/3v7eauxy។

[76] ផុន សុធីរ័ត្ន ហៃល កំសាន្ត "អ្នកសារព័ត៌មានជាង ១០០ នាក់ដាក់ញត្តិនៅក្រសួងព័ត៌មាន ដើម្បីដកហូតអាជ្ញាប័ណ្ណរបស់លោក ផេង វណ្ណៈ បន្ទាប់ពីទទួលរងការប្រមាថ" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤)។

[77]សារព័ត៌មាន ស៊ីអិនស៊ី "អ្នកសារព័ត៌មានស្នើសុំឱ្យក្រសួងព័ត៌មានចាត់វិធានការលើលោក ផេង វណ្ណៈ ពីបទប្រើពាក្យពេចន៍ប្រមាថដល់អ្នកសារព័ត៌មាន" (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤)។
https://www-cnc-com-kh.translate.goog/detail/news/45239>?_x_tr_sl=auto&_x_tr_tl=en&_x_tr_hl=en&_x_tr_pto=wapp

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ មានការរាយការណ៍ថា បណ្ដាញផ្សព្វផ្សាយចំនួនបី ពោលគឺ វិទ្យុអាស៊ីសេរីខ្មែរ វីអូឌីខ្មែរ និងខេមបូឌាដេលីខ្មែរ បានក្លាយជាមុខសញ្ញានៃយុទ្ធនាការលាបពណ៌តាមប្រព័ន្ធអ៊ីនធឺណិត ពីសំណាក់ក្រុមអ្នកប្រើប្រាស់ហ្វេសប៊ុក។ គណនីទាំងនេះ ជារឿយៗ ជាគណនីអនាមិក ដែលមានអ្នកតាមដានតិចតួច ឬមានរូបប្រូហ្វាលជាបុគ្គលស្លៀកពាក់ឯកសណ្ឋានយោធា បានបង្ហោះមតិយោបល់ដូចៗគ្នាដោយចោទប្រកាន់ស្ថាប័នផ្សព្វផ្សាយថាចែកចាយព័ត៌មានក្លែងក្លាយ និងបម្រើឱ្យផលប្រយោជន៍បរទេស។ អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយបានស្នើឡើងថា មតិយោបល់ទាំងនេះ គឺទំនងជាធ្វើឡើងដោយ "ក្រុមមានអង្គភាពចាត់តាំង" ដែលដៅមុខសញ្ញាទៅលើប្រព័ន្ធផ្សព្វផ្សាយមិនមែនគ្រប់គ្រងដោយរដ្ឋ និងមានមូលដ្ឋាននៅបរទេស។ ការស៊ើបអង្កេតរបស់សារព័ត៌មាន ខេមបូចា បានបង្ហាញឱ្យឃើញថា គណនីទាំងនេះភាគច្រើនបានចែកចាយមាតិកាពីបុគ្គលដែលគាំទ្ររដ្ឋាភិបាល និងបង្ហាញឥរិយាបថដដែលៗ ដែលទាំងនេះនាំឱ្យមានចម្ងល់ពីសុក្រិតភាពរបស់គណនីទាំងនោះ។ កងទ័ពជើងគោកកម្ពុជា បានច្រានចោលការចូលរួមពាក់ព័ន្ធនានា ដោយលើកឡើងថា មតិយោបល់នៅលើបណ្ដាញសង្គម ជារឿងឯកជន។[78]

## បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានជាស្ត្រី

វិស័យសារព័ត៌មាននៅកម្ពុជា នៅតែជាវិស័យមួយដែលភាគច្រើនគឺជាបុរស យោងតាមទិន្នន័យពីក្រសួងព័ត៌មានបង្ហាញឱ្យឃើញអំពីការធ្លាក់ចុះនៃចំនួនអ្នកសារព័ត៌មានជាស្ត្រី។ នៅឆ្នាំ២០២១ អ្នកសារព័ត៌មានជាស្ត្រីមានចំនួន ៤៧០ នាក់ ដែលស្មើនឹង ៩,៤% នៃចំនួនអ្នកសារព័ត៌មានសរុប។[79] ប៉ុន្តែ ក្រសួងព័ត៌មានបានចេញបណ្ណសម្គាល់ខ្លួនសារព័ត៌មានតែ ២៦៩ បណ្ណប៉ុណ្ណោះសម្រាប់ស្ត្រី ក្នុងចំណោម ៣.២០១ បណ្ណនៅឆ្នាំ២០២៣ ដែលស្មើនឹងត្រឹមតែ ៨,៧% ប៉ុណ្ណោះ។[80] ក្រសួងហាក់បីដូចជាទទួលស្គាល់អំពីតម្រូវការក្នុងការដោះស្រាយបញ្ហាអតុល្យភាពនេះ។ នៅក្នុងរបាយការណ៍ស្ដីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា បានប្រកាសអំពីផែនការក្នុងការពង្រឹងភាពចម្រុះនៃយេនឌ័រនៅក្នុងតួនាទី និងអាជីពប្រព័ន្ធផ្សព្វផ្សាយតាមរយៈការលើកកម្ពស់សិទ្ធិស្ត្រី និងការបង្កើនការចូលរួមរបស់ពួកគេតាមរយៈការអនុវត្តប្រព័ន្ធកូតា។[81] ក្រសួងមិនបានបញ្ជាក់ឱ្យបានច្បាស់អំពីពេលវេលាដែលត្រូវអនុវត្តវិធានការនេះនោះទេ។

របាយការណ៍ស្ដីពីស្ថានភាពនៃសេរីភាពសារព័ត៌មាន មិនបានបែងចែកទិន្នន័យតាមយេនឌ័រ ដើម្បីបង្ហាញអំពីថាតើបទពិសោធន៍របស់អ្នកសារព័ត៌មានជាស្ត្រីខុសគ្នាយ៉ាងណាពីអ្នកសារព័ត៌មានជាបុរស និងមិនបានដោះស្រាយឧបសគ្គយេនឌ័រជាក់លាក់ ដែលបុគ្គលិកស្ត្រីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយជួបប្រទះឡើយ។ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ សារព័ត៌មាន ខេមបូចា បានស្រង់សម្ដីរបស់អ្នកស្រី ហង្ស សម្ផស្ស ប្រធានក្រុមអ្នកសារព័ត៌មានស្ត្រីកម្ពុជា ដូចដែលបានគូសបញ្ជាក់ឱ្យឃើញថា ចំនួនអ្នកសារព័ត៌មានជាស្ត្រី គឺនៅមានកម្រិត

[78]វ៉ា សុភានុត "ប្រតិបត្តិការជាយុទ្ធសាស្ត្រ និងជាប្រព័ន្ធ" រៀបចំឡើងដើម្បីវាយប្រហារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ " (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤)។

[79]វ័ន្ត សុជាតា "អ្នកសារព័ត៌មានជាស្ត្រីចែករំលែកអំពីក្ដីបារម្ភ និងស្នើឱ្យមានការកែលម្អ " (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២)។

[80]ក្រសួងព័ត៌មាន "របាយការណ៍ស្ដីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា" (ខែមេសា ឆ្នាំ២០២៤) https://tinyurl.com/mr4659u5 ទំព័រ ២០។

[81]ដូចខាងលើ ទំព័រ ៥២។

ដោយសារតែបញ្ហានានាដូចជា ការបៀតបៀនផ្លូវភេទជាដើម។ អ្នកស្រី សម្ផស្ស ក៏បានសម្តែងក្តីព្រួយបារម្ភអំពីសុវត្ថិភាពរបស់ពួកគេផងដែរ ជាពិសេសក្នុងអំឡុងពេលចុះបំពេញការងារនៅទីតាំងផ្ទាល់ និងការធ្វើដំណើរពេលយប់ ព្រមទាំងបានកត់សម្គាល់ថា អ្នកសារព័ត៌មានជាស្ត្រីជារឿយៗគឺជាជនរងគ្រោះនៃការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ដោយអាជ្ញាធរមិនអាចដោះស្រាយបញ្ហានេះបានឱ្យមានប្រសិទ្ធភាពនោះទេ។ បន្ថែមពីនេះទៅទៀត អ្នកស្រី សម្ផស្ស បានចង្អុលបង្ហាញថា ការរឹតត្បិតលើសេរីភាពសារព័ត៌មាន បន្តរាំងដល់ការចូលរួមរបស់ស្ត្រីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។ អ្នកស្រីបានអំពាវនាវឱ្យមានការលើកកម្ពស់ស្ត្រីអ្នកសារព័ត៌មានឱ្យបានច្រើនបន្ថែមទៀត នៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងបានតស៊ូមតិឱ្យមានការបង្កើនឱកាសសម្រាប់ការកសាងសមត្ថភាព និងការគាំទ្រផ្នែកចិត្តសាស្ត្រ។[82]

អ្នកសារព័ត៌មានជាស្ត្រី៤នាក់ក្នុងចំណោម៧នាក់ដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ បានរាយការណ៍ថាជួបប្រទះបញ្ហាលំបាកនៅក្នុងការបំពេញការងាររបស់ខ្លួន ដោយសារតែយេនឌ័ររបស់ពួកគេ។ អ្នកឆ្លើយតបម្នាក់បានចង្អុលបង្ហាញថា អ្នកសារព័ត៌មានជាស្ត្រីជួបប្រទះការរើសអើង និងការរឹតត្បិតជាប្រចាំ ដោយមានអ្នកសារព័ត៌មានខ្លះត្រូវបានគេហាមឃាត់ពីការផលិតព័ត៌មាន ដោយសារតែលម្អៀងដោយផ្អែកលើយេនឌ័រ។ អ្នកសារព័ត៌មានម្នាក់ទៀតបានលើកឡើងថា គាត់ជួបប្រទះបញ្ហាជាញឹកញាប់នៅក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការបំពេញការងារសារព័ត៌មានរបស់ខ្លួន។ គាត់បានរាយការណ៍ថា បានជួបប្រទះបញ្ហាប្រឈមនៅពេលធ្វើដំណើរផ្លូវឆ្ងាយដើម្បីប្រមូលព័ត៌មាន រួមទាំងក្តីបារម្ភចំពោះសុវត្ថិភាពក្នុងអំឡុងពេលសម្ភាស និងបញ្ហាធ្វើដំណើរនៅក្នុងខេត្តមួយចំនួន ព្រមទាំងបានបង្ហាញឱ្យដឹងអំពីបទពិសោធន៍ទទួលរងការបៀតបៀនពីសំណាក់អ្នកផ្តល់សម្ភាសន៍ទៀតផង។ អ្នកផ្តល់សម្ភាសន៍ទីបី អ្នកសារព័ត៌មានដែលជាមនុស្សស្រឡាញ់ភេទទាំងពីរ បានលើកឡើងថា គាត់បានជួបប្រទះបញ្ហាប្រឈមយ៉ាងខ្លាំងនៅក្នុងការប្រមូលព័ត៌មាន និងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់គាត់ ជាពិសេសសិទ្ធិក្នុងការរាយការណ៍ព័ត៌មាន ដែលអាជ្ញាធរបានប្រមាថមកលើការងាររបស់គាត់ ដោយពោលពាក្យថាគេឱ្យអ្នកឯងប៉ុន្មាន? ម្តេចក៏ខំប្រឹងម្ល៉េះ? អ្នកឯងមិនខ្លាចស្លាប់ទេឬអី?

អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកសារព័ត៌មាន ក៏បានលើកឡើងអំពីក្តីបារម្ភចំពោះការរើសអើងដែលអ្នកសារព័ត៌មានជាស្ត្រីបានជួបប្រទះ ដែលត្រូវបានអាជ្ញាធរមួយចំនួនមើលមកពួកគាត់ថាមិនមានសមត្ថភាពដូចបុរស។ អាជ្ញាធរទាំងនេះជារឿយៗ ចោទសួរថាហេតុអ្វីបានជាស្ត្រីទាំងនេះជ្រើសរើសវិស័យសារព័ត៌មាន នៅពេលដែលមានអាជីពផ្សេងៗទៀត។ ប្រការនេះបានបង្ហាញឱ្យឃើញអំពីជំនឿមួយថា ការងារសារព័ត៌មានគឺមិនសមស្របសម្រាប់ស្ត្រីនោះទេ។ អ្នកចូលរួមបានសង្កត់ធ្ងន់ថា ឥរិយាបថលម្អៀងបែបនេះ ធ្វើឱ្យប៉ះពាល់ដល់ការចូលរួមចំណែករបស់ស្ត្រីអ្នកសារព័ត៌មាន ដោយពង្រឹងបន្ថែមទៅលើភាពលម្អៀងផ្អែកលើ យេនឌ័រដែលមិនផ្តល់តម្លៃដល់ការងាររបស់ស្ត្រី បើធៀបជាមួយ

[82]ខេមបូចា "អ្នកសារព័ត៌មានជាស្ត្រី និងបញ្ហាប្រឈមដែលពួកគេជួបប្រទះនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ" (ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤) https://tinyurl.com/bdzxc2p8។

ការសម្ភាស និងកិច្ចពិភាក្សាក្រុមគោលដៅ បានបង្ហាញឱ្យឃើញពីការរើសអើងដោយផ្អែកលើយេនឌ័រ និងឧបសគ្គអាជីពការងារដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងាររបស់អ្នកសារព័ត៌មានជាស្ត្រី។ ភាពលម្អៀងជាប្រព័ន្ធទាំងនេះ មិនត្រឹមតែរារាំងដល់សិទ្ធិទទួលព័ត៌មាន និងសេរីភាពខាងការបញ្ចេញមតិប៉ុណ្ណោះទេ តែថែមទាំងចូលរួមចំណែកធ្វើឱ្យបរិកាសការងារមានគ្រោះថ្នាក់ទៀតផង ដែលបង្អាក់ទឹកចិត្តដល់ស្ត្រីមិនឱ្យឈោងចាប់អាជីពការងារនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ។ បន្ថែមពីនេះទៅទៀត បញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះនៅពេលចូលរួមជាមួយនឹងសមាគមស្ត្រី និងសមាគមអ្នកស្រឡាញ់ភេទដូចគ្នាគូសបញ្ជាក់ឱ្យឃើញអំពីភាពស្មុគស្មាញកាន់តែច្រើន ដែលក្នុងនោះស្ត្រីអ្នកសារព័ត៌មានជួបប្រទះហានិភ័យ និងការរារាំងដល់ការរាយការណ៍អំពីប្រធានបទរសើបពាក់ព័ន្ធនឹងបញ្ហាប្រឈមរបស់សហគមន៍។ ការរើសអើងបែបនេះ បញ្ជាក់ឱ្យឃើញអំពីតម្រូវការបន្ទាន់ក្នុងការផ្លាស់ប្តូរជាប្រព័ន្ធ ដើម្បីគាំទ្រ និងផ្តល់តម្លៃពីតួនាទីរបស់ស្ត្រីនៅក្នុងលំហប្រព័ន្ធផ្សព្វផ្សាយ។

ការតំណាងឱ្យចំនួនស្ត្រីមិនបានគ្រប់គ្រាន់នៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសនៅក្នុងតួនាទីដឹកនាំមានផលប៉ះពាល់យ៉ាងខ្លាំង ដោយសារតែវាធ្វើឱ្យវដ្តនៃការមិនអើពើ និងការផាត់ចោលស្ត្រីនៅក្នុងសង្គមកម្ពុជាមិនងាយសាបសូន្យទៅណាឡើយ។

> ការសិក្សារបស់អង្គការយូណេស្កូ ដែលបានចុះផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ និងផ្អែកលើការវិភាគលើ ៤.០៩៤ អត្ថបទព័ត៌មាន ចាប់ពីខែមករា ឆ្នាំ២០២៣ បានបង្ហាញអំពីអតុល្យភាពយេនឌ័រយ៉ាងធ្ងន់ធ្ងរនៅក្នុងការផ្សព្វផ្សាយសារព័ត៌មាន។ ក្នុងចំណោមសារព័ត៌មានទាំងនេះ មានសារព័ត៌មានតែ ៥% ប៉ុណ្ណោះដែលមានវត្តមានស្ត្រីផ្តាច់មុខ បើធៀបទៅនឹងសារព័ត៌មានជាងពាក់កណ្តាលដែលមានវត្តមានបុរស។

បន្ថែមពីនេះ រឿងរ៉ាវសារព័ត៌មានដែលមានវត្តមានបុរសផ្តាច់មុខ គឺអាចនឹងទំនងជារឿងនៅទំព័រមុខច្រើនជាងស្ត្រី រួមទាំងនៅពេលវេលាមានមនុស្សមើលច្រើននៅលើទំព័រមុខ។ ជាចុងក្រោយ សមភាពយេនឌ័រ និងបញ្ហាវិសមភាពមានការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ ហើយរឿងរ៉ាវអំពីអំពើហិង្សាលើយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ គឺកម្រនឹងផ្សព្វផ្សាយណាស់ និងជារឿយៗគឺត្រូវបានចាត់ទុកថារំលោភបំពានលើឯកជនភាពរបស់ជនរងគ្រោះ។ បទសម្ភាសន៍ជាមួយអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ ក៏បានចង្អុលបង្ហាញឱ្យឃើញថាថ្នាក់គ្រប់គ្រងជាន់ខ្ពស់ផងដែរ ដែលទទួលខុសត្រូវលើការជ្រើសរើសរឿងរ៉ាវ និងកំណត់យកទស្សនៈ ជានិច្ចកាលមិនយល់ដឹងអំពីបញ្ហាយេនឌ័រប៉ុន្មាននោះទេ។[83]

នៅពេលដែលស្ត្រីមិនមានការតំណាងឱ្យបានគ្រប់គ្រាន់ និងតំណាងមិនបានត្រឹមត្រូវនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានរហូតដូច្នេះ ទស្សនៈ និងបញ្ហារបស់ពួកគេ គឺមិនសូវទំនងជាទទួលបានការចាប់អារម្មណ៍ និងការចាត់វិធានការឱ្យបានឆាប់រហ័សសមនឹងអ្វីដែលពួកគេត្រូវទទួលបាននោះទេ។ ប្រការនេះមិនត្រឹមតែធ្វើ

[83] អង្គការយូណេស្កូ "អ្នកណាជាអ្នកផលិតសារព័ត៌មានកម្ពុជា៖ ការវាយតម្លៃវត្តមានស្ត្រី និងការបង្ហាញនៅក្នុងសារព័ត៌មានកម្ពុជា" (ខែធ្នូ ឆ្នាំ២០២៣) https://tinyurl.com/49me9e56។

ឱ្យផ្ទត់គំនិតគ្រោះថ្នាក់កាន់តែរឹងមាំប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងដាក់កំហិតទៅលើការយល់ដឹងរបស់សាធារណជន និងការផ្សព្វផ្សាយអំពីបញ្ហាយេនឌ័រសំខាន់ៗ រួមទាំងអំពើហិង្សា និងវិសមភាព។ ជាលទ្ធផល កង្វះភាពចម្រុះនៃសំឡេងរបស់ស្ត្រីនៅក្នុងថ្នាក់ដឹកនាំប្រព័ន្ធផ្សព្វផ្សាយ និងការផ្សព្វផ្សាយ រួមចំណែកដល់ការមិនអើពើលក្ខណៈជាប្រព័ន្ធកាន់តែទូលំទូលាយជាងមុនទៅលើសិទ្ធិ និងបញ្ហាប្រឈមរបស់ស្ត្រី។ ការដែលមិនមានការតំណាងឱ្យស្ត្រីឱ្យបានរឹងមាំនេះ រារាំងដល់កិច្ចខិតខំប្រឹងប្រែងក្នុងការការពារ និងពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី ដោយសារតែប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតទស្សនៈរបស់សាធារណជន និងរបៀបវារៈនយោបាយ។ ដោយសារតែមិនបានគូសបញ្ជាក់ឱ្យឃើញជាក់ច្បាស់អំពីបទពិសោធន៍ និងការចូលរួមចំណែករបស់ស្ត្រី ការអនុវត្តរបស់ប្រព័ន្ធផ្សព្វផ្សាយដែលបានលាតត្រដាងនៅក្នុងរបាយការណ៍របស់អង្គការយូណេស្កូ ធ្វើឱ្យគម្លាតយេនឌ័រ កាន់តែយ៉ាប់យ៉ឺន និងរារាំងដល់វឌ្ឍនភាពឆ្ពោះទៅរកវិសមភាពយេនឌ័រទូលំទូលាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤.២ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស

*ការយាយីតាមប្រព័ន្ធតុលាការមកលើអ្នកការពារសិទ្ធិមនុស្សដោយសារការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ*

អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមដែលជាអ្នកការពារសិទ្ធិមនុស្ស បានគូសបញ្ជាក់ឱ្យឃើញថាការគំរាមកំហែងធំបំផុតចំពោះសេរីភាពខាងការបញ្ចេញមតិ កើតចេញពីច្បាប់ដែលមានលក្ខណៈរឹតត្បិតដែលធ្វើឱ្យសិទ្ធិជាមូលដ្ឋានរបស់សាធារណជនធ្លាក់ចុះ។ ពួកគេបានកត់សម្គាល់ថា ជារឿយៗអាជ្ញាធរប្រើប្រាស់ច្បាប់ទាំងនេះដើម្បីដាក់សម្ពាធលើសំឡេងរិះគន់ រួមទាំងការទាមទារសំណងក្នុងចំនួនទឹកប្រាក់ជាច្រើន ដែលជាយុទ្ធសាស្ត្រមួយដាក់សម្ពាធផ្លូវចិត្តយ៉ាងខ្លាំងមកលើគ្រួសាររបស់ពួកគេ។

អ្នកការពារសិទ្ធិមនុស្សចំនួនប្រាំនាក់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សដែលបានស្ទង់មតិ បានបញ្ជាក់ឱ្យដឹងថា ការយាយីតាមប្រព័ន្ធតុលាការ គឺការគំរាមកំហែងមួយក្នុងចំណោមការគំរាមកំហែងធំបំផុតដែលពួកគេជួបប្រទះ។ អ្នកការពារសិទ្ធិមនុស្សម្នាក់បានលើកឡើងថា "ការគំរាមកំហែងធំបំផុតនោះគឺជាការគំរាមកំហែងដាក់ពន្ធនាគារ ដោយប្រព័ន្ធច្បាប់ត្រូវបានគេប្រើប្រាស់ដើម្បីគាបសង្កត់ និងបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្សដោយចោទប្រកាន់ពួកគេពីបទញុះញង់ បង្កអសន្តិសុខ ឬប៉ុនប៉ងផ្តួលរលំរដ្ឋាភិបាល"។ អ្នកការពារសិទ្ធិមនុស្សមួយរូបទៀតបានសម្តែងការសោកស្តាយចំពោះនិន្នាការរបស់អាជ្ញាធរក្នុងការចោទប្រកាន់លើបុគ្គលដែលផ្សព្វផ្សាយអំពីបញ្ហាធនធានបរិស្ថានថាបង្ក "អសន្តិសុខជាតិ" និង "ការធ្លាក់ចុះសេដ្ឋកិច្ច"។ អ្នកការពារសិទ្ធិមនុស្សទីបីបានលើកឡើងថា អាជ្ញាធរលាបពណ៌ជាប្រចាំទៅលើសំឡេងមិនពេញចិត្តថាជាសមាជិកគណបក្សប្រឆាំង និងដៅមុខសញ្ញាលើពួកគេដោយចោទប្រកាន់ពីបទញុះញង់៖ "ខ្ញុំមិនអាចធ្វើការងារលើបញ្ហារសើបបានទេ ដោយសារតែខ្ញុំអាចនឹងត្រូវជាប់ពន្ធនាគារ"។ ជាចុងក្រោយ អ្នកការពារសិទ្ធិមនុស្សបានតំណាលប្រាប់អំពីរបៀបដែលក្រុមហ៊ុនឯកជនមួយចោទប្រកាន់សហគមន៍របស់ពួកគេពីបទបរិហាកេរ្តិ៍ បន្ទាប់ពីមានការតវ៉ាពាក់ព័ន្ធនឹងដីធ្លី ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីនិន្នាការទូលាយរបស់ភាគីទីបីដែលប្រើប្រាស់បញ្ញត្តិច្បាប់ដែលមានលក្ខណៈរឹតត្បិតរបស់កម្ពុជា ដើម្បីបំបិទការរិះគន់ ឬការចោទប្រកាន់នានា។

ការឃាយឃីតាមប្រព័ន្ធតុលាការ បានបន្តជាឧបករណ៍មួយនៃការបង្ក្រាបអ្នកការពារសិទ្ធិមនុស្សក្នុងអំឡុងពេលនៃរបាយការណ៍។ យោងតាមទិន្នន័យដែលប្រមូលបានតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រាជរដ្ឋាភិបាលកម្ពុជា ឬភាគីទីបីបានចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សយ៉ាងហោចណាស់ ៥០នាក់ ដោយសារការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហាឆ្នាំ២០២៤៖




តួលេខទាំងនេះ អមជាមួយនឹងទស្សនៈយល់ឃើញដែលចែករំលែកដោយអ្នកការពារសិទ្ធិមនុស្សដែលបានស្ទង់មតិ បង្ហាញឱ្យឃើញអំពីនិន្នាការគួរឱ្យព្រួយបារម្ភ ដែលការតស៊ូមតិសិទ្ធិមនុស្សទទួលរងការដាក់ទោសកាន់តែច្រើនឡើងៗ ជាជាងការទទួលស្គាល់ថាជាការចូលរួមចំណែកស្របច្បាប់ចំពោះសង្គមជាតិ។ ការប្រើប្រាស់មធ្យោបាយឃាយឃីតាមប្រព័ន្ធតុលាការដដែលៗពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងភាគីទីបី បង្ហាញឱ្យឃើញអំពីយុទ្ធសាស្ត្របំបិទសំឡេងរិះគន់។ ប្រការនេះមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឱ្យមានបរិយាកាសភ័យខ្លាច ដែលនៅក្នុងនោះអ្នកការពារសិទ្ធិមនុស្សមានអារម្មណ៍ថាមិនអាចលើកឡើងអំពីបញ្ហារសើបបាន ដោយមិនរងហានិភ័យនៃផលវិបាកធ្ងន់ធ្ងរឡើយ។ អំឡុងពេលនៃរបាយការណ៍ អ្នកការពារសិទ្ធិមនុស្សដែលគេដៅភាគច្រើន គឺជាសកម្មជនបរិស្ថាន និងសិទ្ធិការងារ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីការគាបសង្កត់សភាពធ្ងន់ធ្ងរមកលើអ្នកដែលផ្សព្វផ្សាយអំពីបញ្ហាទាំងពីរនេះ ដែលអាជ្ញាធរកម្ពុជាចាត់ទុកថាជាបញ្ហារសើបជាពិសេស។

***យ៉ាងតិចមានអ្នកការពារសិទ្ធិមនុស្សម្នាក់ត្រូវបានកាត់ទោស ហើយម្នាក់ ត្រូវបានសាលាឧទ្ធរណ៍តម្កល់សាលក្រមទុកជាបានការ នៅចន្លោះពេលចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤៖***

***<u>សកម្មជនសហជីព និងសិទ្ធិការងារ</u>***

លោក **ជា ចាន់៖** នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ នគរបាលខេត្តកំពង់ស្ពឺ បានឃុំខ្លួនលោក ជា ចាន់ មេដឹកនាំសហជីពនៃរោងចក្រស្បែកជើងវីងស្តារ ដោយមិនមានដីកា។ ក្រោយមក លោកត្រូវបានគេចោទប្រកាន់ពីបទ "សមគំនិតលួច" និងបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃទី១៨ ខែកុម្ភៈ។ ការចាប់ខ្លួនបានធ្វើឡើង

ក្នុងរយៈពេលប៉ុន្មានសប្ដាហ៍ក្រោយពីលោក ជា ចាន់ ត្រូវបានបោះឆ្នោតជ្រើសតាំងឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៃសហជីពឯករាជ្យមួយដែលទើបបង្កើតឡើងថ្មីថ្មោង ទោះបីជានិយោជិតរបស់លោកបានប៉ុនប៉ងរារាំងមិនឱ្យបង្កើតសហជីពនេះឡើងក្ដី។ អ្នកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសហព័ន្ធសហជីពកម្ពុជាបានអះអាងថារោងចក្រស្បែកជើងវីងស្ដារ "បានប្រឌិត" បទចោទប្រកាន់ជាមួយនគរបាល ដោយកំណត់សំណុំរឿងនេះថាជាការរំលោភបំពានសិទ្ធិសហជីពធ្ងន់ធ្ងរ។[84]នៅថ្ងៃទី២០ ខែមិថុនា តុលាការខេត្តកំពង់ស្ពឺបានផ្ដន្ទាទោសលោក ជា ចាន់ ឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ រួមទាំងការព្យួរទោសរយៈពេលប្រាំមួយខែ។ អ្នកស្រី សុភ័ណ្ឌ បានមានប្រសាសន៍ថា លោកស្រី "មានការខកចិត្តជាខ្លាំង" ចំពោះសេចក្ដីសម្រេចនេះ ដោយបន្ថែមថា លោក ជា ចាន់ មិនបានប្រព្រឹត្តអំពើលួចអ្វីនោះទេ។ "យើងមិនរំពឹងថាតុលាការធ្វើសេចក្ដីសម្រេចបែបនេះឡើយ។ លោកស្រីបានបន្ថែមថា "សេចក្ដីសម្រេចនេះហាក់បីដូចជារងឥទ្ធិពលពីអ្នកកាន់អំណាច ឬអ្នកមានលុយ។"[85] ក្រោយមក សាលាឧទ្ធរណ៍រាជធានីភ្នំពេញបានធ្វើមោឃកម្មសាលដីកាលើពិរុទ្ធភាពរបស់លោក ជា ចាន់ នៅ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។ អ្នកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសហព័ន្ធសហជីពកម្ពុជា បានសាទរចំពោះសេចក្ដីសម្រេចនេះ ប៉ុន្តែបានលើកឡើងថា វាមិនយុត្តិធម៌សម្រាប់លោក ចាន់ នោះទេ ដែលត្រូវចំណាយរយៈពេលប្រាំមួយខែនៅក្នុងពន្ធនាគារ សូម្បីលោកមិនបានប្រព្រឹត្តបទល្មើសក៏ដោយ។[86]

**សកម្មជនសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលដ៍៖** នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ តុលាការកំពូលបានតម្កល់សេចក្ដីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលផ្ដន្ទាទោស**កញ្ញា ឈឹម ស៊ីថរ** ប្រធានសហជីពគាំទ្រសិទ្ធិការងាររបស់និយោជិតខ្មែរណាហ្គាវើលដ៍ជាប់ពន្ធនាគារពីរឆ្នាំពីបទញុះញង់ពាក់ព័ន្ធនឹងតួនាទីរបស់កញ្ញានៅក្នុងការធ្វើកូដកម្មនៅណាហ្គាវើលដ៍។[87]

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានលើកឡើងថាការិយាល័យមាន "ក្ដីព្រួយបារម្ភជាខ្លាំង" ចំពោះសេចក្ដីសម្រេចនេះ ដោយជំរុញឱ្យមានការដោះលែងកញ្ញា ស៊ីថរ ភ្លាមៗ និងមោឃភាពសេចក្ដីសម្រេចផ្ដន្ទាទោស។ អ្នកនាំពាក្យរបស់ លោក យេរេមី ឡូរិន (Jeremy Laurence) ក៏បានបញ្ជាក់ដែរថា សកម្មជនត្រូវបានគេផ្ដន្ទាទោស ដោយសារតែការ "គ្រាន់តែអនុវត្ត" សិទ្ធិសេរីភាពខាងការជួបប្រជុំ

[84]សុវណ្ណ ស្រីពេជ្រ "មេដឹកនាំសហជីពនៅរោងចក្រ វីងស្ដារស៊ូ ត្រូវបានចោទប្រកាន់ពីបទសមគំនិតក្នុងអំពើលួច បន្ទាប់ពីជាប់ឆ្នោត" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤)។

[85]សុវណ្ណ ស្រីពេជ្រ "មេដឹកនាំសហជីពនៅរោងចក្រ វីងស្ដារស៊ូ ត្រូវបានតុលាការខេត្តកំពង់ស្ពឺផ្ដន្ទាទោសជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤)។

[86]សុវណ្ណ ស្រីពេជ្រ ទេព សួគ៌ានី "សាលដីកាលើពិរុទ្ធភាពរបស់លោក ជា ចាន់ មេដឹកនាំសហជីព ត្រូវបានធ្វើមោឃភាព និងដោះលែងឱ្យមានសេរីភាពបន្ទាប់ពីជាប់ពន្ធនាគារអស់រយៈពេលប្រាំមួយខែ" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៤)។

[87]សុវណ្ណ ស្រីពេជ្រ "តុលាការកំពូលតម្កល់សាលដីកាសាលាដំបូងប្ដឹងទៅលើ កញ្ញា ឈឹម ស៊ីថរ ដោយលើកឡើងថាជា "សេចក្ដីសម្រេចយុត្តិធម៌" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៤) នៅខែមេសា ឆ្នាំ២០២១ កាស៊ីណូណាហ្គាវើលដ៍ បានបញ្ឈប់បុគ្គលិកជាង ១.៣០០ នាក់ ដោយលើកឡើងពីការធ្លាក់ចុះចំណូលបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩។ កម្មករនិយោជិតដែលបានបញ្ឈប់ពីការងារជាច្រើននាក់ គឺជាសមាជិក និងមេដឹកនាំសហជីព។ បន្ទាប់ពីការព្យាយាមចរចាមិនបានសម្រេចជាច្រើនលើកជាមួយនឹងកាស៊ីណូ និងការដាក់បណ្ដឹងទៅអាជ្ញាធរពាក់ព័ន្ធមិនបានជោគជ័យ សហជីពគាំទ្រសិទ្ធិការងាររបស់និយោជិកខ្មែរណាហ្គាវើលដ៍ ("LRSU") បានជូនដំណឹងដល់អាជ្ញាធរអំពីផែនការរបស់ខ្លួនក្នុងការចាប់ផ្ដើមធ្វើកូដកម្មអហិង្សាមួយនៅខែធ្នូ ឆ្នាំ២០២១។ នៅពេលសរសេររបាយការណ៍នេះ (ដំណាច់ខែតុលា ឆ្នាំ២០២៤) វិវាទនេះនៅមិនទាន់បានដោះស្រាយនៅឡើយទេ។

និងខាងសមាគមដោយសន្តិវិធី ដែលការពារនៅក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។[88]ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ បានលើកឡើងថា មតិយោបល់ទាំងនេះ "បានប្រមាថដល់សមត្ថកិច្ច និងសុចរិតភាពរបស់តុលាការកម្ពុជា" ដោយលើកហេតុផលថាសកម្មជនសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលដ៍ "ត្រូវបានផ្តន្ទាទោសពីបទល្មើសដែលពួកគេបានប្រព្រឹត្ត" មិនមែនផ្តន្ទាទោសពីការអនុវត្តសិទ្ធិរបស់ពួកគេនោះទេ។ បេសកកម្មនេះក៏បានបន្តជំរុញឱ្យ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "គោរពអធិបតេយ្យភាព និងដែនយុត្តាធិការជាតិរបស់ប្រទេស [សមាជិកអង្គការសហប្រជាជាតិ] ផងដែរ។ [89] នៅថ្ងៃទី០៥ ខែឧសភា អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានលើកឡើងថា ការផ្តន្ទាទោសនេះគឺ "មិនមានមូលដ្ឋាន" ច្បាស់លាស់។[90]

## *ការរឹតត្បិត*

អ្នកការពារសិទ្ធិមនុស្ស ១៧ នាក់ក្នុងចំណោម ២១ នាក់ដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ ធ្លាប់រងនូវការរឹតត្បិត ឬការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេពីសំណាក់អាជ្ញាធរ ឬភាគីទីបី នៅពេលបំពេញការងារតស៊ូមតិរបស់ពួកគេ។ ការសម្ភាសដែលបានធ្វើឡើងសម្រាប់របាយការណ៍នេះ បង្ហាញឱ្យឃើញអំពីការរឹតត្បិតដែលទទួលរងដោយអ្នកដែលអនុវត្តសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ អ្នកផ្តល់សម្ភាសន៍ម្នាក់បានពិពណ៌នាអំពីការឃ្លាំមើល ដោយលើកឡើងថា "អាជ្ញាធរបានប្រើប្រាស់ប្រព័ន្ធច្បាប់ដើម្បីឃ្លាំមើល និងមិនអនុញ្ញាតឱ្យចាកចេញក្រៅសហគមន៍ ប្រសិនបើនៅក្នុងសហគមន៍មានសកម្មភាពមួយចំនួន ពួកគេនឹងថតរូបទុកជាភស្តុតាង"។ បុគ្គលម្នាក់ទៀតបានបញ្ជាក់ឱ្យដឹងអំពីឥទ្ធិពលភ័យខ្លាចនៃយុទ្ធសាស្រ្តបំភិតបំភ័យ ដោយបានរៀបរាប់ថា "ស្នងការខេត្តបានបញ្ឈប់សកម្មភាព និងគំរាមកំហែងថាប្រសិនបើមិនឈប់ទេ ពួកគេនឹងឃុំខ្លួន។ នេះគឺជាការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ។ ពួកគេបានហៅឈ្មោះ និងបានកោះហៅទៅឱ្យប្រជុំ។" ការជួបប្រទះផ្ទាល់ជាក់ស្តែងទាំងនេះ បង្ហាញឱ្យឃើញអំពីសម្ពាធ និងការភ័យខ្លាចគ្រប់ពេលដែលអ្នកការពារសិទ្ធិមនុស្សបំពេញការងារ ពោលគឺសូម្បីតែសកម្មភាពប្រចាំថ្ងៃ គឺរងការពិនិត្យពិច័យ និងការគំរាមកំហែងដែរ។ ការភ័យខ្លាចពីការតបត ដូចដែលបានបញ្ជាក់ជាភស្តុតាងពីបុគ្គលជាច្រើនដែលជ្រើសរើសមិនដាក់ពាក្យបណ្តឹង ទោះបីជារងការរឹតត្បិតធ្ងន់ធ្ងរក៏ដោយ។ អ្នកផ្តល់សម្ភាសន៍ម្នាក់បានពន្យល់ប្រាប់អំពីការស្ទាក់ស្ទើរនេះ ដោយបានលើកឡើងថា "ខ្ញុំមិនដែលដាក់ពាក្យបណ្តឹងនោះទេ ដោយសារតែអាជ្ញាធរមូលដ្ឋានក៏គ្នាទទួលបញ្ជាពីមន្ត្រីថ្នាក់លើដែរ"។ អារម្មណ៍នៃការគ្មានសិទ្ធិអំណាច និងកង្វះជំនឿចិត្តលើ

---

[88]ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "មតិរបស់អ្នកនាំពាក្យសិទ្ធិមនុស្សអង្គការសហប្រជាចាតិ លោក យេរេមី ឡូរិន (Jeremy Laurence) អំពីតុលាការកម្ពុជាដែលចោទប្រកាន់មកលើ កញ្ញា ឈឹម ស៊ីថរ" (ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤) https://tinyurl.com/mvnyecpv។

[89]ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជានៅទីក្រុងហ្សឺណែវ តាមរយៈហ្វេសប៊ុក៖ "សេចក្តីថ្លែងការណ៍សារព័ត៌មាន៖ ការចូលរួមប្រកបដោយបរិយាប័ន្ននៅក្នុងសង្គមប្រជាធិបតេយ្យអាចធ្វើឡើងទៅបាន នៅពេលដែលបុគ្គលអនុវត្តសិទ្ធិរបស់ពួកគេប្រកបដោយគណនេយ្យភាព" (ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤) https://tinyurl.com/4mwv8dda។

[90]អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ ការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ គួររិះគន់ទៅលើការបាត់បង់សេរីភាព" (ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤) https://tinyurl.com/5b2wura8។

ប្រព័ន្ធច្បាប់ បានធ្វើឱ្យវដ្តនៃការបំបិទសេរីភាព និងគាបសង្កត់នៅតែកើតមាន។ បទពិសោធន៍ដែលបានចែករំលែកដោយបុគ្គលទាំងនេះ គូសបញ្ជាក់អំពីតម្រូវការបន្ទាន់ក្នុងការធ្វើកំណែទម្រង់ ដើម្បីធានាថាពលរដ្ឋកម្ពុជាទាំងអស់អាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ពួកគេបានដោយសេរី ដោយមិនចាំបាច់ភ័យខ្លាចការបំភិតបំភ័យ ឬការផ្ទាញ់ផ្ទាលឡើយ។

ស្រដៀងគ្នានេះដែរ ការសម្ភាសដែលបានធ្វើឡើងសម្រាប់របាយការណ៍នេះ លាតត្រដាងឱ្យឃើញអំពីបរិយាកាសឃ្លាំមើលរីករាលដាលគ្រប់កន្លែង ដែលបង្កឱ្យមានភាពភ័យខ្លាចមកលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ អ្នកការពារសិទ្ធិមនុស្សបានប្រាប់អំពីបទពិសោធន៍ដែលរងការឃ្លាំមើលជាប្រចាំពីសំណាក់អាជ្ញាធរ ការតាមដានលើសកម្មភាពរបស់ពួកគេ និងសកម្មភាពនានារបស់ពួកគេត្រូវបានគេពិនិត្យពិច័យជានិច្ច។ អ្នកការពារសិទ្ធិមនុស្សម្នាក់បានចែករំលែកថា "ការរឹតត្បិតពីសំណាក់អាជ្ញាធរដែលតាមដានសកម្មភាពរបស់ខ្ញុំ ហើយខ្ញុំមានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនណាស់។" អារម្មណ៍នេះគឺបញ្ជាក់បន្ថែមពីសំណាក់អ្នកផ្សេងទៀតដែលបានរៀបរាប់អំពីអារម្មណ៍ដូចមានអ្នកចាំឃ្លាំមើលខ្លួនគេជានិច្ច មានការកត់ត្រាអំពីសកម្មភាពរបស់ខ្លួន និងអាចប្រើប្រាស់ការឃ្លាំមើលនេះប្រឆាំងមកលើខ្លួនគេ។ សូម្បីតែនៅកម្រិតមូលដ្ឋានក៏ដោយ ការឃ្លាំមើលនេះគឺបង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់ ដោយមានអ្នកខ្លះបានរាយការណ៍ថា "ប្រធានភូមិតាមដានរាល់សកម្មភាពតស៊ូមតិរបស់ខ្ញុំអំពីសិទ្ធិដីធ្លី ហើយជាទូទៅគាត់មកសួរខ្ញុំថាខ្ញុំបានធ្វើអ្វីខ្លះ និងធ្វើកិច្ចការជាមួយអ្នកណាខ្លះ។" ការឃ្លាំមើលបែបនេះ បង្កើតឱ្យមានបរិយាកាសភ័យខ្លាច និងការដាក់កំហិតខ្លួនឯង ដែលពលរដ្ឋមានការស្ទាក់ស្ទើរក្នុងការបង្ហាញមតិរបស់ខ្លួនដោយសេរី ដោយសារតែភ័យខ្លាចមានផលវិបាក។ ការពិនិត្យពិច័យជាប់ជានិច្ច និងលទ្ធភាពនៃការចាត់វិធានការតាមអំពើចិត្តពីសំណាក់អាជ្ញាធរ បង្អាក់ដល់កិច្ចសន្ទនាបើកចំហ និងការរិះគន់ ដែលជាចុងក្រោយរារាំងដល់ការសម្រេចបាននូវសង្គមមួយដែលមានសេរីភាព និងប្រជាធិបតេយ្យពិតប្រាកដ។

បទសម្ភាសន៍បានបង្ហាញឱ្យឃើញអំពីបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យដែលអ្នកការពារសិទ្ធិមនុស្សទទួលរងសម្ពាធគ្រប់ទម្រង់ ដែលរៀបចំឡើងដើម្បីបំបិទសំឡេងរបស់ខ្លួនគេ។ អ្នកការពារសិទ្ធិមនុស្សម្នាក់បានរៀបរាប់អំពីការបំភិតបំភ័យដោយផ្ទាល់ពីសំណាក់អាជ្ញាធរ ដោយលើកឡើងថា "ខ្ញុំធ្លាប់បានត្រូវគេបំភិតបំភ័យ ហើយអាជ្ញាធរបានចុះមកផ្ទាល់ដើម្បីបំភិតបំភ័យ ដោយសារតែខ្ញុំបានចូលរួមកិច្ចការសង្គម។" អ្នកការពារសិទ្ធិមនុស្សម្នាក់ទៀតបានបញ្ជាក់ពីការបៀតបៀនដោយពាក្យសម្ដីថា "ខ្ញុំធ្លាប់ទទួលរងការរឹតត្បិត ក្នុងន័យការបៀតបៀនដោយពាក្យសម្ដី នៅពេលដែលយើងចុះទៅតាមដានបាតុកម្ម ហើយអាជ្ញាធរបានចាត់ទុកពួកយើងថាជាគណបក្សជំទាស់ និងជាអ្នកគាំទ្រគណបក្សជំទាស់។" វិធីសាស្ត្រទាំងនេះ អមជាមួយនឹងការគំរាមកំហែងឃុំខ្លួន និងវិធានការផ្លូវច្បាប់ បង្កើតឱ្យមានបរិយាកាសមួយដែលធ្វើឱ្យពលរដ្ឋមានភាពស្ទាក់ស្ទើរក្នុងការលើកមតិ ឬចូលរួមនៅក្នុងការងារតស៊ូមតិ។ វិធានការទាំងនេះ គឺបញ្ជាក់ជាភស្តុតាងនៅក្នុងករណីជាច្រើននៃការដាក់កំហិតខ្លួនឯង និងការស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្ដឹង។ អ្នកផ្ដល់សម្ភាសន៍ម្នាក់បានពន្យល់អំពីការសម្រេចចិត្តរបស់គាត់ក្នុងការមិនរាយការណ៍អំពីការបំភិតបំភ័យ ដោយបានលើកឡើងថា "ខ្ញុំមិនដាក់ពាក្យបណ្ដឹង ដោយសារតែខ្ញុំមិនចំណេញអ្វីពីបណ្ដឹងនោះទេ"។ ការរាថយនេះ គូសបញ្ជាក់ឱ្យឃើញថាការស្វែងរក

ដំណោះស្រាយគឺមិនមានប្រយោជន៍អ្វី និងការភ័យខ្លាចកាន់តែខ្លាំងពីផលវិបាកបន្ថែមទៀត។ បទពិសោធន៍ដែលបានចែករំលែកដោយអ្នកការពារសិទ្ធិមនុស្សទាំងនេះ បានសបញ្ជាក់ឱ្យឃើញអំពីសង្គមមួយដែលគួរឱ្យព្រួយបារម្ភ ដែលសេរីភាពខាងការបញ្ចេញមតិ ត្រូវបានគេគាបសង្កត់តាមរយៈការបំភិតបំភ័យ និងការគំរាមកំហែង ដែលធ្វើឱ្យពលរដ្ឋមានអារម្មណ៍ងាយរងគ្រោះ និងមិនមានទឹកចិត្តក្នុងការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួន។

### *ការវាយដំលើរូបរាងកាយអ្នកការពារសិទ្ធិមនុស្ស*

បន្ថែមលើការយាយីតាមផ្លូវតុលាការដែលពួកគេតែងតែប្រឈមនោះ អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាធ្វើការងារក្នុងបរិយាកាសគ្រោះថ្នាក់ និងពុំមានសុវត្ថិភាព។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ មានការកត់ត្រានូវករណីវាយដំលើរាងកាយលើអ្នកការពារសិទ្ធិមនុស្សម្នាក់។

ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ជាខួបដប់ពីរឆ្នាំនៃការសម្លាប់សកម្មជនបរិស្ថានលោក ឈុត វុទ្ធី ដែលត្រូវបានគេបាញ់សម្លាប់នៅពេលដែលអមដំណើរអ្នកសារព័ត៌មានពីរនាក់ចុះធ្វើការស៊ើបអង្កេតករណីកាប់ឈើខុសច្បាប់នៅខេត្តកោះកុង។ លោក វុទ្ធី ត្រូវបានគេស្គាល់ដោយសារតែគាត់ចូលរួមនៅក្នុងការការពារព្រៃឈើ និងធនធានធម្មជាតិកម្ពុជា ព្រមទាំងបកអាក្រាតអំពីបទល្មើសបរិស្ថាន រួមទាំងបទល្មើសពាក់ព័ន្ធនឹងមន្ត្រីកម្ពុជា។[91] នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ សកម្មជនប្រមាណជា ២០ នាក់មកពីអង្គការមាតាធម្មជាតិកម្ពុជា និងព្រះសង្ឃប្រាំមួយអង្គ បានដង្ហែរក្បួនទៅកាន់ក្រសួងយុត្តិធម៌ ដើម្បីដាក់ញត្តិអំពាវនាវឱ្យមានការស៊ើបអង្កេតឯករាជ្យលើករណីសម្លាប់នេះ។ ការដង្ហែរក្បួននេះធ្វើឡើងបន្ទាប់ពីកម្មវិធីគំរប់ខួបនៅផ្ទះសាមគ្គី ដែលមានការចូលរួមពីសំណាក់អ្នកតំណាងអង្គការសង្គមស៊ីវិលប្រមាណជា ៥០ នាក់។[92] អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានលើកឡើងថា សំណុំរឿងនេះត្រូវបានបិទបញ្ចប់ ហើយជនល្មើសត្រូវបានផ្តន្ទាទោសរួចហើយ ដោយលោកបន្ថែមទៀតថា "ការដាក់ញត្តិ ការរិះគន់ និងមតិយោបល់មិនមានមូលដ្ឋាន មិនអាចជំរុញឱ្យនគរបាលធ្វើការស៊ើបអង្កេតបានទេ។"[93] ម.ស.ម.ក ក៏បានចូលរួមជាមួយអង្គការសង្គមស៊ីវិលចំនួនប្រាំពីរផ្សេងទៀតនៅក្នុងការអំពាវនាវឱ្យរដ្ឋាភិបាល បើកការស៊ើបអង្កេតសំណុំរឿងនេះឡើងវិញ និងកំណត់អត្តសញ្ញាណ "អ្នកផ្តើមគំនិត" នៃការសម្លាប់លោក វុទ្ធី។[94]

ករណីស្រដៀងគ្នានេះ ក្នុងខែកក្កដា គម្រប់ខួបប្រាំពីរឆ្នាំនៃឃាតកម្មលើលោក កែម ឡី ជាអ្នកវិភាគនយោបាយ និងអ្នកការពារសិទ្ធិមនុស្សដ៏លេចធ្លោ។ សកម្មជនរូបនេះ ត្រូវបានឃាតករបាញ់សម្លាប់នៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញក្នុងខែកក្កដា ឆ្នាំ២០១៦ ដោយពុំមានការស៊ើបអង្កេតឱ្យបានហ្មត់ចត់

[91]ម.ស.ម.ក «សេចក្តីថ្លែងការណ៍៖ ម.ស.ម.ក សូមចូលរួមមរណៈទុក្ខគម្រប់ខួបពីរឆ្នាំនៃសកម្មជនបរិស្ថាន លោកឈុត វុទ្ធី និងថ្កោលទោសចំពោះវប្បធម៌អំពើហិង្សា និងនិទណ្ឌភាពដែលបន្តកើតមានឡើងនៅកម្ពុជា» (ម.ស.ម.ក ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៤)។

[92]អង្គការលីកាដូ "ពលរដ្ឋកម្ពុជាអំពាវនាវឱ្យរកយុត្តិធម៌ បន្ទាប់ពីរយៈពេល ១២ ឆ្នាំក្រោយពីការសម្លាប់លោក ឈុត វុទ្ធី" (ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤) https://tinyurl.com/mu7fcxy7។

[93]យួន ណារិម "មិនមានការបិទបញ្ចប់សំណុំរឿងនៃការសម្លាប់សកម្មជនប្រឆាំងការកាប់ព្រៃឈើខុសច្បាប់ លោក ឈុត វិទ្ធី បន្ទាប់ពីរយៈពេល ១២ ឆ្នាំ សកម្មជនអំពាវនាវឱ្យមានការស៊ើបអង្កេតឡើងវិញ" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤)។

[94]ម.ស.ម.ក តាមរយៈហ្វេសប៊ុក (ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤) https://tinyurl.com/4weuc5z9។

និងឯករាជ្យ ហើយឃាតករពាក់ព័ន្ធនឹងការសម្លាប់លោកទាំងអស់មិនទាន់ត្រូវបានកាត់ទោសនៅឡើយ។[95] កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ មានមនុស្សប្រមាណជា១៥០នាក់ បានប្រមូលផ្តុំគ្នានៅស្ថាននីយប្រេងឥន្ធនៈទីកន្លែងដែលលោក កែម ឡី ត្រូវឃាតករបាញ់សម្លាប់ ដើម្បីអំពាវនាវឱ្យរដ្ឋាភិបាលផ្តល់យុត្តិធម៌ដល់លោក កែម ឡី។ យ៉ាងតិចមានមន្ត្រីអាជ្ញាធរ ១៥ នាក់ ស្លៀកពាក់ស៊ីវិលបានឃ្លាំមើលព្រឹត្តិការណ៍នោះ។ លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌លើកឡើងថា យុត្តិធម៌បានផ្តល់រួចហើយតាមរយៈការផ្តន្ទាទោសលោក អឿត អាង អតីតទាហានឱ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះអំពើឃាតកម្មក្នុងឆ្នាំ២០១៧ នោះ និងបានបដិសេធការអះអាងថាឃាតករដែលត្រូវបានផ្តន្ទាទោសនោះត្រូវបានគេប្រើឱ្យមកទទួលទោសជំនួស។[96]

ករណីដែលពុំទាន់ត្រូវបានដោះស្រាយ ឬករណីដែលដោះស្រាយមិនបានពេញលេញទាំងពីរនេះ ជាការរំឭកនឹកដល់គ្រោះថ្នាក់ដែលអ្នកការពារសិទ្ធិមនុស្សបន្តប្រឈមដោយសារការធ្វើការងារដោយស្របច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន និងនិទណ្ឌភាពដែលកំពុងកើតមានរាលដាលនៅប្រទេសកម្ពុជា និងផ្តល់លទ្ធភាពដល់ការវាយប្រហារលើអ្នកការពារសិទ្ធិមនុស្សបន្តកើតឡើង។ ជាលទ្ធផល អ្នកការពារសិទ្ធិមនុស្សជាច្រើនពុំមានសេរីភាពក្នុងការអនុវត្តការងាររបស់ខ្លួនដោយសេរី និងបារម្ភពីផលវិបាក។ អ្នកការពារសិទ្ធិមនុស្សចំនួន ១២ នាក់ ក្នុងចំណោម ២១ នាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះបានលើកឡើងថា ធ្លាប់ខ្លាច ឬព្រួយបារម្ភពីសន្តិសុខផ្ទាល់ខ្លួននៅពេលធ្វើការងារសិទ្ធិមនុស្ស។

## *យុទ្ធសាស្ត្រសម្របសម្រួល*

ឆ្លើយតបទៅនឹងបរិយាកាសដែលមិនមានសុវត្ថិភាពក្នុងការបំពេញការងារ អ្នកការពារសិទ្ធិមនុស្សដែលបានស្ទង់មតិសម្រាប់របាយការណ៍នេះ បានបង្កើតយុទ្ធសាស្ត្រសម្របសម្រួលជាច្រើន ដើម្បីបន្តបំពេញការងារសំខាន់ៗរបស់ខ្លួន និងកាត់បន្ថយហានិភ័យចំពោះសុវត្ថិភាពរបស់ខ្លួន។ ដោយទទួលស្គាល់គ្រោះថ្នាក់នៃការបំពេញការងារតែម្នាក់ឯង អ្នកការពារសិទ្ធិមនុស្សខ្លះបានជ្រើសរើសអនុវត្តបេសកកម្ម និងសកម្មភាពនានាជាលក្ខណៈប្រព័ន្ធ និងជាក្រុម។ វិធីសាស្ត្រនេះមិនត្រឹមតែផ្តល់នូវអារម្មណ៍សុវត្ថិភាពប៉ុណ្ណោះទេ តែថែមទាំងបម្រើជាវិធានការដែលអាចអនុវត្តបានជាក់ស្តែងដើម្បីធានាសុវត្ថិភាពនៅពេលពួកគេបំពេញការងារផងដែរ។ ការធ្វើការងារជាក្រុមជួយឱ្យអ្នកការពារសិទ្ធិមនុស្សអាចគាំទ្រគ្នាទៅវិញទៅមក ចែករំលែកហានិភ័យ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងរួមគ្នា ដែលតាមរយៈការធ្វើការជាក្រុមនេះ ពួកគេអាចពង្រឹងភាពធន់បានទាំងអស់គ្នា។

ដើម្បីកាត់បន្ថយហានិភ័យ អ្នកការពារសិទ្ធិមនុស្សកម្ពុជាចូលរួមយ៉ាងសកម្មជាមួយនឹងអាជ្ញាធរ ដោយជូនដំណឹងដល់អាជ្ញាធរអំពីបេសកកម្មរបស់ខ្លួន និងសង្កត់ធ្ងន់ទៅលើភាពស្របច្បាប់នៃសកម្មភាពរបស់ពួក

[95] ម.ស.ម.ក សលាកប័ត្រព័ត៌មាន "និទណ្ឌភាពនៅកម្ពុជា" (*ម.ស.ម.ក* ខែកក្កដា ឆ្នាំ២០២១)។

[96] យួន ណារិម "សកម្មជនស្នើជាថ្មីម្តងទៀតឱ្យស្វែងរកយុត្តិធម៌ក្នុងឱកាសខួបប្រាំពីរឆ្នាំនៃឃាតកម្មលោក កែម ឡី" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤) អង្គការលីកាដូ "បណ្តុំប្រព័ន្ធផ្សព្វផ្សាយ | អស់រយៈពេល៧ឆ្នាំ ការអំពាវនាវឱ្យមានយុត្តិធម៌ទៅលើឃាតកម្មលោកបណ្ឌិត កែម ឡី នៅតែបន្ត" (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣)។ វិទ្យុអាស៊ីសេរី "សកម្មជនកម្ពុជាចងចាំការបាញ់សម្លាប់អ្នករិះគន់រដ្ឋាភិបាលលេខធ្លោនៅឆ្នាំ២០១៦" (វិទ្យុអាស៊ីសេរី ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤)

គេ។ ប្រការនេះសំខាន់ណាស់ ដោយសារតែសកម្មជនជារឿយៗត្រូវបានគេយល់ឃើញដោយភាន់ច្រឡំថាជាអ្នកគាំទ្រគណបក្សជំទាស់ ឬបម្រើឱ្យផលប្រយោជន៍បរទេស។ យុទ្ធសាស្ត្រនេះជួយបន្ធូរបន្ថយភាពតានតឹងបណ្ដុះនូវស្មារតីសហប្រតិបត្តិការ និងឆ្លុះបញ្ចាំងអំពីការយល់ដឹងរបស់អ្នកការពារសិទ្ធិមនុស្សអំពីតម្រូវការក្នុងការសម្របសម្រួលជាមួយអំណាចមូលដ្ឋានដោយប្រុងប្រយ័ត្ន។ លើសពីនេះ អ្នកឆ្លើយតបបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃចំណេះដឹងអំពីក្របខណ្ឌច្បាប់ដែលគ្រប់គ្រងលើសេរីភាពមូលដ្ឋាន និងការតស៊ូមតិអំពីសិទ្ធិមនុស្សសម្រាប់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ ការយល់ដឹងផ្នែកច្បាប់នេះ ជួយពួកគេឱ្យស្ថិតនៅក្នុងព្រំដែនច្បាប់ និងការពារសកម្មភាពរបស់ពួកគេ ប្រសិនបើមានការតបត ដែលអនុញ្ញាតឱ្យពួកគេបំពេញការងារក្នុងលំហពលរដ្ឋដែលមានការរឹតត្បិតនៅកម្ពុជាកាន់តែមានទំនុកចិត្ត។ ចំណេះដឹងនេះ ជួយពង្រឹងការការពារ និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការបន្តបំពេញការងារប្រកបដោយប្រសិទ្ធភាព។

ជាចុងក្រោយ អ្នកឆ្លើយតបជាច្រើនបានជ្រើសរើសមិនធ្វើការលើប្រធានបទក្ដៅៗដូចជាសិទ្ធិនយោបាយជាដើម ដោយផ្ដោតលើបញ្ហាសិទ្ធិមនុស្សផ្សេងៗដែលមិនសូវបង្កឱ្យមានប្រតិកម្មតបពីសំណាក់អាជ្ញាធរ។ យុទ្ធសាស្ត្រនេះបញ្ជាក់ឱ្យឃើញពីភាពចាំបាច់ក្នុងការគិតគូរល្អិតល្អន់ទៅលើហានិភ័យពីសំណាក់អ្នកការពារសិទ្ធិមនុស្ស ដើម្បីធានាបាននូវសុវត្ថិភាពរបស់ខ្លួនគេ ដោយបញ្ជាក់ឱ្យឃើញពីតុល្យភាពរវាងការលើកកម្ពស់សិទ្ធិមនុស្ស និងការការពារខ្លួនពីការយាយី។ នៅក្នុងស្ថានភាពដែលពួកគេជួបបញ្ហាប្រឈម ឬការបំភិតបំភ័យដោយផ្ទាល់ពីអាជ្ញាធរ អ្នកការពារសិទ្ធិមនុស្សខ្លះបានជ្រើសរើសផ្ដាច់ខ្លួន និងមិននិយាយស្ដី ស្របពេលដែលអ្នកផ្សេងទៀតប្រមូលផ្ដុំជាក្រុមឡើងវិញ និងត្រៀមរៀបចំវិធីសាស្ត្រផ្សេងទៀតដែលមិនសូវទាញចំណាប់អារម្មណ៍មន្ត្រីមូលដ្ឋាន។ ការសម្របខ្លួននេះ ជួយឱ្យពួកគេបន្តការងារតស៊ូមតិ ស្របពេលដែលកាត់បន្ថយការប្រឈម ប៉ុន្តែប្រការនេះក៏បញ្ជាក់ឱ្យឃើញអំពីតម្រូវការជាបន្តបន្ទាប់ក្នុងការកែសម្រួលយុទ្ធសាស្ត្ររបស់ខ្លួនគេនៅក្នុងបរិបទកម្ពុជា។

### *សេរីភាពបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី*

នៅក្នុងបរិយាកាសប្រទូសចំពោះសំឡេងរិះគន់ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីគេចមិនផុតពីការជួបនូវបញ្ហាប្រឈមជាច្រើនដែលសកម្មជននានាប្រឈមនៅប្រទេសកម្ពុជានោះទេ។ ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលប្រឈមនឹងចំណាត់ការផ្លូវច្បាប់ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួនក្នុងអំឡុងពេលរាយការណ៍នេះ គឺកញ្ញា ឈឹម ស៊ីថរ សកម្មជនសហជីពដ៏លេចធ្លោ ក៏ដូចជាលោក ឈុន ហួត ផងដែរ។ ទោះជាយ៉ាងនេះក្ដី អ្នកការពារសិទ្ធិមនុស្សជាស្ត្រីកម្ពុជាក៏ជួបប្រទះនឹងឧបសគ្គលើយេនឌ័រផងដែរ ដែលចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងបទដ្ឋានសង្គមដែលពិបាកនឹងកែប្រែ ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការរឹតត្បិត ការរំលោភបំពាន និងការរារាំងពីសង្គមច្រើនជាងបុរស។ ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ១០ នាក់ដែលបានស្ទង់មតិសម្រាប់របាយការណ៍នេះ ប្រាំបួននាក់បានរាយការណ៍ថាធ្លាប់រងវិបត្តិនៅពេលព្យាយាមអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ជាពិសេសដោយសារតែយេនឌ័ររបស់ពួកគេ។

អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅកម្ពុជា ជួបប្រទះនឹងហានិភ័យខ្ពស់ ដោយសារកត្តាសង្គមដែលបង្អាក់ទឹកចិត្តស្ត្រីមិនឱ្យសម្ដែងមតិ។ ពួកគេតបតទៅនឹងរចនាសម្ព័ន្ធអំណាចបែបប្រពៃណី និងបទដ្ឋានសង្គមតាម

រយៈការតស៊ូមតិលើបញ្ហាដូចជា សិទ្ធិដីធ្លី ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការបំភិតបំភ័យ អំពើហិង្សា និងការបៀតបៀនពីសំណាក់អាជ្ញាធរ និងអ្នកផ្សេងទៀត។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីម្នាក់បានលើកឡើងថា សេរីភាពខាងការបញ្ចេញមតិមានកម្រិតសម្រាប់ស្ត្រី ខណៈដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីម្នាក់ទៀតបានរៀបរាប់អំពីការទទួលរងការគំរាមកំហែងដាក់ពន្ធនាគារដោយសារតែសកម្មភាពរបស់គាត់។ ភាពងាយរងគ្រោះនេះ គឺត្រូវបានគូសបញ្ជាក់បន្ថែមដោយបទពិសោធន៍របស់អ្នកឆ្លើយតបទីបីដែលបានកត់សម្គាល់ថា អ្នកតស៊ូមតិជាស្ត្រី គឺទទួលរងការវាយដំលើរូបកាយជាញឹកញាប់ក្នុងអំឡុងពេលធ្វើការតវ៉ា។ អ្នកឆ្លើយតបទី៤បានសម្ដែងការសោកស្ដាយថា អ្នកការពារសិទ្ធិមនុស្សជាស្ត្រីអះអាងអំពីកង្វះការគាំទ្រ និងទទួលរងការរើសអើងពីប្រជាពលរដ្ឋក្នុងសហគមន៍ ឬគ្រួសាររបស់ពួកគេផ្ទាល់ ដែលព្យាយាមរារាំងពួកគេក្នុងការចូលរួមនៅក្នុងការតស៊ូមតិសិទ្ធិមនុស្ស។ គាត់បានលើកឡើងថា សម្ពាធបែបនេះអាចធ្វើឱ្យមានផលប៉ះពាល់មកលើការងាររបស់ពួកគេ និងអាចនាំឱ្យមានភាពតានតឹងផ្លូវចិត្តផងដែរ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីទី៥បានលើកឡើងស្រដៀងគ្នា ដោយបង្ហាញអំពីក្ដីបារម្ភចំពោះការរើសអើងពីសង្គម។ កង្វះការគាំទ្រ និងការទទួលស្គាល់នេះបង្កើតឱ្យមានឧបសគ្គយ៉ាងខ្លាំងសម្រាប់អ្នកតស៊ូមតិជាស្ត្រី ដោយសារតែពួកគេរងសម្ពាធទាំងពីអាជ្ញាធរ និងសហគមន៍របស់ពួកគេផ្ទាល់។ បរិយាកាសប្រទូសនេះ អាចបង្កភាពភ័យខ្លាច ដែលបង្អាក់ទឹកចិត្តស្ត្រីក្នុងការសម្ដែងមតិ និងរារាំងអ្នកដែលធ្វើការសម្ដែងមតិក្នុងការបន្តសកម្មភាពរបស់ពួកគេតទៅទៀត។

ជាចុងក្រោយ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីទី៦ដែលបានស្នង់មតិសម្រាប់របាយការណ៍នេះបានលើកឡើងថា គណនីបណ្ដាញសង្គមរបស់គាត់ រួមទាំងតេលេក្រាម និងហ្វេសប៊ុក ត្រូវបានចោរលួចយកទៅកាន់កាប់ដោយសារតែការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតរបស់គាត់អំពីបញ្ហាសង្គម។ ទោះបីជាគាត់មិនខ្លាចក្នុងការតស៊ូមតិសម្រាប់បញ្ហាសិទ្ធិមនុស្សណាមួយក៏ដោយ ក៏គាត់បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការរក្សាតុល្យភាពសកម្មភាព និងការចាំបាច់ក្នុងការថែទាំគ្រួសាររបស់គាត់។ ទំនួលខុសត្រូវទ្វេនេះឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមកាន់តែធំដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីភាគច្រើនជួបប្រទះ ដែលជាអ្នករ៉ាប់រងបន្ទុកតួនាទីយេនឌ័រ ប្រពៃណីស្របពេលដែលបំពេញការងារតស៊ូមតិសិទ្ធិមនុស្សនៅក្នុងបរិយាកាសដ៏គ្រោះថ្នាក់នេះ។ ទោះបីជាមានបញ្ហាប្រឈមយ៉ាងនេះក្ដី គាត់មិនដែលទុកក្នុងចិត្តថាយេនឌ័ររបស់គាត់គឺជាឧបសគ្គនោះទេ ផ្ទុយទៅវិញគាត់មើលឃើញយេនឌ័រគឺជាប្រភពនៃចំណុចខ្លាំង ដោយជឿថាក្នុងនាមជាស្ត្រីមួយរូប គាត់អាចសម្រេចសមិទ្ធផលបានច្រើនជាងនេះក្នុងនាមជាអ្នកតស៊ូមតិសង្គម។ ប្រការនេះបញ្ជាក់ឱ្យឃើញអំពីភាពធន់របស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅកម្ពុជា ដែលត្រូវគិតអំពីតម្រូវការជីវិតផ្ទាល់ខ្លួន និងខាងវិជ្ជាជីវៈរបស់ពួកគេក្នុងប្រទេសដែលមានបរិយាកាសប្រទូសចំពោះសំឡេងរិះគន់។

### *ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត*

ផ្នែកខាងក្រោមនេះ រៀបរាប់លម្អិតអំពីនិន្នាការគួរឱ្យព្រួយបារម្ភនៃការរឹតត្បិតកើនឡើងទៅលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ទាំងនៅលើប្រព័ន្ធអ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិត។ ប្រជាពលរដ្ឋដែលសម្ដែងមតិរិះគន់ មិនថាពួកគេគឺជាអ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម អ្នកការពារសិទ្ធិមនុស្ស ឬបុគ្គលគណបក្សជំទាស់ក្ដី គឺប្រទះនឹងយុទ្ធសាស្ត្រគាបសង្កត់ជាច្រើនទម្រង់ រួមទាំង ការយាយីផ្លូវច្បាប់ ការឃុំ

ខ្លួនតាមអំពើចិត្ត និងថែមទាំងអំពើហិង្សាលើរូបកាយទៀតផង។ សកម្មភាពទាំងនេះ បង្កើតបរិយាកាសភ័យខ្លាច និងការដាក់កំហិតខ្លួនឯង ដែលប៉ះពាល់ដល់សេរីភាពមូលដ្ឋាន និងគោលការណ៍ប្រជាធិបតេយ្យនៅកម្ពុជា។

### *អ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម*

ម.ស.ម.ក បានកត់ត្រានូវហេតុការណ៍ជាច្រើនពាក់ព័ន្ធនឹងអ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងសាធារណជនដែលត្រូវបានគេដៅមុខសញ្ញាដោយសារតែការរិះគន់មន្ត្រី និងគោលនយោបាយរដ្ឋាភិបាលក្នុងអំឡុងពេលនៃរបាយការណ៍។ ករណីទាំងនេះបង្ហាញឱ្យឃើញអំពីសកម្មភាពគាបសង្កត់ពីសំណាក់អាជ្ញាធរ រួមទាំងយាយីតាមប្រព័ន្ធតុលាការ និងការបំភិតបំភ័យ។ ស្ថានភាពនៃការឆ្លើយតបទៅនឹងមតិរិះគន់តាមប្រព័ន្ធអ៊ីនធឺណិតហាក់បីដូចជាឆ្លុះបញ្ចាំងអំពីការប្រព្រឹត្តរបស់រដ្ឋាភិបាលទៅលើសំឡេងជំទាស់ផ្សេងៗទៀត ដែលជាសញ្ញាណមួយបង្ហាញថា សេរីភាពខាងការបញ្ចេញមតិនៅតែស្ថិតក្រោមការគំរាមកំហែងក្នុងលំហឌីជីថល។

ករណីលេចធ្លោរមួយគឺថា អ្នករិះគន់គណបក្សប្រជាជនកម្ពុជា លោក កង សារ៉ាន់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារបីឆ្នាំនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ពីបទបរិហាកេរ្តិ៍ ញុះញង់ និងប្រមាថចំពោះអង្គព្រះមហាក្សត្រ។ ការចោទប្រកាន់នេះកើតចេញពីការផ្សាយផ្ទាល់នៅលើគេហទំព័រហ្វេសប៊ុក កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣ ដែលនៅក្នុងការផ្សាយនោះ លោកបានរិះគន់គណបក្សកាន់អំណាចថាមិនមានសមត្ថភាពគ្រប់គ្រងអន្តោប្រវេសន៍ខុសច្បាប់ពីវៀតណាម និងបាននិយាយថា ការប្រើប្រាស់គ្រឿងញៀន អំពើពុករលួយនៅក្នុងជួររដ្ឋាភិបាល និងអសន្តិសុខផ្នែកសេដ្ឋកិច្ច នៅតែជាបញ្ហានៅកម្ពុជា។ ចំណាត់ការផ្លូវច្បាប់ដ៏លឿនដែលបានអនុវត្តទៅលើលោក សារ៉ាន់ រួមទាំងការឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលត្រឹមប៉ុន្មានម៉ោងនៃការលើកឡើងបែបនេះ បង្ហាញឱ្យឃើញអំពីវិធីសាស្ត្រមិនអត់ឱនចំពោះការរិះគន់នៅលើប្រព័ន្ធអ៊ីនធឺណិត។[97]

ស្រដៀងគ្នានេះដែរ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ នគរបាលរាជធានីភ្នំពេញបានចាប់ខ្លួនលោក យ៉ង ប៉ាក់ នាយកប្រតិបត្តិក្រុមហ៊ុនក្រុមហ៊ុន អា ហ្វ្រី ប៊ី កម្ពុជា បន្ទាប់ពី លោក ព្រាប កុល រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រីបានដាក់ពាក្យបណ្តឹង។ លោក ប៉ាក់ ត្រូវបានគេចោទប្រកាន់ពីបទញុះញង់ និងបរិហាកេរ្តិ៍ ព្រមទាំងបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២៣ ខែមករា។ នគរបាលបានលើកឡើងថា ការចោទប្រកាន់នេះគឺពាក់ព័ន្ធនឹងការផ្សព្វផ្សាយនៅលើហ្វេសប៊ុកកាលពីថ្ងៃទី១៥ ខែមករា ដែលនៅក្នុងនោះ លោក ប៉ាក់ បានចោទប្រកាន់ទៅលើរដ្ឋមន្ត្រីពីការកេងប្រវ័ញ្ច។ មានការរាយការណ៍ថា លោកបានសារភាព និងបានស្នើសុំការលើកលែងទោស ប៉ុន្តែលោក ព្រាប កុល បានលើកហេតុផលថា លោកមិនមានជម្រើសអ្វីផ្សេងក្រៅពីប្តឹងលោក ប៉ាក់ នោះទេ ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់រដ្ឋាភិបាល និងកិត្តិយសគ្រួសាររបស់លោក។[98] នេះជាករណីនេះដែលអាជ្ញាធរបានបន្ថែមការចោទប្រកាន់ពីបទញុះញង់ ដែលមានស្ថានទម្ងន់ទោសធ្ងន់ជាងមុន ចំពោះករណីដែលជាទូទៅគ្រាន់តែចាត់ថ្នាក់

[97] វិទ្យុអាស៊ីសេរីខ្មែរ "ពលរដ្ឋកម្ពុជាបីរូបត្រូវជាប់ពន្ធនាគារបីឆ្នាំដោយសារតែការផ្សព្វផ្សាយលើ ហ្វេសប៊ុក ដោយរិះគន់លើរដ្ឋាភិបាល" (*វិទ្យុអាស៊ីសេរី*ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣) សំ ឧត្តម "លោក ម៉ុន ពេជ្រ បានប្រកាសថាលោកនឹងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែដល់ម្តាយរបស់សកម្មជន លោក កង សារ៉ាន រហូតដល់ដង្ហើមចុងក្រោយ" [ភាសាខ្មែរ] (*វិទ្យុបារាំងអន្តរជាតិ* ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣)

[98] ប៊ុត រស្មីគង្គា "ធុរជនម្នាក់ត្រូវបានឃុំខ្លួនពីបទបរិហាកេរ្តិ៍មន្ត្រីរដ្ឋាភិបាល" (*ខ្មែរថាមស៍*ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤)។

ជាបទបរិហាកេរ្តិ៍ប៉ុណ្ណោះ។ ការបន្ថែមផលវិបាកផ្លូវច្បាប់ ហាក់បីដូចជាបម្រើជាទម្រង់មួយនៃការតបតទៅលើអ្នករិះគន់ និងជាមធ្យោបាយមួយដើម្បីរារាំងជាសាធារណជនក្នុងការពិនិត្យពិច័យទៅលើមន្ត្រីរដ្ឋាភិបាល។

ហេតុការណ៍មួយទៀតបញ្ជាក់ឱ្យឃើញអំពីឆន្ទៈរបស់អាជ្ញាធរក្នុងការដាក់មុខសញ្ញាលើសាធារណជនសូម្បីតែការសម្តែងមតិមិនពេញចិត្តដែលស្រពិចស្រពិលបំផុតនៅលើបណ្តាញសង្គម។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ នគរបាលរាជធានីភ្នំពេញបានឃុំខ្លួនលោក សុខ ឡា ជាប្តី និងប្រពន្ធឈ្មោះ សុខ លីដា ពីបទប្រើប្រាស់ "ពាក្យសម្តីមិនសមរម្យដែលប៉ះពាល់ដល់ថ្នាក់ដឹកនាំ"។ លោក សុខ ឡា បានថ្លែងពាក្យដែលមានការភាន់ច្រឡំ មិនច្បាស់ ឬមិនស៊ីគ្នាអំពី ព្រះមហាក្សត្រ ព្រះនរោត្តម សីហមុនី និង លោក ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៅក្នុងការផ្សព្វផ្សាយជាអត្ថបទ និងវីដេអូលើហ្វេសប៊ុកមុនពេលលោកត្រូវបានគេចាប់ខ្លួន។ បុគ្គលទាំងពីរក្រោយមកត្រូវបានគេធ្វើតេស្តឃើញសារធាតុញៀន ត្រូវបានបញ្ជូនទៅនគរបាល ដើម្បីកសាងសំណុំរឿង។[99] ទោះបីជាមិនមានការធ្វើបច្ចុប្បន្នភាពករណីនេះឱ្យសាធារណជនបានដឹងនៅពេលធ្វើសេចក្តីព្រាងរបាយការណ៍នេះក្តី ក៏ការឃុំខ្លួនប្រជាពលរដ្ឋសាមញ្ញនៅក្រោមបទចោទប្រកាន់មិនច្បាស់លាស់នេះ បង្ហាញថា មិនមានការអត់ឱនឡើយចំពោះការរិះគន់តាមប្រព័ន្ធអ៊ីនធឺណិតមកលើមន្ត្រីរដ្ឋាភិបាល ទោះជាមានផលប៉ះពាល់តិច ឬច្រើនក្តី។

ជាចុងក្រោយ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤ លោក ហ៊ុន សែន ប្រធានព្រឹទ្ធសភា បានស្នើឱ្យអាជ្ញាធរកម្ពុជាសហការជាមួយនឹងអាជ្ញាធរវៀតណាម ដើម្បីស្រាវជ្រាវរកមុខអ្នកប្រើប្រាស់បណ្តាញសង្គមដែលបានសម្តែងមតិប្រមាថលោកជាភាសាវៀតណាមនៅលើការផ្សព្វផ្សាយរបស់លោកនៅលើ TikTok។ លោកបានលើកឡើងថា មតិយោបល់នេះ គឺទំនងជាកើតឡើងដោយសារតែគម្រោងព្រែកជីកដែលបានអនុម័តដោយអតីតរដ្ឋបាលរបស់លោក ដែលបាននាំឱ្យមានក្តីព្រួយបារម្ភនៅក្នុងប្រទេសវៀតណាមចំពោះផលប៉ះពាល់មកទៅលើតំបន់ដីសណ្តទន្លេមេគង្គ។ នៅថ្ងៃទី២០ ខែឧសភា រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បានកោះហៅឯកអគ្គរដ្ឋទូតវៀតណាម ដើម្បីពិភាក្សាអំពីមតិយោបល់លើប្រព័ន្ធអ៊ីនធឺណិត និងស្នើសុំឱ្យខាងវៀតណាមសហការស្រាវជ្រាវ កំណត់រកអត្តសញ្ញាណអ្នកដែលសរសេរមតិយោបល់នោះ។[100] ករណីនេះបង្ហាញអំពីកម្រិតវិសាលភាព ដែលរដ្ឋាភិបាលធ្វើដើម្បីគ្រប់គ្រងការផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិត ថែមទាំងព្យាយាមពង្រីកវិសាលភាពរបស់ខ្លួនហួសពីព្រំដែនជាតិ ដើម្បីបំបិទទម្រង់នៃការរិះគន់នានានៅលើបណ្តាញសង្គម។ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ជនមិនស្គាល់មុខ៤នាក់ប្រដាប់ដោយស្នាប់ដៃបានវាយដំមកលើលោក នី ណាក់ ដែលជាអ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងភរិយារបស់លោក អ្នកស្រី សុខ ស្រីណែត នៅរាជធានីភ្នំពេញ ដែលធ្វើឱ្យលោករងរបួសធ្ងន់ធ្ងរ និងសន្លប់បាត់ស្មារតី។ ក្រោយមក លោក ណាក់ ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ។ ការវាយប្រហារនេះធ្វើឡើងនៅត្រឹមរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីលោកបានរិះ

---

[99]ខ្មែរថាមស៍ "ប្តីប្រពន្ធដែលបានប្រើប្រាស់ "ពាក្យសម្តីមិនសមរម្យ" នៅលើបណ្តាញសង្គម ត្រូវបានគេឃុំខ្លួន" (*ខ្មែរថាមស៍*ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣) នគរបាលរាជធានីភ្នំពេញ តាមរយៈហ្វេសប៊ុក (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣) http://tinyurl.com/5fzttya6។
[100]វិទ្យុអាស៊ីសេរីខ្មែរ "អ្នកប្រើប្រាស់បណ្តាញសង្គមជនជាតិវៀតណាមសង្ស័យ ដៅមុខសញ្ញាលើលោកហ៊ុន សែន នៅលើ TikTok" (*វិទ្យុអាស៊ីសេរី*ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤)។

គន់រដ្ឋមន្ត្រីកសិកម្មនៅលើហ្វេសប៊ុក ដែលការបង្ហោះផ្សព្វផ្សាយស្រដៀងគ្នា ដោយកំណត់គោលដៅទៅលើរដ្ឋមន្ត្រីក្រសួងកសិកម្ម និងលោក ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ កាលពីប៉ុន្មានថ្ងៃមុន។[101] អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានលើកឡើងថា ហេតុការណ៍នេះបាននាំឱ្យមាន "ក្ដីបារម្ភជាខ្លាំង" ថាភាពឃោរឃៅរបស់រដ្ឋាភិបាលពីមុនមកដែលប្រឆាំងទៅលើសំឡេងរិះគន់ នៅតែមិនមានការផ្លាស់ប្ដូរអ្វីបន្តិចសោះនៅក្រោមរដ្ឋបាលថ្មីនេះ។ អង្គការនេះក៏បានអំពាវនាវឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត "បង្ហាញថាអំពើអាណាធិបតេយ្យគ្មានច្បាប់ទម្លាប់នេះ នឹងត្រូវបានស៊ើបអង្កេត និងផ្ដន្ទាទោសដោយមិនគិតលើអ្នកណាជាអ្នកទទួលខុសត្រូវឡើយ"។[102] នគរបាលរាជធានីភ្នំពេញបានអះអាងថា ការវាយប្រហារនេះគឺជាការប៉ុនប៉ងប្លន់ ដោយបន្ថែមថានគរបាល "កំពុងដុតដៃដុតជើង" ដើម្បីនាំជនល្មើសទាំងអស់មកផ្ដន្ទាទោស។[103] ប៉ុន្តែ លោក ណាក់ បានបដិសេធយ៉ាងមុតមាំទៅលើការវាយតម្លៃនេះ។ "ខ្ញុំ និងភរិយារបស់ខ្ញុំមិនបានត្រូវគេប្លន់យកប្រាក់កាស ឬទ្រព្យសម្បត្តិអ្វីនោះទេ។ នេះគឺជាការប៉ុនប៉ងសម្លាប់។"[104] នៅពេលធ្វើសេចក្ដីព្រាងរបាយការណ៍នេះ ជនសង្ស័យនៅមិនទាន់បានចាប់ខ្លួនបាននៅឡើយទេ។ នេះគឺមិនមែនជាលើកទីមួយនោះទេ ដែលលោក ណាក់ ត្រូវបានគេកំណត់មុខសញ្ញាដោយសារតែការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់លោកនៅលើហ្វេសប៊ុក។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ លោកត្រូវបានគេផ្ដន្ទាទោសដាក់ពន្ធនាគារ ១៨ ខែ និងពិន័យជាប្រាក់ពីរលានរៀលពីបទប្រមាថ និងញុះញង់ជាសាធារណៈ ដោយសារតែនិយាយឌឺដងទៅលើប្រសាសន៍លោកនាយករដ្ឋមន្ត្រីហ៊ុនសែន កាលពីខែធ្នូ ឆ្នាំ២០២០។[105] លោកត្រូវបានគេដោះលែងវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ បន្ទាប់ពីការទទួលទោសរបស់លោក។[106] ពាក់ព័ន្ធនឹងករណីនេះដែរ លោកបានលើកឡើងថា៖ *"ខ្ញុំសូមបដិសេធយ៉ាងមុតមាំថា អំពើនេះប្រព្រឹត្តឡើងដោយសារតែការសងសឹកផ្ទាល់ខ្លួន។ ការវាយប្រហារនេះ គឺមកពីការរិះគន់របស់ខ្ញុំទៅលើរដ្ឋាភិបាល។ វាគឺពាក់ព័ន្ធនឹងសេរីភាពនៃការបញ្ចេញមតិ។ ករណីនេះកើតឡើងភ្លាមៗបន្ទាប់ពីខ្ញុំបានបង្ហោះការរិះគន់មួយចំនួននៅលើហ្វេសប៊ុក។ សកម្មភាពចុងក្រោយរបស់ខ្ញុំ គឺសម្ដែងមតិរបស់ខ្ញុំ។*[107]

---

[101] យួន ណារិម "គ្រួសារអ្នករិះគន់រដ្ឋាភិបាលដែលរងការវាយដំយ៉ាងឃោរឃៅស្វែងរកយុត្តិធម៌" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣) វិទ្យុអាស៊ីសេរីខ្មែរ "បទសម្ភាសន៍៖ សកម្មជនកម្ពុជាដែលរងការវាយដំ រៀបរាប់ឡើងវិញអំពីការវាយប្រហារ" (*វិទ្យុអាស៊ីសេរី* ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣) អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ អ្នករិះគន់ និងភរិយាត្រូវបានគេវាយដំ - ហេតុការណ៍នេះសាកល្បងអំពីឆន្ទៈរបស់រដ្ឋាភិបាលថ្មីក្នុងការដោះស្រាយនិទណ្ឌភាព" (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣)
https://tinyurl.com/33b45set។

[102] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ អ្នករិះគន់ និងភរិយាត្រូវបានគេវាយដំ - ហេតុការណ៍នេះសាកល្បងអំពីឆន្ទៈរបស់រដ្ឋាភិបាលថ្មីក្នុងការដោះស្រាយនិទណ្ឌភាព" (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣) https://tinyurl.com/33b45set។

[103] ប៊ុត រស្មីគង្គា "ការស្វែងរកចាប់ខ្លួនជនសង្ស័យនៅក្នុងការវាយប្រហារលើសកម្មជន" (*ខ្មែរថាមស៍* ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣)។

[104] វិទ្យុអាស៊ីសេរីខ្មែរ "បទសម្ភាសន៍៖ សកម្មជនកម្ពុជាដែលរងការវាយដំ រៀបរាប់ឡើងវិញអំពីការវាយប្រហារ" (*វិទ្យុអាស៊ីសេរី* ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣)

[105] យី សុវុទ្ធី "បុរសម្នាក់ត្រូវបានផ្ដន្ទាទោសជាប់ពន្ធនាគារពីបទនិយាយគ្រាប់តាមលោកហ៊ុន សែន" (*សារព័ត៌មាន ខេមបូចា* ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០) អ៊ុច សុនី "ជាប់ពន្ធនាគារ ១៨ ខែពីបទនិយាយគ្រាប់តាមលោក ហ៊ុន សែន" (*វីអូឌី* ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១)។

[106] ហង្ស ពណ្ណរាយ "បុរសពាក់មាសឱ្យមាន់ ត្រូវបានដោះលែងពីពន្ធនាគារ នឹងចូលរួមជាមួយគណបក្សភ្លើងទៀន" (*ខ្មែរថាមស៍* ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២)។

[107] វិទ្យុអាស៊ីសេរីខ្មែរ "បទសម្ភាសន៍៖ សកម្មជនកម្ពុជាដែលរងការវាយដំ រៀបរាប់ឡើងវិញអំពីការវាយប្រហារ" (*វិទ្យុអាស៊ីសេរី* ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣)

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ លោក ណាក់ ត្រូវបានចាប់ខ្លួនពីបទញុះញង់ និងបរិហាកេរ្តិ៍ បន្ទាប់ពីលោក ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារដាក់ពាក្យបណ្តឹង។ [108] លោកត្រូវបានគេឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃបន្ទាប់។ លោក ណាក់ បាននិយាយថា ការចោទប្រកាន់នេះកើតចេញពីការបង្ហោះនៅលើហ្វេសប៊ុក កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ដែលក្នុងនោះលោកបានរិះគន់សេចក្តីសម្រេចរបស់រដ្ឋាភិបាលក្នុងការផ្តល់ដីទំហំ ៩១ ហិចតានៅខេត្តកំពត ដែលបុគ្គលនោះក៏មានឈ្មោះ "ហេង សួរ" ដែរ។[109] ការបង្ហោះនេះមិនបានលើកឡើងតំណែងផ្លូវការរបស់បុគ្គលនេះឡើយ ហើយក្រោយមករដ្ឋាភិបាលបានច្រានចោលការផ្តល់ដីទៅឱ្យរដ្ឋមន្ត្រីរូបនោះ។ [110] នៅថ្ងៃទី២៤ ខែមករា អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចាត់ទុកការចោទប្រកាន់ថា "ជំរុញដោយនយោបាយ" និងបានអំពាវនាវឱ្យដោះលែងលោក ណាក់ ភ្លាមៗ និងឥតលក្ខខណ្ឌ។ អង្គការនេះក៏បានជំរុញឱ្យរដ្ឋាភិបាលកម្ពុជាគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដោយសេរី ស្របពេលជាមួយគ្នានេះដែរ អង្គការក៏សម្តែងអំពីក្តីបារម្ភចំពោះការដៅមុខសញ្ញាជាបន្តបន្ទាប់មកលើសំឡេងរិះគន់ពីសំណាក់រដ្ឋាភិបាលថ្មី។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានបន្ថែមថា "រដ្ឋាភិបាលថ្មីរបស់កម្ពុជាបានបន្តអនុវត្តការធ្វើទុក្ខបុកម្នេញលើអ្នករិះគន់រដ្ឋាភិបាលបន្តពីរដ្ឋាភិបាលចាស់" ។[111]

## *អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសង្គម*

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ មន្ត្រីនគរបាលបីរូបបានវាយដំលើរូបកាយ គំរាមបាញ់ប្រហារ និងរឹបអូសទ្រព្យសម្បត្តិមួយចំនួនរបស់ ភិក្ខុ សយ សាត ជាព្រះសង្ឃមួយអង្គដែលគេស្គាល់ដោយសារការងារតស៊ូមតិរបស់ព្រះអង្គចំពោះបញ្ហាសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ភិក្ខុ សយ សាត បានមានសង្ឃដីកាថា ពួកគេបានវាយដំព្រះអង្គ ដោយចោទប្រកាន់ព្រះអង្គថាបន្លំធ្វើជាសង្ឃក្លែងក្លាយ និងបានព្រមានព្រះអង្គឱ្យបញ្ឈប់សកម្មភាពសង្គម ជាពិសេស ការគាំទ្រគណបក្សភ្លើងទៀន។ ហេតុការណ៍នេះបានកើតឡើងក្នុងរយៈពេលត្រឹមមួយថ្ងៃបន្ទាប់ពីព្រះអង្គបានប្រកាសនៅលើហ្វេសប៊ុកអំពីផែនការដើរក្បួនពីទីលានប្រជាធិបតេយ្យនៅរាជធានីភ្នំពេញ ទៅខេត្តសៀមរាបពីថ្ងៃទី០១ ដល់ទី១០ ខែធ្នូ ដើម្បីផ្សព្វផ្សាយអំពីសីលធម៌សង្គម និងអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ។ ក្រោយមក ស្នងការ និងស្នងការរងនគរបាលខេត្ត បានច្រានចោលមិនទទួលស្គាល់ចំពោះហេតុការណ៍នេះ។[112]

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤ សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសលោក ម៉ម រិទ្ធី ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា និងអនុប្រធានសហភាពការងារកម្ពុជា ដាក់

---

[108]វិទ្យុអាស៊ីសេរីខ្មែរ "អ្នករិះគន់ប្រឈមនឹងការចោទប្រកាន់បន្ទាប់ពីឌឺដងរដ្ឋាភិបាលនៅលើហ្វេសប៊ុក" (*វិទ្យុអាស៊ីសេរី*, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤)។

[109]អង្គការលីកាដូ "លោក ណាក់ អ្នកអត្ថាធិប្បាយលើបណ្តាញសង្គមជាប់ពន្ធនាគារដោយសារការបង្ហោះលើហ្វេសប៊ុក" (ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៤) https://tinyurl.com/358dv4np។

[110]វិទ្យុអាស៊ីសេរីខ្មែរ "អ្នករិះគន់ប្រឈមនឹងការចោទប្រកាន់បន្ទាប់ពីឌឺដងរដ្ឋាភិបាលនៅលើហ្វេសប៊ុក" (*វិទ្យុអាស៊ីសេរី*, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤)។

[111]អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ អ្នករិះគន់ត្រូវបានចាប់ខ្លួនបន្ទាប់ពីរិះគន់រដ្ឋមន្ត្រី - រដ្ឋាភិបាលថ្មីត្រូវដោះលែងលោក នី ណាក់ ការពារសេរីភាពខាងការបញ្ចេញមតិ" (ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤) https://tinyurl.com/ykxf5chu។

[112]ចាន់ ដារ៉ូ "ភិក្ខុ សយ សាត រត់គេចពីការធ្វើទុក្ខបុកម្នេញរបស់អាជ្ញាធរ" [ភាសាខ្មែរ], (*វិទ្យុអាស៊ីសេរី* ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣) យាង សុខមាន "សង្គមស៊ីវិលចាត់ទុកការឃុំខ្លួនភិក្ខុ សយ សាត ពីសំណាក់រដ្ឋាភិបាលជាការរំលោភបំពានលើសេរីភាពរបស់ព្រះអង្គ" [ភាសាខ្មែរ] (សារព័ត៌មាន ខេមបូចា ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣)។

ពន្ធនាគារ ១៨ ខែ និងពិន័យជាប្រាក់ពីរលានរៀលពីបទញុះញង់ឱ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍ និងបទធ្វើឱ្យបាត់បង់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ។ ក្រោយមក លោកត្រូវបានគេចាប់ខ្លួន និងបញ្ជូនទៅពន្ធនាគារព្រៃស។ កាលពីមុន លោក រិទ្ធី បានរិះគន់នៅក្នុងការផ្សាយផ្ទាល់លើ ហ្វេសប៊ុក កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ទៅលើ កាស៊ីណូ ជីនប៊ី ដែលកាន់កាប់ដោយជនជាតិចិនពីការបំភិតបំភ័យបុគ្គលិកស្រីឱ្យទទួលស្គាល់ថា នាងបានជួយភ្ញៀវប្រើល្បិចដើម្បីឈ្នះល្បែង។ លោកក៏បានសម្ដែងការមិនយល់ស្របទៅនឹងសេចក្ដីសម្រេចរបស់តុលាការក្នុងការឃុំខ្លួននាង ដោយមិនមានភស្តុតាងអ្វីទាំងអស់។ សហភាពការងារកម្ពុជា បានលើកឡើងថា ការផ្ដន្ទាទោសលោក រិទ្ធី គឺ "មិនសមហេតុផល" "បំភិតបំភ័យ" និងជាការយាយីប្រឆាំងនឹងអ្នកតំណាងសហជីព។ លោក ទូច កុសល ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា ក៏បានព្រមានផងដែរថា ប្រការនេះអាចនាំឱ្យមានឥទ្ធិពលភ័យខ្លាចមកលើសកម្មជនការងារ៖ "[លោករិទ្ធី] គ្រាន់តែសម្ដែងមតិរបស់លោកមកលើភាពអយុត្តិធម៌របស់កម្មករនិយោជិត ហើយត្រូវបានគេចាប់ខ្លួន ដូច្នេះអ្នកដឹកនាំសហជីពផ្សេងទៀតមិនហ៊ានសម្ដែងមតិអ្វីនោះទេ។ ប្រសិនបើពួកគេមិនហ៊ានសម្ដែងមតិទេ នោះភាពអយុត្តិធម៌កាន់តែយ៉ាប់យ៉ឺន។"[113]

នៅថ្ងៃទី២៣ ខែកក្កដា នគរបាលស្នងការខេត្តសៀមរាបបានចាប់ខ្លួនសកម្មជនកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសគឺ លោក ស្រ៊ុន ស្រ៊ន កញ្ញា ភឹង សោភា និងលោក សាន សិទ្ធិ ក៏ដូចជាបុគ្គលទី៤ឈ្មោះ លោក ចក់ បានមុនី ដែលនៅក្នុងនោះពួកគេបានពិភាក្សាថាតើកម្ពុជាអាចនឹងបាត់បង់ការគ្រប់គ្រងដែនដី ឬធនធានធម្មជាតិ របស់ខ្លួនមួយផ្នែកទៅឱ្យវៀតណាមនៅក្រោមគំនិតផ្ដួចផ្ដើមកិច្ចសហប្រតិបត្តិការឆ្លងដែនតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)។ បុគ្គលទាំងបួននាក់នេះត្រូវបានបញ្ជូនមករាជធានីភ្នំពេញ ដែលពួកគេត្រូវបានចោទប្រកាន់ពីបទញុះញង់រំខានដល់សន្តិសុខជាតិ និងត្រូវបានឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ។ លោក ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី បានបដិសេធថា កិច្ចព្រមព្រៀង CLV-DTA មិនបានរួមបញ្ចូលបញ្ញត្តិណាមួយដូចដែលបានលើកឡើងនោះទេ។ លោកបានលើកឡើងពីការចោទប្រកាន់នេះថាជា "ការប្រមាថយ៉ាងខ្លាំង" និងបានចោទប្រកាន់ថាសកម្មជនទាំងនេះបំភ្លៃការពិត។ លោកបានបន្ថែមថា "ខ្ញុំស្នើដល់តុលាការ បើសិនជាមានការកាត់ទោស សូមដាក់ទោសកម្រិតអតិ បរមា"។ បទញុះញង់មានស្ថានទម្ងន់ទោសជាប់ពន្ធនាគារពីរឆ្នាំ។

ផ្នែកនេះគូសបញ្ជាក់ឱ្យឃើញអំពីការគាបសង្កត់ជាបន្តបន្ទាប់ និងមានលក្ខណៈជាប្រព័ន្ធទៅលើអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសង្គមនៅកម្ពុជា។ ករណីដែលបានឆ្លុះបញ្ចាំងអំពីលំនាំនៃការយាយី ការបំភិតបំភ័យ និងការឃុំខ្លួនតាមអំពើចិត្ត ដើម្បីបំបិទសំឡេងរិះគន់ និងរារាំងដល់សេរីភាពមូលដ្ឋាន។ ការវាយដំលើរូបកាយមកលើភិក្ខុ សយ សាត ជាព្រះសង្ឃដែលតស៊ូមតិសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម បង្ហាញអំពីឆន្ទៈរបស់អាជ្ញាធរ ប្រើប្រាស់អំពើហិង្សាដើម្បីបំភិតបំភ័យអ្នកដែលមិនហ៊ានសម្ដែងមតិ។ ករណីលោក ម៉ម រិទ្ធី ត្រូវបាន

[113]ឃួន ណារិម និងលី រ៉ូសឡែន "លោក ម៉ម រិទ្ធី មេដឹកនាំសហជីពត្រូវបានគេផ្ដន្ទាទោសពីបទរិះគន់កាស៊ីណូ ជីន ប៊ី កាន់កាប់ដោយជនជាតិចិន កាលពីពីរឆ្នាំមុន" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤)។

ផ្តន្ទាទោសពីបទរិះគន់លើកាស៊ីណូកាន់កាប់ដោយជនជាតិចិន និងតុលាការ ដែលសរបញ្ជាក់ឱ្យឃើញអំពីហានិភ័យដែលអ្នកតតាំងនឹងអ្នកមានអំណាចជួបប្រទះ។ ការផ្តន្ទាទោសរូបលោក បញ្ជូននូវសារភ័យខ្លាចដល់សកម្មជនការងារផ្សេងៗ និងគូសបញ្ជាក់អំពីលំហរួមតូចសម្រាប់ឱ្យសហជីពឯករាជ្យអាចធ្វើប្រតិបត្តិការបានដោយសេរី។

លើសពីនេះ ការចាប់ខ្លួន និងការចោទប្រកាន់សកម្មជនកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដោយសារតែការពិភាក្សាអំពីក្តីបារម្ភព្រំដែនដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើម CLV-DTA លាតត្រដាងបន្ថែមទៀតអំពីការមិនអត់ឱនរបស់រដ្ឋាភិបាលចំពោះមតិផ្ទុយ សូម្បីតែកិច្ចការជាផលប្រយោជន៍ជាតិ។ ការអំពាវនាវរបស់លោក ហ៊ុន សែន ស្នើឱ្យផ្តន្ទាទោសសកម្មជនកម្រិតអតិបរិមា គូសបញ្ជាក់ឱ្យឃើញអំពីការប្រើឥទ្ធិពលនយោបាយលើតុលាការ និងកង្វះការគោរពតាមនិតិវិធីដ៏ត្រឹមត្រូវ។ ករណីទាំងនេះ គូសបញ្ជាក់ឱ្យឃើញអំពីទិដ្ឋភាពគួរឱ្យព្រួយបារម្ភអំពីចេតនារបស់រដ្ឋាភិបាលក្នុងការឃាយីសំឡេងមិនគាំទ្រ និងរក្សាការគ្រប់គ្រងតាមរយៈការបំភិតបំភ័យ និងចំណាត់ការផ្លូវច្បាប់។ ការគាបសង្កត់នេះមិនត្រឹមតែរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

## ៤.៣. ស្ថានភាពនៃសិទ្ធិទទួលព័ត៌មាន

*ការចេញផ្សាយសាលក្រម*

គោលការណ៍យុត្តិធម៌បើកចំហរ ចែងអំពីសិទ្ធិរបស់សាធារណជនក្នុងការទទួលបានសេចក្តីសម្រេចរបស់តុលាការ ទាំងក្នុងសំណុំរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ តម្លាភាពនេះ គឺពិតជាមានសារៈសំខាន់ណាស់មិនត្រឹមតែសម្រាប់ការរក្សាបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងសម្រាប់ជានាឱ្យបាននូវសិទ្ធិទទួលព័ត៌មានផងដែរ។ ការចេញផ្សាយសាលក្រមលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៅក្នុងតុលាការ ដោយដើរតួនាទីការពារប្រឆាំងនឹងសេចក្តីសម្រេចតាមអំពើចិត្ត។ លើសពីនេះ វាជួយឱ្យសាធារណជនមានការយល់ដឹងអំពីប្រព័ន្ធច្បាប់ តាមរយៈការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីឥរិយាបថដែលហាមឃាត់។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធតុលាការកម្ពុជាបង្ហាញឱ្យឃើញនូវការព្រួយបារម្ភពីកង្វះតម្លាភាព។ ទោះបីជាក្រុមប្រឹក្សាជម្មនុញ្ញចេញផ្សាយអំពីសេចក្តីសម្រេចរបស់ខ្លួនជានិច្ចក៏ដោយ ក៏ការអនុវត្តនេះ មិនបានអនុវត្តទូលំទូលាយនៅក្នុងប្រព័ន្ធតុលាការនោះដែរ ដែលបង្អាក់ដល់សិទ្ធិរបស់សាធារណជនក្នុងការទទួលព័ត៌មានផ្លូវច្បាប់ និងអាចធ្វើឱ្យប៉ះពាល់ដល់គណនេយ្យភាពតុលាការផងដែរ។[114] ស្របពេលដែលក្រុមប្រឹក្សាជម្មនុញ្ញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញអំពីតម្លាភាពគួរឱ្យសាទរដោយបានចុះផ្សាយសេចក្តីសម្រេចរបស់ខ្លួន សាលក្រមពីតុលាការផ្សេងៗទៀតនៅតែមិនអាចទទួលបានភាគច្រើនក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ កង្វះសិទ្ធិទទួលពីសេចក្តីសម្រេចតុលាការ បង្ហាញឱ្យឃើញអំពីឧបសគ្គក្នុងការទទួលបានព័ត៌មាន និងទទួលបានទំនុកចិត្តពីសាធារណជន។

[114] វែបសាយត៍ របស់ក្រុមប្រឹក្សាជម្មនុញ្ញកម្ពុជា។

*ការរឹតបន្តឹងការចូលប្រើគេហទំព័រសារព័ត៌មាន*

យោងតាមវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ ២០២៣ មានគេហទំព័រចំនួន ២.២០១ ត្រូវបានវាស់វែងដោយ OONI Probe tool។ លទ្ធផលបានបង្ហាញឱ្យ ឃើញថា នៅកម្ពុជា គេហទំព័រចំនួន ៣៧ (គេហទំព័រសកលចំនួន ២២ និងគេហទំព័រខ្មែរចំនួន ១៥ ) ក្នុង ចំណោម ២២០១ ត្រូវបានបិទខ្ទប់ ឬរឹតត្បិតដោយប្រើប្រាស់ប្រព័ន្ធបិទខ្ទប់ឈ្មោះដូមេនពីក្រុមហ៊ុនផ្តល់សេវាអ៊ី នធឺណិត (Viettel, Ezecom, Wicam, CamSIM, Private Company (iSEEK)។ វិធីសាស្ត្របិទខ្ទប់ដែល ប្រើប្រាស់ គឺជាការបិទខ្ទប់លក្ខណៈ DNS ដែលតាមរយៈការបិទខ្ទប់នេះ គេហទំព័រនឹងត្រូវនាំទៅកាន់ អាសយដ្ឋាន IP ដែលហួសសុពលភាព ដែលជាអាសយដ្ឋានរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ឬអាសយដ្ឋាន IP ក្លែងក្លាយ ១២៧.០.០.១។ ស្ថាប័នសារព័ត៌មានល្បីៗមួយចំនួន ក៏រកឃើញថាត្រូវបានគេរឹតត្បិតដែរ៖ វិទ្យុ សំឡេងប្រជាធិបតេយ្យ (វីអូឌី) វិទ្យុអាស៊ីសេរី និងសារព័ត៌មាន ខេមបូឌាដេលី។ [115] ការតាមដានប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មានរបស់ ម.ស.ម.ក បានបង្ហាញថា រដ្ឋាភិបាលបានបន្តបិទខ្ទប់បែបនេះចាប់ពីខែកញ្ញា ឆ្នាំ២០២៣ ដល់ខែសីហា ឆ្នាំ២០២៤ យ៉ាងមានប្រសិទ្ធភាពជាងមុន។ ក្នុងចំណោមគេហទំព័រចំនួន ៣៧ ដែល បានបិទខ្ទប់ ឬរឹតត្បិត គេរកឃើញថាឈ្មោះដូមេន ឬគេហទំព័រមួយចំនួនគឺនៅមានសកម្មភាពនៅឡើយ (១២ គេហទំព័រ) លែងដំណើរការ/មិនអាចចូលបាន (១៨ គេហទំព័រ) ឬដាក់លក់វិញ (៧ គេហទំព័រ)។ ដូមេនដែល បានបិទខ្ទប់ និងដាក់លក់វិញ នៅតែបន្តបិទខ្ទប់ដដែល ទោះបីជាគេហទំព័រទាំងនេះនឹងអាចមានសកម្មភាព ឡើងវិញ ប្រសិនបើក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតមិនលុបចេញពីបញ្ជីរឹតត្បិត។ [116]

យោងតាមអាជ្ញាធរ និយតករទូរគមនាគមន៍កម្ពុជាបានពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការ រីកសាយភាយមាតិកាអនឡាញខុសច្បាប់។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ និយតករបានបិទខ្ទប់គេហទំព័រ និងអាសយដ្ឋាន IP ជាង ៧.០០០។ វិធានការនេះ ដែលអនុវត្តដោយសហការជាមួយប្រតិបត្តិករទូរគមនាគមន៍ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ មានគោលបំណងបិទខ្ទប់ការផ្សព្វផ្សាយឯកសារគ្រោះថ្នាក់ រួមទាំងល្បែងស៊ីសង អនឡាញ រូបភាពអាសអាភាសកុមារ និងព័ត៌មានមិនពិត។ ចំណាត់ការរបស់និយតករទូរគមនាគមន៍កម្ពុជា ឆ្លុះ បញ្ចាំងឱ្យឃើញអំពីការព្រួយបារម្ភកាន់តែច្រើនអំពីការរីកសាយភាយនៃមាតិកាទាំងនេះ និងលទ្ធភាពនៃមាតិកា ទាំងនេះក្នុងការរារាំងដល់សណ្តាប់ធ្នាប់សង្គម ធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ និងជះឥទ្ធិពលអវិជ្ជមាន មកលើប្រជាពលរដ្ឋកម្ពុជា។ គំនិតផ្តួចផ្តើមនេះគូសបញ្ជាក់ឱ្យឃើញអំពីការប្តេជ្ញាចិត្តរបស់និយតករទូរគមនា គមន៍កម្ពុជា ចំពោះការប្រកាន់ជំហររបស់ខ្លួនក្នុងការរក្សាសន្តិសុខ និងធ្វើនិយតកម្មបរិយាកាសអនឡាញ។[117]

---

[115] ឡាំ សុជាតិ តាន់ ថារី ណុប វី ធន សុគន្ធា សិទ្ធី នូលីហ្សា សាមស៊ូឌីន និងខេលី កូ។ គម្រោងសកម្មភាពត្រួតពិនិត្យអ៊ីនធឺណិត iMAP កម្ពុជា របាយការណ៍ស្តីពីការរឹតត្បិតអ៊ីនធឺណិត ឆ្នាំ២០២៣។

[116] ដូចខាងលើ

[117] ទិត្យ គង់នៅ "និយតករទូរគមនាគមន៍កម្ពុជាបិទខ្ទប់គេហទំព័រជាង ៧.០០០ ដែលផ្សព្វផ្សាយមាតិកាខុសច្បាប់" (ខ្មែរថាមស៍ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២៤)

***អ្នកសារព័ត៌មានជួបការលំបាកក្នុងទទួលបានព័ត៌មានពីមន្ត្រីសាធារណៈ***

ការសម្ភាសន៍ដែលធ្វើឡើងសម្រាប់របាយការណ៍នេះបង្ហាញថា អ្នកសារព័ត៌មាននៅកម្ពុជាធ្វើប្រតិបត្តិការនៅក្នុងបរិយាកាសរឹតត្បិត ដែលរារាំងយ៉ាងខ្លាំងដល់សមត្ថភាពរបស់ពួកគេក្នុងការទទួលបានព័ត៌មាន។ អ្នកសារព័ត៌មានទាំង ២២ នាក់ដែលបានសម្ភាសន៍ បានរាយការណ៍អំពីការប្រឈមមុខនឹងឧបសគ្គក្នុងការទទួលបានព័ត៌មានចាំបាច់សម្រាប់សេចក្តីរាយការណ៍របស់ពួកគេ។ អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមនោះបានលើកឡើងថា៖

> **"ការគំរាមកំហែងធំបំផុតចំពោះសិទ្ធិទទួលព័ត៌មាននៅកម្ពុជា គឺអាជ្ញាធរដែលមិនផ្តល់ព័ត៌មានដល់អ្នកសារព័ត៌មាន។"**
>
> អ្នកសារព័ត៌មានដែល ម.ស.ម.ក បានជួបបានសម្ភាសន៍ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែមីនា ឆ្នាំ ២០២៤

«ការគំរាមកំហែងដ៏ធំបំផុតនោះគឺប្រព័ន្ធច្បាប់ អ្នកដែលមានអំណាច និងមុខតំណែងធំៗ។» អ្នកសារព័ត៌មានម្នាក់ទៀតបានលើកឡើងថា «ជួបបញ្ហាប្រឈមកាន់តែខ្ពស់នៅពេលចុះទៅប្រមូលព័ត៌មាន។»គួរឱ្យកត់សម្គាល់ផងដែរ អ្នកសារព័ត៌មានយ៉ាងតិចបីនាក់ បានលើកឡើងយ៉ាងច្បាស់អំពីការលំបាកក្នុងការទទួលបានព័ត៌មានពីមន្ត្រីរដ្ឋាភិបាល។ អ្នកសារព័ត៌មានម្នាក់បានកត់សម្គាល់អំពីការមិនសហការពីអាជ្ញាធរ រួមទាំងការបដិសេធលើការស្នើសុំសម្ភាសន៍ និងការបដិសេធទាំងស្រុងលើការចូលរួមព្រឹត្តិការណ៍មួយចំនួន។ អ្នកសារព័ត៌មានម្នាក់ទៀតបានលើកឡើងពីការបដិសេធញឹកញាប់លើសំណើសុំព័ត៌មាន ពីសំណាក់មន្ត្រីរដ្ឋាភិបាលជារឿយៗអមជាមួយនឹងការចោទប្រកាន់ថាផ្សព្វផ្សាយព័ត៌មានទៅឱ្យស្ថាប័នបរទេសក្នុងគោលបំណងមិនល្អ។ ប្រការនេះ បង្ហាញឱ្យឃើញអំពីនិន្នាការគួរឱ្យព្រួយបារម្ភដែលរើសអើងចំពោះការទទួលព័ត៌មានពីប្រភពផ្លូវការ និងរដ្ឋាភិបាល ដែលដាក់កំហិតលើសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការបំពេញតួនាទីដ៏សំខាន់របស់ពួកគេនៅក្នុងការផ្តល់ព័ត៌មានដល់សាធារណជន និងឱ្យអ្នកមានអំណាចទទួលខុសត្រូវ។

នៅខែមីនា ឆ្នាំ២០២២ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កញ្ញារិទ្ធ បានជំរុញឱ្យអ្នកនាំពាក្យរបស់រដ្ឋាភិបាលឆ្លើយតបនឹងសំណើ "ឱ្យទាន់ពេលវេលា ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់សាធារណជន និងប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន"។ លោកក៏អំពាវនាវឱ្យមន្ត្រីសារព័ត៌មានរបស់រដ្ឋាភិបាលកុំធ្វើការរើសអើងទៅកាន់សមាជិកនៃអង្គភាពសារព័ត៌មានផងដែរ។[118]ទោះបីជាយ៉ាងណាក៏ដោយ ម.ស.ម.ក បានកត់សម្គាល់ថា អ្នកនាំពាក្យដែលអ្នកសារព័ត៌មានឯករាជ្យទាក់ទងទៅនៅក្នុងអំឡុងពេលនៃរបាយការណ៍ តែងតែមិនអាច ឬមិនចង់ផ្តល់នូវព័ត៌មាន ឬមតិយោបល់ទៅលើករណីរសើបនោះទេ។[119]

---

[118] វិទ្យុអាស៊ីសេរីខ្មែរ "រដ្ឋមន្ត្រីព័ត៌មានកម្ពុជា ប្រាប់អ្នកនាំពាក្យរដ្ឋឱ្យធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ" (*វិទ្យុអាស៊ីសេរី*ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០២២)។

[119]កត់សម្គាល់ឃើញនៅ៖ ស៊ើង និមល់, Leila Goldstein, "ក្រុមហ៊ុន Meta ប្រានចោលអនុសាសន៍ដែលឱ្យព្យួរគណនីហ្វេសប៊ុកអតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន" (*សារព័ត៌មាន ខេមបូចា*,ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣) វិទ្យុអាស៊ីសេរីខ្មែរ "ហ៊ុន សែន រក្សាការតំឡើងតំណែងក្នុងវិស័យយោធាសម្រាប់កូនៗ

នៅចុងខែកញ្ញា ឆ្នាំ២០២៤ កញ្ញា ឃួន លក្ខិណា អ្នកសារព័ត៌មានឯករាជ្យ ដែលជាសមាជិកអ្នកសារព័ត៌មានស្ត្រីកម្ពុជាបានបញ្ជាក់ឱ្យដឹងអំពីឧបសគ្គដែលអ្នកសារព័ត៌មានឯករាជ្យជួបប្រទះក្នុងអំឡុងសិក្ខាសាលាមួយកាលពីពេលថ្មីៗនេះ។ ទោះបីជាអ្នកសារព័ត៌មានស្ត្រីកម្ពុជាបានដាក់សំណើជាច្រើនលើកច្រើនសារទៅក្រសួងព័ត៌មានក៏ដោយ ក៏កញ្ញា លក្ខិណា នៅមិនទាន់បានទទួលបណ្ណសម្គាល់ខ្លួនសារព័ត៌មានដែរ។ កង្វះការទទួលស្គាល់គុណវុឌ្ឍិផ្លូវការនេះ បង្កើតឱ្យមានភាពងាយរងគ្រោះ ដោយសារតែវារារាំងដល់សិទ្ធិទទួលព័ត៌មាន និងសិទ្ធិចូលរួមកម្មវិធីនានា ព្រមទាំងធ្វើឱ្យមានហានិភ័យនៃការយាយីកើនឡើង ឬការភាន់ច្រឡំពីសំណាក់អាជ្ញាធរដែលអាចនឹងមិនស្គាល់រូបនាងជាអ្នកអនុវត្តប្រព័ន្ធផ្សព្វផ្សាយស្របច្បាប់។ កញ្ញា លក្ខិណា បានសង្កត់ធ្ងន់ថាប្រសិនបើមិនមានបណ្ណសម្គាល់ខ្លួនសារព័ត៌មានទេ អ្នកសារព័ត៌មានប្រឈមនឹងឧបសគ្គកាន់តែខ្លាំងចំពោះការងាររបស់ពួកគេ ជាពិសេសនៅពេលរាយការណ៍អំពីព្រឹត្តិការណ៍ធំៗ ឬស្នើសុំព័ត៌មាន។ ជាការឆ្លើយតបទៅនឹងសំណើពាក់ព័ន្ធនឹងពាក្យស្នើសុំបណ្ណសម្គាល់ខ្លួនសារព័ត៌មាន លោក ទឹម សុលីណា អគ្គនាយករងនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ បានលើកឡើងថា អ្នកសារព័ត៌មានដែលប្រឈមនឹងការលំបាកដូច្នេះគួរតែដាក់លិខិតផ្លូវការមកកាន់ក្រសួងផ្ទាល់។ [120]

លើសពីនេះ អ្នកស្រី រឿន សំណាង និពន្ធនាយកសារព័ត៌មាន Say Pouch Hot News នៅខេត្តបាត់ដំបង បានរៀបរាប់អំពីបញ្ហាប្រឈមមួយចំនួនដែលអ្នកសារព័ត៌មានស្ត្រីបានជួបប្រទះ ជាពិសេសនៅពេលចុះបំពេញការងារផ្ទាល់នៅទីតាំង និងស្នើសុំសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន។ អ្នកស្រី សំណាង បានកត់សម្គាល់ថា ជារឿយៗអាជ្ញាធរបង្ហាញអំពីឥរិយាបថកង្វះការសហការ ដោយលើកឡើងអំពីការជាប់រវល់ ការប្រជុំ ឬធ្វើដំណើរទៅរាជធានីភ្នំពេញជាមូលហេតុដើម្បីគេចវេសពីការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយ។[121]

## *ដំណើរការឆ្ពោះទៅរកការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន*

ទោះបីជារដ្ឋធម្មនុញ្ញកម្ពុជាធានានូវសិទ្ធិទទួលព័ត៌មានក៏ដោយ ក៏កង្វះច្បាប់ជាក់លាក់បង្កើតឱ្យមានការអនុវត្តមិនមានសង្គតិភាពក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ដែលរឹតត្បិតទៅលើសិទ្ធិរបស់ពលរដ្ឋ។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានប្រឈមនឹងឧបសគ្គជាច្រើនពាក់ព័ន្ធនឹងសន្តិសុខជាតិ ការការពារព័ត៌មានផ្ទាល់ខ្លួន និងសមត្ថភាពអនុវត្ត។ បញ្ហាប្រឈមទាំងនេះគូសបញ្ជាក់ឱ្យឃើញអំពីតម្រូវការឱ្យមានក្របខណ្ឌច្បាប់ច្បាស់លាស់មួយ ដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាព។

---

ច្បង" (*វិទ្យុអាស៊ីសេរី* ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣) ប្រាក់ ចាន់ធុល "ក្រសួងអប់រំបញ្ជាឱ្យសាលាបិទជាបណ្តោះអាសន្ននៅក្នុងរយៈពេលពេលនៃកិច្ចប្រជុំកំពូលអាស៊ាន" (*Kiripost* ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២) Colin Meyn "បែឌិន ដាក់សម្ពាធលើលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាចំពោះសកម្មជនជាប់ពន្ធនាគារ", (*The Hill* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២); AFP "ប្រទេសកម្ពុជាបានជំរុញឱ្យបញ្ឈប់ការបណ្តេញចេញ" (*Taipei Times* ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣)។

[120] ស៊ើង និមល តាំង ប៉ហ៊ិច "អ្នកសារព័ត៌មានស្ត្រីស្នើសុំការយោគយល់ និងការសហការពីនគរបាល ក្រុមប្រព័ន្ធផ្សព្វផ្សាយសង្កត់ធ្ងន់អំពីគុណតម្លៃនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន" (សារព័ត៌មាន ខេមបូចា ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៤)

[121] ដូចខាងលើ

ឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានទទួលស្គាល់ជាលើកដំបូងពីភាពចាំបាច់នៃច្បាប់ដែលចែងពីសេរីភាពសារព័ត៌មាន ហើយបានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការទទួលបានព័ត៌មាននៅឆ្នាំ២០០៧។ [122] ទោះបីជាយ៉ាងណាក៏ដោយ មួយទស្សវត្សរ៍កន្លះក្រោយមក សេចក្តីព្រាងគោលនយោបាយនេះមិនទាន់បានក្លាយទៅជាច្បាប់មួយចែងពីការទទួលព័ត៌មាននៅឡើយ។ ក្រសួងពាក់ព័ន្ធបានបញ្ចប់នូវការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅខែសីហា ឆ្នាំ២០១៩។[123] នៅខែឧសភា ឆ្នាំ២០២១ ក្រសួងព័ត៌មានបានសន្យាបញ្ចប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់នេះជាមួយក្រសួងយុត្តិធម៌ក្នុងពេល 'ឆាប់ៗ' និងនិយាយថាសេចក្តីព្រាងនេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភាជាតិ ដើម្បីអនុម័តឱ្យបានមុនបំណាច់ឆ្នាំ២០២១។[124]នៅចុងឆ្នាំ២០២១ ក្រសួងព័ត៌មានបាននិយាយថាដំណើរការនៃការព្រាងច្បាប់នេះ គឺស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ ហើយការបញ្ចប់នៃសេចក្តីព្រាងច្បាប់នេះនឹងត្រូវបានពន្លឿនដើម្បីបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។[125]

នៅខែមិថុនា ឆ្នាំ២០២២ អង្គការសង្គមស៊ីវិលចំនួន ៣៣ បានដាក់ញត្តិជូនលោក ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៅក្នុងពេលនោះ ដើម្បីអំពាវនាវឱ្យអ្នកធ្វើច្បាប់ ឬតំណាងរាស្ត្រទទួលយកជាតុចូលរបស់ពួកគេទៅពិចារណា[126]កែសម្រួលសេចក្តីព្រាងច្បាប់ និងពន្លឿនឱ្យសេចក្តីព្រាងច្បាប់នេះក្លាយទៅជាច្បាប់។[127] ជាការកត់សម្គាល់ អង្គការសង្គមស៊ីវិលទាំងអស់នោះស្នើសុំឱ្យដកមាត្រា ២០.៧ និងមាត្រា១៥.៤ នៃសេចក្តីព្រាងច្បាប់ ដែលអនុញ្ញាតឱ្យស្ថាប័នសាធារណៈបដិសេធការបញ្ចេញ 'ព័ត៌មានសម្ងាត់ផ្សេងទៀត' និងកំណត់រយៈពេល៤០ថ្ងៃ មុននឹងការស្នើសុំម្តងទៀតអាចធ្វើឡើង។ ពួកគេក៏ជំរុញឱ្យកែសម្រួលខ្លឹមសារនៅក្នុងមាត្រាចំនួន ៦ ផ្សេងទៀត ដើម្បីបង្កើនការការពារអ្នករាយការណ៍ព័ត៌មានជាសម្ងាត់ផងដែរ។ [128] ជាការឆ្លើយតប ក្រសួងព័ត៌មានបានរៀបចំកិច្ចប្រជុំដើម្បីត្រួតពិនិត្យសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ និងនិយាយថាដំណើរការទាំងស្រុងអាចនឹងមានភាពយឺតយ៉ាវ។ [129] នៅខែកញ្ញា ឆ្នាំ២០២២ អ្នកនាំពាក្យក្រសួងព័ត៌មានលើកឡើងពីហេតុផលចំនួនបីដែលធ្វើឱ្យមានការពន្យាការអនុម័តសេចក្តីព្រាងច្បាប់នេះ៖ ភាគីពាក់ព័ន្ធនៅតែ

---

[122]MoNASRI, "សិទ្ធិទទួលបានព័ត៌មាន៖ ក្របខណ្ឌគោលនយោបាយជាក់លាក់មួយសម្រាប់ប្រទេសកម្ពុជា" (ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ៤ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ, "សេចក្តីណែនាំទូទៅអំពីសិទ្ធិទទួលបានព័ត៌មាននៅប្រទេសកម្ពុជា" (ខែសីហា ឆ្នាំ២០១០) ទំព័រ ១១។
[123]វួន ដារ៉ា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវបានបញ្ចប់នៅក្នុងខែបន្ទាប់" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩)។
[124] រី សុចាន់ "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននឹងត្រូវបានអនុម័តនៅឆ្នាំនេះ ក្រសួងបានសន្យា" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១)។
[125] សរ សុជាតិ"សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ និងត្រូវបានពន្លឿន" (*ខ្មែរថាមស៍*ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១)។
[126] ឃួន ណារីម, "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២)។
[127]ឡាយ សាមាន "ការអំពាវនាវរបស់អង្គការសង្គមស៊ីវិលឱ្យបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានក្នុងពេលឆាប់ៗ" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២)។
[128] ឃួន ណារីម, "នាយករដ្ឋមន្ត្រីអះអាងថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវអនុម័តក្រោយការបោះឆ្នោត" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣) ឃួន ណារីម, "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២)។
[129]លឹម ណារី "ការត្រួតពិនិត្យមួយផ្សេងទៀតនៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានសម្របសម្រួល" (*ខ្មែរថាមស៍*ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២) បុគ្គលិកសារព័ត៌មាន "សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានផ្អាកសម្រាប់ការវាយតម្លៃឡើងវិញ" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២)។

ផ្តល់ជាតុចូល ភាពចាំបាច់ក្នុងការធ្វើឱ្យប្រាកដថាច្បាប់នេះអនុលោមតាមក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ និងបញ្ហាប្រឈមដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ-១៩។ លោកក៏បានរំឭកឡើងវិញនូវការប្តេជ្ញាចិត្តរបស់ក្រសួងព័ត៌មានក្នុងការបញ្ចប់សេចក្តីព្រាងច្បាប់ និងទទួលបានការអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។[130]

នៅចុងខែតុលា ឆ្នាំ២០២២ ក្រសួងព័ត៌មានបានប្រកាសថា សេចក្តីព្រាងច្បាប់ ត្រូវបានបញ្ជូនទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីធ្វើការពិនិត្យ ប៉ុន្តែមិនបានផ្តល់ព័ត៌មានអំពីកាលប្បវត្តិ ឬពេលវេលាជាក់លាក់នៃការអនុម័តច្បាប់នេះនោះទេ។[131] នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ អតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា លោករំពឹងថាច្បាប់នេះនឹងត្រូវបានអនុម័ត 'បន្ទាប់ពីការបោះឆ្នោត [ខែកក្កដា ឆ្នាំ២០២៣] ឬប្រហែលជាមុនឆ្នាំ២០២៤ ឬឆ្នាំ២០២៥ ជាក់ជាមិនខាន' និងបានស្តីបន្ទោសផងដែរពីការពន្យាពេលជាបន្តបន្ទាប់លើកិច្ចការដែលត្រូវពិនិត្យទៅលើជាតុចូលដែលស្នើដោយអង្គការសង្គមស៊ីវិល។ លោក ឡាំ សុជាតិ នាយកប្រតិបត្តិនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ បាននិយាយថា ការលើកឡើងរបស់លោក ហ៊ុន សែន គឺដើម្បីផ្គាប់ចិត្តក្រុមអង្គការសង្គមស៊ីវិល និងសាធារណជន មុនការបោះឆ្នោតឆ្នាំ២០២៣ ចូលមកដល់ ហើយបានមើលឃើញថាការពន្យាពេលក្នុងការអនុម័តសេចក្តីព្រាងច្បាប់ក៏បានឆ្លុះបញ្ចាំងពីកង្វះខាតគណបក្សនយោបាយជំទាស់ដែលមានភាពប្រកួតប្រជែងខ្ពស់ធ្វើការជំរុញឱ្យអនុម័តនៅក្នុងរដ្ឋសភាជាតិ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ អ្នកនាំពាក្យក្រសួងសារព័ត៌មាន ត្រូវបានគេដកស្រង់សម្តីថា រដ្ឋាភិបាលមិនបញ្ចូលមតិរបស់អង្គការសង្គមស៊ីវិលណាដែលមើលឃើញថា 'មិនសមរម្យ'ទេ។ លោកបានបន្ថែមថា កង្វល់របស់អង្គការសង្គមស៊ីវិល គឺ'មិនមានអ្វីគួរឱ្យចាប់អារម្មណ៍នោះទេ' ពីព្រោះអង្គការទាំងអស់នោះ 'តែងតែមានទស្សនៈអវិជ្ជមានកន្លងមក'។[132]

នៅឆ្នាំ២០២៤ លោក ទេព អស្នារិទ្ធ អ្នកនាំពាក្យក្រសួងព័ត៌មាន បានប្រកាសថា ក្រសួងបានដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២៤ ដោយកំណត់អាទិភាពលើការអភិវឌ្ឍន៍ក្របខណ្ឌច្បាប់ និងគោលការណ៍បទប្បញ្ញត្តិ។ គំនិតផ្តួចផ្តើមនេះ ស្របតាមអាណត្តិស្នូលរបស់ក្រសួងក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលសន្តិសុខព័ត៌មាន ការពិចារណាលើលំហព័ត៌មាន និងវិធានការនានាដើម្បីប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។ ឯកសារនានាដែល ខេមបូចាបានត្រួតពិនិត្យ បង្ហាញឱ្យឃើញថាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបច្ចុប្បន្នគឺក្រសួងយុត្តិធម៌កំពុងធ្វើការត្រួតពិនិត្យ។ [133]

---

[130] វួន ដារ៉ា "ក្រសួងពន្យល់ពីវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ស្តីពី'សិទ្ធិទទួលព័ត៌មាន" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២)។

[131]យួន ណារីម "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលទន្ទឹមរងចាំយូរមកហើយកំពុងរងចាំការយល់ព្រមពីគណៈរដ្ឋមន្ត្រី" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២២)។

[132]អោម ប៊ុនធឿន, "នាយករដ្ឋមន្ត្រី៖ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានប្រហែលជាមុនឆ្នាំ២០២៤-២៥ ដោយសារតែតម្រូវការនៃការបញ្ចូលជាតុចូលទាំងអស់" (*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣); យួន ណារីម, "នាយករដ្ឋមន្ត្រីអះអាងថា ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននឹងត្រូវអនុម័តក្រោយការបោះឆ្នោត" (*សារព័ត៌មាន ខេមបូចា*ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣)។

[133]ស៊ឹង និមល "ក្រសួងព័ត៌មានបញ្ចប់ជាស្ថាពរនូវសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបន្ទាប់ពីមានការពន្យារពេលយ៉ាងយូរ" (ខេមបូចា ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤)

## V. សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

អំឡុងពេលនៃរបាយការណ៍នេះ បានបញ្ជាក់ឱ្យឃើញអំពីការបន្តធ្លាក់ចុះនៃសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិសេរីភាពសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស បានបន្តប្រឈមមុខនឹងសម្ពាធពីរាជរដ្ឋាភិបាលកម្ពុជា ដែលបំបិទលើសំឡេងរិះគន់ និងគ្រប់គ្រងលើអ្វីដែលរាយការណ៍។ សម្ពាធនេះបង្ហាញឡើងជាច្រើនទម្រង់ រួមទាំង ការឃាយឹតាមប្រព័ន្ធតុលាការ ការវាយប្រហារលើរូបកាយ ការបំភិតបំភ័យ និងការបង្កើតឱ្យមានបរិយាកាសដែលជំរុញឱ្យមានការដាក់កំហិតខ្លួនឯង ដែលសម្ពាធនេះរារាំងដល់សមត្ថភាពរបស់ពលរដ្ឋក្នុងការសម្ដែងមតិផ្ទុយ ឬលើកឡើងអំពីក្ដីបារម្ភពាក់ព័ន្ធនឹងបញ្ហារសើប។

អំឡុងពេលនៃរបាយការណ៍នេះ ក៏បានបង្ហាញអំពីការបន្តធ្លាក់នៃសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស បានប្រឈមមុខនឹងសម្ពាធពីរាជរដ្ឋាភិបាលកម្ពុជា ដែលបំបិទលើសំឡេងរិះគន់ និងគ្រប់គ្រងលើអ្វីដែលរាយការណ៍។ សម្ពាធនេះបង្ហាញឡើងជាច្រើនទម្រង់ រួមទាំង ការឃាយឹតាមប្រព័ន្ធតុលាការ ការវាយប្រហារលើរូបកាយ ការបំភិតបំភ័យ និងការបង្កើតឱ្យមានបរិយាកាសដែលជំរុញឱ្យមានការដាក់កំហិតខ្លួនឯង ដែលសម្ពាធនេះរារាំងដល់សមត្ថភាពរបស់ពលរដ្ឋក្នុងការសម្ដែងអំពីការមិនពេញចិត្ត ឬលើកឡើងអំពីក្ដីបារម្ភពាក់ព័ន្ធនឹងបញ្ហារសើប។ ជាងនេះទៅទៀត ស្របពេលដែលសេចក្ដីព្រាងច្បាប់សិទ្ធិទទួលព័ត៌មានបញ្ជាក់អំពីជំហានសក្ដានុពលឆ្ពោះទៅរកតម្លាភាពជាងមុនក៏ដោយ ក៏នៅមានឧបសគ្គសំខាន់ៗនៅក្នុងការសម្រេចឱ្យបាននូវសិទ្ធិនេះផងដែរ។ ការគោរព និងការការពារសិទ្ធិទទួលព័ត៌មានពេញលេញ ចាំបាច់ត្រូវមានវឌ្ឍនភាពនិងកំណែទម្រង់បន្ថែមទៀត និងលើសពីនេះទៅទៀត គឺត្រូវការច្បាប់មួយដែលពណ៌នាច្បាស់លាស់អំពីនីតិវិធី និងយន្តការសម្រាប់ការទទួលព័ត៌មាន។

ការសម្រេចបាននូវសិទ្ធិមនុស្ស និងសង្គមប្រជាធិបតេយ្យមួយឱ្យរីកចម្រើន គឺអាចសម្រេចទៅបាននៅពេលប្រជាពលរដ្ឋគ្រប់រូបអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិបានដោយមិនមានការរារាំង។ សិទ្ធិជាមូលដ្ឋាននេះ អមជាមួយនឹងកន្សោមសំខាន់ៗ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានដែលជាទឡ្ហីករណ៍មួយដើម្បីឱ្យសិទ្ធិផ្សេងៗទៀតអាចសម្រេចទៅបាន។ ទោះបីជាកម្ពុជាប្ដេជ្ញាចិត្តការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដូចចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ ក៏ដោយ ក៏តថភាពជាក់ស្ដែងនៅខ្វះការប្ដេជ្ញាចិត្តទាំងនេះ។ ដើម្បីដោះស្រាយក្ដីបារម្ភនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ដើម្បីលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិឡើងវិញ។ ត្រូវវិធានការចាំបាច់ដើម្បីអនុវត្តការប្ដេជ្ញាចិត្តទាំងនេះឱ្យបានជាវឌ្ឍនភាពពិតប្រាកដ។

សិទ្ធិមនុស្សអាចត្រូវបានធានា និងលទ្ធិប្រជាធិបតេយ្យអាចរីកចម្រើនទៅបាន លុះត្រាតែប្រជាពលរដ្ឋគ្រប់ៗរូបមានសេរីភាពក្នុងអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលមានរួមនឹងកន្សោមចំនួនពីរ គឺសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលជាកត្តាដ៏សំខាន់មួយសម្រាប់ការអនុវត្តសិទ្ធិផ្សេងទៀត។ នៅឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដោយប្ដេជ្ញាការពារសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន និងលើកកម្ពស់លិទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ខ្លួន។ រយៈពេលជាង ៣០ឆ្នាំក្រោយមក ការសន្យានេះមិនទាន់ត្រូវបានបំពេញនៅឡើយទេ ហើយប្រជាជនកម្ពុជានៅតែចង់បាន

សង្គមមួយយុត្តិធម៌ ដែលសិទ្ធិរបស់ខ្លួនរួមបញ្ចូលទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ត្រូវបានធានាយ៉ាងពេញលេញ។ ដូច្នេះ ជារឿងសំខាន់ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយជាបន្ទាន់ នូវស្ថានភាពធ្លាក់ចុះនៃសេរីភាពខាងការបញ្ចេញមតិនៅប្រទេសកម្ពុជា។ សកម្មភាពជាក់ស្តែង គឺត្រូវការជាចាំបាច់ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទាំងនេះឱ្យក្លាយជាការពិត។

ជាចុងក្រោយ ការគាបសង្កត់ទៅលើសេរីភាពខាងការបញ្ចេញមតិ បង្កការគំរាមកំហែងយ៉ាងខ្លាំងចំពោះវឌ្ឍនភាពប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ឈប់ការដៅមុខសញ្ញាលើសំឡេងរិះគន់ ដោយធានាបាននូវការទទួលខុសត្រូវពីបទរំលោភបំពាន និងបណ្តុះនូវបរិយាកាសមួយដែលពលរដ្ឋអាចអនុវត្តសិទ្ធិរបស់ពួកគេបានដោយមិនមានការភ័យខ្លាច។ ប្រសិនបើអនុវត្តមិនបានបែបនេះ ប្រជាធិបតេយ្យបន្តធ្លាក់ចុះ ហើយកម្ពុជានឹងត្រូវឃ្លាតឆ្ងាយពីសហគមន៍អន្តរជាតិ។

ដូច្នេះ ម.ស.ម.ក សូមជំរុញលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលចាត់វិធានការជាក់ស្តែង ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម **ស្របតាមអនុសាសន៍ដែលរដ្ឋាភិបាលបានទទួលនៅក្នុងការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ចុងក្រោយ**[134]**៖**

| | |
|---|---|
| ១ | លុបចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ឱ្យស្របតាមកាតព្វកិច្ចរបស់កម្ពុជាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាសិទ្ធិខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានរបស់បុគ្គលគ្រប់រូបត្រូវបានការពារនៅក្នុងប្រទេសកម្ពុជា។ |
| ២ | ត្រួតពិនិត្យឡើងវិញលម្អិតអំពីច្បាប់មានស្រាប់ទាំងអស់ដែលរឹតត្បិតមិនសមស្រមទៅលើសេរីភាពខាងការបញ្ចេញមតិ ដើម្បីឱ្យច្បាប់ទាំងនេះស្រមទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ការត្រួតពិនិត្យឡើងវិញនេះ ត្រូវរួមបញ្ចូលដូចជា ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត និងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌស្តីពីការប្រមាថព្រះមហាក្សត្រ ការញុះញង់ និងការបរិហារកេរ្តិ៍។ |
| ៣ | បញ្ចូលជាតុចូលពីភាគីពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីធានាថាសេចក្តីព្រាងច្បាប់ចុងក្រោយស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងអនុម័តឱ្យទាន់ពេលវេលា ដោយធានាបានថាច្បាប់នេះអនុលោមពេញលេញតាមបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិទទួលព័ត៌មាន រួមទាំងបញ្ញត្តិសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ការកម្រិតវិសាលភាពនៃការលើកលែង និងយន្តការត្រួតពិនិត្យឯករាជ្យ។ |

[134]ក្រុមការងារក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ សម័យប្រជុំលើកទី ៤៦។ ព័ត៌មានចងក្រងរៀបចំឡើងដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ A/HRC/WG.6/46/KHM/2. (ថ្ងៃទី២៩ ខែមេសា–ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)។ សូមមើលផងដែរ ក្រុមការងារក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ សម័យប្រជុំលើកទី ៤៦។ សេចក្តីសង្ខេបអំពីការដាក់ឯកសាររបស់ភាគីពាក់ព័ន្ធអំពីកម្ពុជា។
A/HRC/WG.6/46/KHM/3. (ថ្ងៃទី២៩ ខែមេសា–ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)។ សូមមើលផងដែរ ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី ៥៧។ របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់អំពីកម្ពុជា។ A/HRC/57/17. (ថ្ងៃទី០៩ ខែកញ្ញា–ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤)

| | |
|---|---|
| ៤ | បញ្ឈប់រាល់ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងធានានូវបរិយាកាសអំណោយផលដែលអាចឱ្យពួកគេធ្វើការស្របច្បាប់ដោយសេរី ដោយគ្មានការភ័យខ្លាច ឬឧបសគ្គ ការរារាំង ឬការយាយីតាមប្រព័ន្ធតុលាការ និងការយាយីតាមរូបភាពផ្សេងៗទៀត។ |
| ៥ | ដោះលែងជាបន្ទាន់នូវអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ដែលកំពុងជាប់ពន្ធនាគារ ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងទម្លាក់ការចោទប្រកាន់ទៅលើពួកគេពាក់ព័ន្ធទៅនឹងសកម្មភាពសារព័ត៌មានស្របច្បាប់ ឬការងារសិទ្ធិមនុស្សដូចជាការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ញុះញង់ ឬផ្សព្វផ្សាយព័ត៌មានមិនពិត។ |
| ៦ | ត្រូវធានាថា ការវាយប្រហារ និងបទល្មើសដែលប្រព្រឹត្តទៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សត្រូវបានស៊ើបអង្កេតយ៉ាងច្បាស់លាស់ ហ្មត់ចត់ និងឯករាជ្យ ហើយជនល្មើសត្រូវបាននាំយកទៅកាត់ទោសដើម្បីបញ្ឈប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីឱ្យពួកគេធ្វើការដោយសុវត្ថិភាព។ |
| ៧ | ត្រូវបញ្ឈប់ការគំរាមកំហែង និងការបំភិតបំភ័យអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាទាំងឡាយដែលមានលក្ខណៈរសើប ដូចជារឿងនយោបាយ ជម្លោះដីធ្លី ឬអំពើពុករលួយជាដើម ដើម្បីធានាថាអ្នកសារព័ត៌មានអាចបំពេញតួនាទីរបស់ខ្លួនក្នុងការរាយការណ៍ដល់សាធារណជនលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ ដោយមិនគិតពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជាយល់ឃើញបែបណានោះឡើយ។ |
| ៨ | លើកកម្ពស់បរិយាកាសប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងឯករាជ្យ តាមរយៈការរារាំងពីការជ្រៀតជ្រែកហួសហេតុនៅក្នុងប្រតិបត្តិការ ការផ្តល់អាជ្ញាបណ្ណ និងកម្មសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយ។ ត្រូវធានាឱ្យបាននូវសិទ្ធិទទួលព័ត៌មានសារធាណៈដោយយុត្តិធម៌ និងសមធម៌សម្រាប់ស្ថាប័នផ្សព្វផ្សាយទាំងអស់។ |
| ៩ | លុបចោលលក្ខខណ្ឌដែលតម្រូវឱ្យអង្គភាពសារព័ត៌មានត្រូវតែមានអាជ្ញាបណ្ណពីក្រសួងព័ត៌មាន មុននឹងអាចបោះពុម្ពផ្សាយ និងបង្កើតនូវស្ថាប័នគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដាច់ដោយឡែកមួយពីរាជរដ្ឋាភិបាល ដើម្បីធានាថាបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយត្រូវបានធ្វើឡើងដោយគោរពសេរីភាពសារព័ត៌មាន និងមិនលម្អៀងទាំងអស់។ |
| ១០ | ត្រូវធានាឱ្យបាននូវការផ្សព្វផ្សាយព័ត៌មានក្នុងកម្រិតអតិបរិមានៅទូទាំងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នសាធារណៈទាំងអស់ ជាពិសេសទៅកាន់អ្នកសារព័ត៌មាន។ ត្រូវចាត់វិធានការណ៍ដើម្បីលុបបំបាត់រាល់អាកប្បកិរិយារើសអើងចំពោះអ្នកសារព័ត៌មានជាស្ត្រី និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងផ្នែកយេនឌ័រ ដើម្បីអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងធ្វើការងារស្របច្បាប់របស់ពួកគេដោយគ្មានការរើសអើង។ |

| | |
|---|---|
| ១១ | មិនត្រូវបាត់វិធានការរឹតត្បិតហួសហេតុលើសេរីភាពប្រព័ន្ធអ៊ីនធឺណិត រួមទាំងប្រព័ន្ធអ៊ីនធឺណិត ការបិទខ្ទប់គេហទំព័រ និងការឃ្លាំមើលលើប្រព័ន្ធអ៊ីនធឺណិត។ លើកកម្ពស់ចំណេះដឹងឌីជីថល និងធានាបាននូវសិទ្ធិទទួលព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ពលរដ្ឋគ្រប់រូប។ |

## VI. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ I៖ កម្រងសំណួរសម្រាប់សម្ភាសន៍

**កម្រងសំណួរសម្រាប់អ្នកសារព័ត៌មាន**

១. តើអ្នកគិតថាអ្វីជាការគំរាមកំហែងធំបំផុតទៅលើសេរីភាពសារព័ត៌មាន និងការទទួលព័ត៌មាននៅប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បឹត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មានពីសំណាក់រាជរដ្ឋាភិបាល ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្ដឹងដែរឬទេ? បើបានដាក់ពាក្យបណ្ដឹង តើអ្នកទទួលការឆ្លើយតបចំពោះពាក្យបណ្ដឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការដោយសេរី និងគ្មានការភ័យខ្លាចពីការគាបសង្កត់ដែរ ឬទេ?

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗសម្រាប់អ្នកសារព័ត៌មាន?

៥. តើអ្នកមានការលំបាកក្នុងការទទួលបានព័ត៌មានសម្រាប់ការសរសេរអត្ថបទរបស់អ្នកដែរ ឬទេ? បើមាន តើអ្នកអាចផ្ដល់ឧទាហរណ៍ខ្លះបានដែរឬទេ?

៦. តើមានប្រធានបទណាខ្លះដែលអ្នកមិនព្រមយកមកសរសេរដែរឬទេ? បើមាន ហេតុអ្វី?

៧. តើអ្នកធ្លាប់ជួបនូវផលលំបាកនៅពេលដែលអ្នកអនុវត្តសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មានដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសជាមួយស្ត្រី)

**កម្រងសំណួរសម្រាប់អ្នកការពារសិទ្ធិមនុស្ស**

១. តើអ្នកគិតថាអ្វីជាការគំរាមកំហែងធំបំផុតទៅលើសេរីភាពខាងការបញ្ចេញមតិ នៅប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បឹត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស ពីសំណាក់រាជរដ្ឋាភិបាល ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្ដឹងដែរឬទេ? បើបានដាក់ពាក្យបណ្ដឹង តើអ្នកទទួលការឆ្លើយតបចំពោះពាក្យបណ្ដឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការដោយសេរី និងគ្មានការភ័យខ្លាចពីការគាបសង្កត់ដែរឬទេ?

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗសម្រាប់អ្នកការពារសិទ្ធិមនុស្ស?

៥. តើមានបញ្ហាសិទ្ធិមនុស្សណាខ្លះដែលអ្នកមិនព្រមធ្វើការតស៊ូមតិដែរឬទេ? បើមាន ហេតុអ្វី?

៦. តើអ្នកធ្លាប់ជួបនូវផលលំបាកនៅពេលដែលអ្នកអនុវត្តសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស ដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសជាមួយស្ត្រី)

